ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលនយោបាយ
# អភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា
# ២០២១-២០៣០

**រៀបរៀង និងផ្សព្វផ្សាយដោយ៖**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក.ស.ក./MAFF)

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (អ.ស.ផ.ស./GDAHP)

**គាំទ្រដោយ៖**

អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO)

កម្មវិធីឡជីវឧស្ម័នជាតិ (NBP)

មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC)

ក្រុមហ៊ុនដៃគូសម្រាប់នវានុវត្តន៍ (PfI)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលនយោបាយ
# អភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា
# ២០២១-២០៣០

ឆ្នាំ ២០២១

# **អារម្ភកថា**

យើងទាំងអស់គ្នាបានជ្រាបយ៉ាងច្បាស់លាស់ហើយថា បច្ចុប្បន្ននេះដោយសារវិបត្តិជាសាកលបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលបានកើតឡើងក្នុងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ ឆ្នាំ២០២១នេះ បានក្លាយជាបញ្ហាប្រឈមមួយធ្វើឱ្យប៉ះពាល់ដល់សង្គម-សេដ្ឋកិច្ចជាតិយើង ជាពិសេសជីវភាពរស់នៅរបស់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវវិធានការយ៉ាងមុតស្រួចដើម្បីជួយស្រោចស្រង់ កាត់បន្ថយផលប៉ះពាល់ និងគាំទ្រលើកស្ទួយនូវកំណើនសេដ្ឋកិច្ចជាតិ ដែលក្នុងនោះវិស័យកសិកម្មគឺជាវិស័យអាទិភាពនាំមុខមួយក្នុងចំណោមវិស័យអាទិភាពសំខាន់ៗដទៃទៀតរបស់រាជរដ្ឋាភិបាល ដែលវិស័យនេះបាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ធានាបាននូវសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាកសិករដែលពឹងអាស្រ័យលើការប្រកបមុខរបរកសិកម្មជាចម្បង។

ដោយឡែក គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០២១-២០៣០ ក៏នឹងត្រូវដាក់ចេញឱ្យអនុវត្តនាពេលខាងមុខដោយមានគោលដៅចម្បងគឺបង្កើនតម្លៃបន្ថែម និងបង្កើនផលិតភាពកសិកម្ម ឆ្លើយតបទៅនឹងវឌ្ឍនាការនៃបដិវត្តន៍ឧស្សាហកម្មទី៤ និងបច្ចេកវិទ្យាឌីជីថល ពិសេសក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥របស់រាជរដ្ឋាភិបាលក្នុងទស្សនទានថ្មីនៃកិច្ចអភិវឌ្ឍសង្គមសេដ្ឋកិច្ច ដើម្បីធានាបាននូវប្រព័ន្ធស្បៀងឆ្លើយតបទៅនឹងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជានាឆ្នាំ២០៣០ នេះផងដែរ។

ទន្ទឹមនឹងនេះ កម្មវិធីឡជីវឧស្ម័នជាតិត្រូវបានដំណើរការអនុវត្តចាប់តាំងពីឆ្នាំ២០០៦ ដែលកម្មវិធីនេះគ្រប់គ្រង ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រតិបត្តិដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។ ឆ្លើយតបនឹងវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងវិស័យជីវឧស្ម័ន ក្រុមការងារបានរៀបចំគោល-នយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥ នៅឆ្នាំ២០១៦ ក្នុងគោលបំណងគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យនេះ ប្រកបដោយភាពវៃឆ្លាត នវានុវត្តន៍ និងបរិយាប័ន្ន។ ជាមួយគ្នានេះ វិស័យជីវឧស្ម័នបានឆ្លងកាត់ដំណើរវិវត្តន៍ជាច្រើន ដោយមានការវិនិយោគឡជីវឧស្ម័នខ្នាតធំ មិនមែនមានតែនៅកសិដ្ឋានចិញ្ចឹមសត្វប៉ុណ្ណោះទេ ព្រមទាំងមាននៅតាមសហគ្រាសកសិ-ឧស្សាហកម្មទៀតផង ដូចជារោងចក្រកែច្នៃដំឡូងមី ជាដើម។

ដោយមានភាពចាំបាច់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតក្រុមការងារបច្ចេកទេសសម្រាប់រៀបចំគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា កាលពីខែមករា ឆ្នាំ២០២១ កន្លងមក។ ជាលទ្ធផលឯកសារគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០ ត្រូវបានរៀបចំឡើងស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍ និងការប្រើប្រាស់ឡជីវឧស្ម័នប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ជាពិសេសចូលរួមអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅកម្ពុជាដែលជាបរិសទានមួយធ្វើឱ្យបរិស្ថានល្អសម្រាប់អនាគតនៃជីវិតរស់នៅរបស់សត្តនិករទាំងឡាយឱ្យកាន់តែល្អប្រសើរឡើង។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំក្រសួង ក្រុមការងារបច្ចេកទេសសម្រាប់រៀបចំគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ន អគ្គនាយកដ្ឋាន

សុខភាពសត្វ និងផលិតកម្មសត្វ និងគ្រប់ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់ដែលបានចូលរួមគាំទ្រ ក្នុងការរៀបចំគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាដ៏មានសារៈសំខាន់នេះឡើង។ ទោះជាយ៉ាងណា ខ្ញុំជឿជាក់ថាឯកសារគោលនយោបាយដែលបានរៀបចំចងក្រងនេះពិតជានៅមានចំណុចខ្វះខាតនៅឡើយរួមទាំងអក្ខរាវិរុទ្ធ និងខ្លឹមសារ ជាដើម។ ជាមួយនេះដែរ ខ្ញុំរង់ចាំទទួលដោយរីករាយនូវមតិស្ថាបនាពីប្រិយមិត្តអ្នកអានដោយមេត្រីភាព។

ជាថ្មីម្តងទៀត ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីឱ្យគ្រួសារកសិករ សហគមន៍ជនបទ និងកសិធុរជនមានជីវភាពរស់នៅកាន់តែប្រសើរឡើង និងបង្កើនផលចំណេញពីធុរកិច្ចរបស់ខ្លួន ក្នុងបរិស្ថានល្អនិងមាននិរន្តរភាព តាមរយៈការប្រើប្រាស់ឡជីវឧស្ម័នប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងចីរភាព។

ថ្ងៃសុក្រ ៥រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក. ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# មាតិកា


អារម្ភកថា

១. សេចក្តីផ្តើម ...... ១

១.១ ស្ថានភាព និងការព្យាករណ៍នៃអនុវិស័យចិញ្ចឹមសត្វ ...... ២

១.២ ស្ថានភាពនៃឧស្សាហកម្មកែច្នៃកសិផល ...... ៤

១.៣ វិស័យកសិកម្ម និងការប្រែប្រួលអាកាសធាតុ ...... ៥

១.៤ ស្ថានភាពនៃការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា ...... ៦

១.៥ កាលានុវត្តភាព និងការប្រឈម ...... ១០

១.៦ ឡជីវឧស្ម័ននិងការរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ...... ១២

២. ចក្ខុវិស័យ ...... ១៣

៣. គោលបំណង និងគោលដៅ ...... ១៣

៣.១ គោលបំណង ...... ១៣

៣.២ គោលដៅ ...... ១៣

៤. យុទ្ធសាស្ត្រដើម្បីសម្រេចគោលដៅ ...... ១៤

៤.១ ពង្រឹងការងារអភិបាលកិច្ច ...... ១៤

៤.២ ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន ...... ១៥

៤.៣ លើកកម្ពស់គុណភាពឡជីវឧស្ម័ន និងប្រយោជន៍ឡជីវឧស្ម័ន ...... ១៥

៤.៤ លើកកម្ពស់ការលើកទឹកចិត្ត និងការឧបត្ថម្ភធន ...... ១៦

៤.៥ បង្កើនទីផ្សារឥណទានកាបូនដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ...... ១៧

៥. ផែនការសកម្មភាព ...... ១៧

៥.១ ការបង្កើតយន្តការអនុវត្តន៍ ...... ១៧

៥.២ ក្របខ័ណ្ឌតាមដានត្តិ ...... ២២

៥.៣ ហិរញ្ញវត្ថុ ...... ២២

៥.៤ ការអភិវឌ្ឍធនធានមនុស្ស ...... ២៣

៥.៥ ការអនុវត្តគោលនយោបាយ ...... ២៤

៥.៥.១ ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន ...... ២៤

៥..៥.២ ជំរុញអភិបាលកិច្ច ការសម្របសម្រួល និងការធ្វើរបាយការណ៍ ...... ២៦

៥.៥.៣ លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធគុណភាពឡជីវឧស្ម័ន ...... ២៧

៥.៥.៤ យន្តការគាំទ្រសារពើពន្ធ និងមិនមែនសារពើពន្ធ ...... ២៧

៥.៥.៥ បង្កើតនិងជំរុញសហគមន៍អ្នកប្រើប្រាស់ឡជីវឧស្ម័ន ...... ២៩

៥.៥.៦ ជំរុញការស្រាវជ្រាវ អភិវឌ្ឍន៍ និងការប្រើប្រាស់ឡជីវឧស្ម័ន ...... ២៩

៥.៥.៧ បង្កើនការវិភាជន៍ថវិកាទៅអគ្គនាយដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីអភិវឌ្ឍន៍ជីវឧស្ម័ន ...... ៣០

៥.៥.៨ ការគៀរគរហិរញ្ញប្បទានអាកាសធាតុ ...... ៣០

៦. ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃគោលនយោបាយ ........ ៣១
៧. សេចក្តីសន្និដ្ឋាន ........ ៣២
ពាក្យសរសេរកាត់ ........ ៣៤
ឧបសម្ព័ន្ធ "ក" ម៉ាទ្រីសនៃការអនុវត្តក្របខ័ណ្ឌគតិយុត្ត ........ ៣៦
ឧបសម្ព័ន្ធ "ខ" ម៉ាទ្រីសនៃវិធានការគោលនយោបាយ និងផែនការសកម្មភាព ........ ៣៧
សន្ទានុក្រម ........ ៥០

# គោលនយោបាយ
# អភិវឌ្ឍន៍ឡូជីវឧស្ម័ននៅកម្ពុជា ២០២១ - ២០៣០

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាបានឆ្លងកាត់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចបានយ៉ាងឆាប់រហ័សដោយសារការរក្សាបាននូវសន្តិភាព និងស្ថិរភាពនៃកំណើនសេដ្ឋកិច្ចរឹងមាំ ក្នុងរយៈពេលប៉ុន្មានទសវត្សថ្មីៗនេះ។ រាជរដ្ឋាភិបាលមានចក្ខុវិស័យក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ឆ្លើយតបនឹងចក្ខុវិស័យនេះ វិស័យកសិកម្ម ត្រូវបានចាត់ទុកជា វិស័យអាទិភាពមួយនៅក្នុងរបៀបវារៈអភិវឌ្ឍន៍ជាតិ ដូចដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩ -២០២៣។

កំណើននៃវិស័យកសិកម្មបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរង្វង់អត្រា៤%ក្នុងមួយឆ្នាំនៅអំឡុងឆ្នាំ២០១១-២០១៧[១] បើទោះបីជាការរួមចំណែករបស់វិស័យនេះទៅក្នុងផលិតផលក្នុងស្រុកសរុប (ផសស)បានធ្លាក់ចុះប្រមាណ ១,៨%ក្នុងមួយឆ្នាំក៏ដោយ តែវិស័យនេះ នៅតែជាវិស័យចម្បងមួយក្នុងចំណោមវិស័យដទៃទៀត ដោយការបង្កើតការងារក្នុងស្រុក(៣៧%នៃកម្លាំងពលកម្មសរុប) និងប្រាក់ចំណូលនៅតំបន់ជនបទ។

ផែនការមេកវិស័យកសិកម្មឆ្នាំ២០៣០បានបង្ហាញនូវចក្ខុវិស័យសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មៈ កសិកម្មកម្ពុជាជាកសិកម្មទំនើបកម្មមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តភាពដែលនាំ ដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។ ក្នុងនោះមានគោលដៅសំខាន់គឺ ១) ជំរុញកំណើន នៃតម្លៃបន្ថែមរបស់វិស័យកសិកម្មទៅក្នុងសេដ្ឋកិច្ចជាតិក្នុងរង្វង់ ៣%ក្នុងមួយឆ្នាំ និង ២) បង្កើនផលិតភាពពលកម្មក្នុងវិស័យកសិកម្មពី ១.៩៨៦ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ដល់ ៤.៦២៥ ដុល្លារអាមេរិក/មនុស្សម្នាក់ នៅឆ្នាំ២០៣០។ ក្នុងកម្រិតយុទ្ធសាស្ត្រ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ ដោយកំណត់តម្លៃបន្ថែមសរុបរបស់វិស័យកសិកម្ម (Gross Value Added-GVA) សម្រេចបានក្នុងរង្វង់ ៣% ទៅ ៥%ក្នុងមួយឆ្នាំ និងមានការព្យាករណ៍នៃគោលដៅកំណើនវិស័យកសិកម្មនឹងត្រូវសម្រេចឱ្យបានក្នុងរង្វង់៤%ក្នុង មួយឆ្នាំ ។ យុទ្ធសាស្ត្រគន្លឹះដើម្បីសម្រេចបានគោលដៅកំណើននេះរួមមាន ការកែលម្អផលិតភាព ពិពិធកម្ម និង ពាណិជ្ជូបនីយកម្មនៃវិស័យកសិកម្ម ការចិញ្ចឹមសត្វ និងវារីវប្បកម្មប្រកបដោយចីរភាព ព្រមទាំងអភិរក្ស និងការពារ ព្រៃឈើ និងជលផលផងដែរ។

អនុវិស័យចិញ្ចឹមសត្វ បានដើរតួនាទីចម្បងទី៣ ក្នុងការរួមចំណែកដល់កំណើននៃវិស័យកសិកម្ម ដែលបានកើនឡើង ១១% ក្នុងអំឡុងឆ្នាំ២០១០-២០១៩[២]។ ប្រកាសលេខ៥៤៩ត្រូវបានបង្កើតឡើងដើម្បីធានាឱ្យបាននូវការផ្គត់ផ្គង់ផលិតផលសត្វប្រកបដោយចីរភាព ទាំងគុណភាព និងបរិមាណសម្រាប់ទីផ្សារក្នុងស្រុក និងនាំចេញ។ ប្រកាសនេះក៏បានកំណត់ចំណាត់ថ្នាក់កសិដ្ឋាន បង្កើតបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីសម្រាប់ផលិតកម្មបសុសត្វ និងជាពិសេស ការតម្រូវឱ្យមានកន្លែងប្រព្រឹត្តកម្មជីវសាស្ត្រ និងការគ្រប់គ្រងលាមកសត្វ។ប្រកាសនេះតម្រូវឱ្យ

---

*[១] ធ្លាក់ចុះពី ៥.៨% ក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ២០០៤-២០១០។ ការចូលរួមរបស់វិស័យនេះទៅក្នុងផ.ស.សបានថយចុះពី៣៤.៦% នៅឆ្នាំ២០១១ទៅ២៣.៦% នៅឆ្នាំ២០១៧។*

*[២] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣*

កសិដ្ឋានបែបពាណិជ្ជកម្ម ទាំងអស់ត្រូវគោរពតាមបទដ្ឋានបច្ចេកទេស ដែលរាប់បញ្ចូលទាំងប្រព័ន្ធជីវសុវត្ថិភាព ការគ្រប់គ្រងសំណល់លាមកសត្វ អនាម័យ និងកិច្ចការពារបរិស្ថាន រួមមានការបង្ការក្លិនសាយភាយ និងសំលេងរំខានជាដើម។

ក្រៅពីអនុវិស័យចិញ្ចឹមសត្វ គោលនយោបាយជីវឧស្ម័ននេះក៏នឹងគាំទ្រដល់ការអនុវត្តន៍នៃគោលនយោបាយជាតិ ស្តីពីជំឡូងមី និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មផងដែរជាពិសេសទាក់ទងនឹងការជួយគាំទ្របណ្តារោងចក្រ កែច្នៃកសិផលឱ្យមានប្រព្រឹត្តកម្មសំណល់រាវ តាមរយៈ ប្រព័ន្ធជីវឧស្ម័ន ដើម្បី ទាញ យក ថាមពល សម្រាប់ប្រើប្រាស់ក្នុង ដំណើរការផលិតកម្ម។ ទាំងអស់នេះ នឹងជួយកែលម្អសមិទ្ធកម្មសេដ្ឋកិច្ចរបស់រោងចក្រទាំងនេះឱ្យប្រសើរឡើង បង្កើន ការធ្វើពាណិជ្ជកម្ម និងនវានុវត្តន៍។ ក្នុងកម្រិតអន្តរជាតិ គោលនយោបាយនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងរបាយការណ៍បច្ចុប្បន្នភាពនៃការចូលរួមចំណែករបស់កម្ពុជា ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ រួម បញ្ចូល ទាំង ការ កាត់ បន្ថយ ការ បញ្ចេញ ឧស្ម័ន ផ្ទះកញ្ចក់ និង បង្កើន ភាព ធន់ នឹង ការ ប្រែប្រួលអាកាសធាតុ។

ដោយសារមានការរីកចម្រើនយ៉ាងឆាប់ រហ័ស ក្នុង វិស័យ ជីវឧស្ម័ន និងការប្រែប្រួលសេដ្ឋកិច្ចជនបទទើបគោលនយោបាយ អភិវឌ្ឍន៍ ឡជីវឧស្ម័ន នៅ កម្ពុជា ឆ្នាំ២០១៦-២០២៥ ត្រូវ បាន ធ្វើ បច្ចុប្បន្នភាព និងជំនួសដោយគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០។ ម្យ៉ាងទៀតគោលនយោបាយអភិវឌ្ឍន៍ឡជីវ-ឧស្ម័ននៅកម្ពុជាថ្មីនេះក៏ត្រូវបានបន្ស៊ីជាមួយផែនការអភិវឌ្ឍវិស័យកសិកម្មឆ្នាំ២០១៩-២០២៣ គោលនយោបាយនិងផែនការអភិវឌ្ឍន៍ វិស័យដទៃទៀតដែលពាក់ព័ន្ធនឹងជីវឧស្ម័ន។ គោលនយោបាយថ្មីនេះនឹងផ្តល់នូវគោលបំណងនិងគោលដៅច្បាស់លាស់ដើម្បីផ្តល់ទិសដៅ និងជួយពន្លឿនការប្រើប្រាស់ឡជីវឧស្ម័នគ្រប់ទំហំទាំងអស់នៅក្នុងអនុ-វិស័យចិញ្ចឹមសត្វ និងវិស័យកែច្នៃ កសិផលដទៃទៀតនៅកម្ពុជា។

## ១.១ ស្ថានភាព និងការព្យាករណ៍នៃអនុវិស័យចិញ្ចឹមសត្វ

តារាងទី១ បង្ហាញពីស្ថិតិផលិតកម្មសត្វតាមប្រភេទនៃការចិញ្ចឹម និងការប្រែប្រួលនៃការចិញ្ចឹមសត្វនៅក្នុងអំឡុង ឆ្នាំ២០១៦-២០២០។ តារាងនេះបង្ហាញថា ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតែជាអ្នកផ្គត់ផ្គង់ផលិតផលសត្វចម្បងនៅឡើយលើកលែងតែការចិញ្ចឹមជ្រូក។ កសិដ្ឋាន ចិញ្ចឹម ជ្រូក ជា លក្ខណៈ ពាណិជ្ជកម្មបានក្លាយ ជា អ្នកផ្គត់ផ្គង់ជ្រូក(សាច់ជ្រូក)សំខាន់ជាងគេបន្តិចម្តងៗ។ ការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មបានកើនឡើងដល់ទៅ ៥៥%នៅឆ្នាំ២០២០ (កើន ឡើងពីចំនួន ៥៩៩ ៣៤១ក្បាល នៅឆ្នាំ២០១៦ ទៅ ១ ៣៧៩ ៦២៣ក្បាល នៅឆ្នាំ ២០២០)។ គិតត្រឹមឆ្នាំ២០២០តួលេខកសិដ្ឋានចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មសរុបមានចំនួន៥៥១កសិដ្ឋាន ដែល ក្នុង នោះ ភាគ ច្រើន ជា កសិដ្ឋាន ចិញ្ចឹមជ្រូកយកសាច់ (៤៨៩កសិដ្ឋាន) និង កសិដ្ឋានចិញ្ចឹមជ្រូកពូជ (៦២កសិដ្ឋាន)[៣]។

[៣] *របាយការណ៍បូកសរុបលទ្ធផលការងារផលិតកម្មសត្វនិងផលិតកម្មសត្វ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (២០២១)*

## តារាងទី១៖ ស្ថិតិផលិតកម្មសត្វ (ក្បាល) ចន្លោះឆ្នាំ២០១៦ -២០២០

| | ប្រភេទ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ |
|---|---|---|---|---|---|---|
| គោ | គ្រួសារ | ២.៨៩៧.១២៦ | ២.៩៥១.៣៥៩ | ២.៩១៧.៣០២ | ២.៧៦៩.៨៨៥ | ២.៨៣៥.៣៦០ |
| | ពាណិជ្ជកម្ម | ២៣.១៨៨ | ២០.៣៦៣ | ១១.២៣២ | ៩.៨៧៧ | ១៣.២១៦ |
| ក្របី | គ្រួសារ | ៥២៣.៣២០ | ៥០៨.៤៥៨ | ៥០០.៧៧៨ | ៤៤៧.១៦៧ | ៤២៣.៦១៤ |
| | ពាណិជ្ជកម្ម | ១៩៤ | ១៩៨ | ២១៧ | ២១៨ | ២១១ |
| ជ្រូក | គ្រួសារ | ២.៣៧១.២៨៣ | ២.៣៣១.៥១២ | ១.៩៣៤.៩១៧ | ១.០៣០.៤៩៤ | ១.១៣៧.០៥៦ |
| | ពាណិជ្ជកម្ម | ៥៩៩.៣៤១ | ៧៤២.៧៧១ | ៨១២.៩៣៤ | ១.១៥៥.៤៣១ | ១.៣៧៩.៦២៣ |
| បសុបក្សី | គ្រួសារ | ២៨.៤០២.៤៨៦ | ២៨.៦៥២.៤០៩ | ២៨.៩៥៦.៣៤២ | ២៧.៧៦៣.៤៧៩ | ៣០.៥៥៣.២៣៣ |
| | ពាណិជ្ជកម្ម | ៧.៣៣១.២៧៥ | ៧.៥៩២.៥៣០ | ៩.២១០.៤០៩ | ១២.៦៣១.៩៧៤ | ១៧.៥០៨.៩៣៦ |
| សេះ | គ្រួសារ | ៥.៦១០ | ៥.០៥៥ | ៤.២០៧ | ៣.៧៧១ | ២.៩៧១ |
| | ពាណិជ្ជកម្ម | ៦៤ | ៨២ | ៨៩ | ៣០ | - |
| ចៀម | គ្រួសារ | ៤០០ | ៤៦១ | ៤៥៩ | ៦៤៨ | ៩៤៤ |
| | ពាណិជ្ជកម្ម | ៦៧ | - | - | - | ៧៨១ |
| ពពែ | គ្រួសារ | ២២.៧១៩ | ២៨.៥៤២ | ២៥.៧៤៧ | ២៧.៧៤០ | ២៩.៩៨១ |
| | ពាណិជ្ជកម្ម | ៦.២៥៨ | ៣៦៥ | ៧០០ | - | ៣០០ |

សម្គាល់៖ “-” គ្មានទិន្នន័យ
ប្រភព៖ GDAHP, 2021

ទន្ទឹមនឹងកំណើននៃអនុវិស័យចិញ្ចឹមសត្វនេះអាជីវកម្មបសុសត្វក៏នៅជួបប្រទះនូវឧបសគ្គមួយចំនួនរួមមាន៖ តម្លៃផលិតកម្មខ្ពស់ (ជាពិសេសអគ្គិសនី) ដែលនាំឱ្យមានការពិបាកក្នុង ការប្រកួតប្រជែង បើធៀបទៅនឹងសត្វរស់នាំចូល(ជាពិសេសជ្រូក)។ ចំពោះការចំណាយលើប្រតិបត្តិការកសិដ្ឋានចិញ្ចឹមជ្រូកដែលមានប្រព័ន្ធត្រជាក់ស្ងួត (ឬហៅថា កសិដ្ឋាន ប្រើប្រាស់ ប្រព័ន្ធ EVAP) ត្រូវ ចំណាយ លើ ថាមពល ច្រើនជាងកសិដ្ឋានដែលមិនមានប្រព័ន្ធEVAP។ កសិដ្ឋានដែលមិនតភ្ជាប់នឹងបណ្តាញអគ្គិសនីភាគច្រើនពឹងផ្អែកទៅលើម៉ាស៊ីនភ្លើងដែលប្រើប្រេងម៉ាស៊ូតដូច្នេះហើយ ទើប ជីវឧស្ម័នត្រូវបានចាត់ទុកជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការកាត់បន្ថយចំណាយលើប្រេងឥន្ធនៈ[៤]។

---

[៤] *ផ្អែកតាមរបាយការណ៍អង្កេតទីផ្សាររបស់កម្មវិធីឡជីវឧស្ម័នជាតិ (NBP) (២០១៩)*

តម្រូវការសាច់ក្នុងស្រុកត្រូវបានព្យាករណ៍ថា នឹងមានការកើនឡើងពី ២៩០ពាន់តោន នៅឆ្នាំ២០១៩ ដល់ ៣២៨ពាន់តោន នៅឆ្នាំ២០២៤។ ក្នុងឆ្នាំ២០២០ ផលិតផលសាច់ដែលផលិតក្នុងស្រុកបានផ្គត់ផ្គង់ចំនួន៨៥% នៃតម្រូវការសរុប[៥]។ការកើនឡើងដ៏ឆាប់រហ័សនេះនឹងជំរុញកំណើនឧស្សាហកម្មបសុសត្វដូចបានព្យាករក្នុងផែនការមេវិស័យកសិកម្មឆ្នាំ២០៣០។ លើសពីនេះ រាជរដ្ឋាភិបាលបានបញ្ចេញកញ្ចប់វិធានការអន្តរាគមន៍បន្ទាន់ និងរយៈពេលវែងដើម្បីគាំទ្រសេដ្ឋកិច្ច ដែលរួមមានកម្មវិធីកម្ចីពិសេសតាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដើម្បីជួយវិស័យកសិកម្មក្នុងការឆ្លើយតបនឹងជំងឺកូវីដ-១៩។ ជាមួយគ្នានេះដែរ វិស័យទេសចរណ៍ក៏ត្រូវបានរំពឹងថានឹងចាប់មានកំណើនខ្លាំងឡើងវិញនៅពេលខាងមុខនេះ ដែលនឹងធ្វើឱ្យតម្រូវការម្ហូបអាហារ និងសាច់កើនឡើងទៀតផងដែរ។ បន្ថែមពីនេះទៀត កម្ពុជាបានសម្រេចចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេរភាគីជាមួយប្រទេសចិន និងជាមួយប្រទេសកូរ៉េខាងត្បូង ក្នុងពេលឆាប់ៗនេះ ហើយផលិតកម្មសត្វកម្ពុជាក៏ត្រូវបានរំពឹងថានឹងទៅបម្រើទីផ្សារ ទាំងនោះផងដែរ។

ស្ថិតក្នុងបរិបទនេះ កម្ពុជានឹងនៅតែបន្តអភិវឌ្ឍន៍និងពង្រឹងក្របខ័ណ្ឌច្បាប់ដែលជំរុញការប្រកួតប្រជែងការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) ជាពិសេសបទដ្ឋានបច្ចេកទេសអនាម័យសម្រាប់ផលិតផលសត្វ និងនៅតាមសត្តឃាតដ្ឋាន ក៏ដូចជាការគ្រប់គ្រងលាមកសត្វ និងសំណល់រាវដើម្បីបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ (ជាពិសេសជំងឺស្វ៊ូណូស) សំដៅឆ្លើយ តបនឹងតម្រូវការទីផ្សារទាំងបរិមាណ និងគុណភាព ទាំងក្នុងស្រុកនិងនាំចេញ ព្រមទាំងកាត់បន្ថយថ្លៃផលិតកម្មផងដែរ។

## ១.២ ស្ថានភាពនៃឧស្សាហកម្មកែច្នៃកសិផល

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដំណាំកសិឧស្សាហកម្មបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងកម្រិតជាមធ្យម ១៣%ក្នុងមួយឆ្នាំ ពោលគឺកើនពី ៦,១៤លានតោន ក្នុងឆ្នាំ២០១០ ដល់ ១៥,១៣លានតោន នៅឆ្នាំ២០១៩។ រីឯផលិតកម្មកៅស៊ូបានកើនឡើងដល់ ២៨៧ ៦៣០តោន ពោលគឺក្នុងអត្រាប្រចាំឆ្នាំ២០% អំឡុងឆ្នាំ២០១០-២០១៩។ ក្នុងរយៈពេលដូចគ្នានេះ ការនាំចេញកៅស៊ូបានកើនឡើង៧ដងគឺពី៤២ពាន់តោនក្នុងឆ្នាំ២០១០ ទៅដល់២៨២ពាន់តោនក្នុងឆ្នាំ២០១៩។ ដំណាំកសិឧស្សាហកម្មផ្សេងទៀតក៏មាននិន្នាការដូចគ្នាផងដែរ លើកលែងតែនៅឆ្នាំ២០១៨ ផលិតកម្ម ដំឡូងមីបានធ្លាក់ចុះដល់ ១៣,៥លានតោន ដោយសារជំងឺម៉ូសាអ៊ិច[៦] គ្រាប់ស្វាយចន្ទី ០,២លានតោន និងពោតក្រហម ០,៩លានតោន។

ដំឡូងមីបានក្លាយជាដំណាំធំជាងគេទី២ នៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីដំណាំស្រូវ ដោយសារការពង្រីកផ្ទៃដីដាំដំឡូងមីធ្វើឡើងយ៉ាងលឿនក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ បច្ចុប្បន្ន អនុវិស័យដំណាំដំឡូងមីបានចូលរួមដល់ផលិតផលក្នុងស្រុកសរុបរបស់ជាតិប្រមាណ ៣% ទៅ ៤%[៧]។ ដំឡូងមីភាគច្រើនត្រូវបាននាំចេញក្នុងទម្រង់ជាមើមដំឡូងមីស្រស់ និងចំណិតដំឡូងមីក្រៀម។ ក្រៅពីនេះដំឡូងមីមួយចំនួនត្រូវបានកែច្នៃជាម្សៅមី (ដោយរោងចក្រចំនួន១៥) ឬយកទៅផលិតអេតាណុល (ដោយរោងចក្រអេតាណុលចំនួន៧) ដើម្បីនាំចេញ និងការបង្កើតតម្លៃបន្ថែម។

---

*[៥] ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (បោះពុម្ពឆ្នាំ២០២១)*

*[៦] ជំងឺនេះបង្កដោយវីរុសម៉ូសាអ៊ិចដែលបណ្តាលឱ្យស្លឹកដំណាំក្លាយជាអុចៗនិងអាចបំផ្លាញដំណាំបាន។*

*[៧] គោលនយោបាយជាតិស្តីពីដំឡូងមី ២០២០-២០២៥*

ដើម្បីគាំទ្របន្ថែមទៀតដល់ដំណាំដំឡូងមី រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយជាតិ ស្តីពីដំឡូងមី នៅឆ្នាំ២០២០ ដើម្បីធ្វើឱ្យកម្ពុជាក្លាយជាទីតាំងផលិត និងកែច្នៃដំឡូងមី និងប្រែក្លាយទៅជាអ្នកផ្គត់ផ្គង់ផលិតផលពីដំឡូងមីមួយ ដែលអាចជឿទុកចិត្តបានសម្រាប់ទីផ្សារអន្តរជាតិ។ ដោយសារសំណល់រាវកើតចេញពីផលិតកម្មដំឡូងមីអាចផលិតជីវឧស្ម័ន និងផលិតជាអគ្គិសនីបាន ទើបគោលនយោបាយជាតិ ស្តីពីដំឡូងមីនេះ បានចែងថា *"ក្រសួងរ៉ែ និងថាមពលនឹង លើកទឹកចិត្តឱ្យរោងចក្រកែច្នៃដំឡូងមីវិនិយោគលើប្រព័ន្ធជីវឧស្ម័នដោយគាំទ្រនីតិវិធីច្បាប់ លិខិតអនុញ្ញាតិ និងបំពេញតាមតម្រូវការក៏ដូចជាការទិញអគ្គិសនីដែលនៅសល់មកវិញក្នុងតម្លៃសមហេតុផល [ដោយអគ្គិសនីកម្ពុជា] ឬអនុញ្ញាតឱ្យ លក់អគ្គិសនីទៅគ្រួសារនៅក្បែរៗដោយផ្ទាល់ ក្នុងតម្លៃដូចគ្នានឹងសេវាករអគ្គិសនីឯកជនក្នុងស្រុកនិង/ឬរដ្ឋ។*

## ១.៣ វិស័យកសិកម្ម និងការប្រែប្រួលអាកាសធាតុ

វិស័យកសិកម្មនៅកម្ពុជា គឺជាប្រភពបញ្ចេញឧស្ម័នផ្ទះកញ្ចក់ធំទី២ បន្ទាប់ពីវិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត (FOLU) ដែលមានប្រមាណ ១៨ ៣៩៨៣ាន់តោន សមមូលឧស្ម័នកាបូនិក[៨] នៅឆ្នាំ២០១៦ ប្រហែល ១១,២% នៃការបញ្ចេញឧស្ម័នសរុប ឬ៥៦,៤% នៃការបញ្ចេញឧស្ម័នសរុប បើគេមិនរាប់បញ្ចូលវិស័យFOLU[៩]។ ក្រៅពីនេះ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យកសិកម្ម មានទំហំធំជាងការរួមបញ្ចូលគ្នានៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យថាមពល ដំណើរការឧស្សាហកម្មនិងការប្រើប្រាស់ផលិតផល (IPPU) និងសំណល់។ របាយការណ៍ស្តីពីការចូលរួម ចំណែក របស់ កម្ពុជា ក្នុងការឆ្លើយតបទៅនឹង ការប្រែប្រួល អាកាសធាតុ បានព្យាករណ៍ថា ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់កម្ពុជានឹងបន្តកើនឡើងពី ២១ ២០០ពាន់តោនសមមូលឧស្ម័នកាបូនិក ក្នុងឆ្នាំ២០១៦ ដល់ ២៧ ១០០ពាន់តោនសមមូលឧស្ម័នកាបូនិកនៅឆ្នាំ២០៣០ សម្រាប់ព្យាករណ៍តាមទម្លាប់ធម្មតា ប៉ុន្តែនៅពេលការអនុវត្តសកម្មភាព កាត់ បន្ថយ ឧស្ម័ន ផ្ទះកញ្ចក់ ទាំង១៧ ដែល រួមមាន ទាំងសកម្មភាពដំឡើងនិងប្រើប្រាស់ឡជីវឧស្ម័នផងនោះ[១០] ការបញ្ចេញឧស្ម័ន នៅឆ្នាំ២០៣០ អាចនឹងត្រូវកាត់បន្ថយចំនួន៦,២% ដែលស្មើនឹង ២០ ២០០ពាន់តោនសមមូលឧស្ម័នកាបូនិក។

ការប្រែប្រួលអាកាសធាតុនឹងបណ្តាលឱ្យរបាយទឹកភ្លៀងម៉ូសុងប្រែប្រួលនិងកាន់តែពិបាកព្យាករណ៍ ហើយជាមួយគ្នានោះ សីតុណ្ហភាពនៅប្រទេសកម្ពុជានឹងអាចកើនឡើងចន្លោះពី ០,៦០-២,៥អង្សាសេលស៊ីស មុនដំណាច់ឆ្នាំ ២១០០[១១]។ ប្រការនេះនឹងជះឥទ្ធិពលអវិជ្ជមានមួយចំនួនលើវិស័យកសិកម្មផងដែរ។ យោងតាមក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការ ប្រែប្រួលអាកាសធាតុ (IPCC) ការផលិតទឹកដោះគោពីសត្វគោដែលមានសមត្ថភាពផលិតទឹកដោះខ្ពស់ នឹងត្រូវថយចុះចំណែកការផលិតសាច់ពីសត្វទំពារអៀងក៏នឹងត្រូវថយចុះផងដែរដោយសារការថយចុះនៃទំហំរាងកាយសត្វ ទម្ងន់គ្រោងឆ្អឹង និងកម្រាស់ខ្លាញ់របស់សត្វទាំងនេះ។

---

[៨] *1 Gg = $10^9$ gram= 1 kt (1 kiloton)។ CO2e ជាសមមូលឧស្ម័នកាបូនិច ដែលជារង្វាស់សម្រាប់ប្រៀបធៀបការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីប្រភពផ្សេងៗ ដោយផ្អែកលើសក្តានុពលកំណើនកំដៅផែនដី (GWP)។*

[៩] *របាយការណ៍ពីរឆ្នាំម្តងលើកទី១របស់កម្ពុជា (1st BUR) ឆ្នាំ២០១៩*

[១០] *ឡជីវឧស្ម័នសម្រាប់ឧស្សាហកម្មជ័រឈើ និងកៅស៊ូ ឡជីវឧស្ម័នសម្រាប់កសិដ្ឋានខ្នាតតូច មធ្យម និងធំ ដើម្បីប្រព្រឹត្តកម្មរូបធាតុសរីរាង្គនៃសំណល់រឹងទីក្រុង*

[១១] *របាយការណ៍ជាតិលើកទីពីររបស់កម្ពុជា ក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (២០១៥)*

ជម្ងឺថ្មីៗក៏អាចប៉ះពាល់ដល់ប្រព័ន្ធភាពស៊ាំរបស់សត្វ ហើយ ការ ទទួលរង សីតុណ្ហភាពខ្ពស់ក្នុងរយៈពេលយូរ អាច ប៉ះពាល់ដល់សុខភាពសត្វផងដែរ (ឧ. ដំណើរមេតាបូលីសប្រូតេអ៊ីននិងខ្លាញ់ និងមុខងារថ្លើម[១២])។ ការកើនឡើង សីតុណ្ហភាព ក៏ នឹង កាត់ បន្ថយ សមត្ថភាព ស្រូប យក សារធាតុ ចិញ្ចឹម របស់ រុក្ខជាតិ ដែល នាំ ឱ្យមានការខ្វះសារធាតុចិញ្ចឹមសម្រាប់ដំណាំដែលជាចំណីសត្វទៀតផង។

កំណើនសីតុណ្ហភាពនឹងធ្វើឱ្យប្រែប្រួលនៃការប្តូរកំដៅរវាងសត្វ និងបរិស្ថានជាពិសេសធ្វើឱ្យមានស្ត្រេសកំដៅ ដែលនឹងជះឥទ្ធិពលដល់ការស៊ីចំណី ការលូតលាស់ ការបន្តពូជ ការចិញ្ចឹមរាងកាយ និងអាយុរបស់សត្វ។ ការប្រែប្រួលអាកាសធាតុអាចផ្លាស់ប្តូរការរីករាលដាលនៃជម្ងឺ និងការចម្លងជម្ងឺសត្វតាមរយៈមធ្យោបាយជាច្រើន។ ការកើនឡើងសីតុណ្ហភាព ភាពរាំងស្ងួត និងទឹកជំនន់ នឹងជះឥទ្ធិពលដល់ភ្នាក់ងារបង្កជម្ងឺវីរុស ភាពស៊ាំរបស់សត្វ និងការចម្លងជម្ងឺ។

## ១.៤ ស្ថានភាពនៃការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា

ចាប់ តាំង ពី ការ ប្រកាស ឱ្យប្រើ គោលនយោបាយ អភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាលើកដំបូងអនុវិស័យចិញ្ចឹមសត្វ បាន ចូល រួម ក្នុង ការ គ្រប់ គ្រង លាមក សត្វ និង សំណល់ រាវ គួរ ឱ្យ កត់ សម្គាល់ ដោយមានទាំងការប្រើប្រាស់ឡជីវឧស្ម័នខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំមួយចំនួននៅតាមលំនៅដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វ សត្តឃាតដ្ឋាន និងកសិធុរកិច្ចផ្សេងទៀត ហើយក្រុមហ៊ុនឯកជនថ្មីៗមួយចំនួនក៏មានវត្តមានក្នុងទីផ្សារនេះដែរ។ តារាងទី២ បង្ហាញពីចំណាត់ថ្នាក់នៃកសិដ្ឋាន និងទំហំឡជីវឧស្ម័នត្រូវបានកំណត់ក្នុងគោលនយោបាយនេះ។ តារាងទី៣ បង្ហាញស្ថានភាពនៃការប្រើប្រាស់ឡជីវឧស្ម័នគ្រួសារ អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ។

**តារាងទី២៖ និយមន័យនៃចំណាត់ថ្នាក់កសិដ្ឋាន[១៣] និងទំហំឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន**

| ចំណាត់ថ្នាក់ឡជីវឧស្ម័ន | ប្រភេទសត្វ (ចំនួនសត្វតាមទំហំកសិដ្ឋាន) | បរិមាណលាមកសត្វ (គ.ក្រ/ថ្ងៃ) | *មាឌឡ/ អាងប្រព្រឹត្តិកម្ម (ម៉ែត្រគូប)* |
|---|---|---|---|
| ***ឡជីវឧស្ម័ន*** | | | |
| គ្រួសារ | គោ-ក្របី: <១០០ក្បាល<br>ជ្រូក: <១០០ក្បាល<br>បសុបក្សី: <២ ០០០ក្បាល | <៥០០ | *<៥០ ម៣* |
| ***អាងប្រព្រឹត្តិកម្មជីវឧស្ម័ន*** | | | |
| ខ្នាតតូច | គោ-ក្របី: ១០០-៣០០ក្បាល<br>ជ្រូក: ១០០-១.០០០ក្បាល<br>បសុបក្សី: ២.០០០-២០.០០០ក្បាល | ៥០០ ទៅ ៣.០០០ | ៥០ ទៅ ៣០០ ម៣ |
| ខ្នាតមធ្យម | គោ-ក្របី: >៣០០-១.០០០ក្បាល<br>ជ្រូក: >១.០០០-៥.០០០ក្បាល<br>បសុបក្សី: >២០.០០០-៥០.០០០ក្បាល | >៣.០០០ ទៅ ១០.០០០ | >៣០០ ទៅ ១.០០០ ម៣ |

---

[១២] *https://www.ipcc.ch/site/assets/uploads/sites/4/2021/02/08_Chapter-5_3.pdf*

[១៣] *យោងតាមប្រកាសលេខ៥៤៩ ចុះថ្ងៃទី១២ ធ្នូ ឆ្នាំ២០១៨*

| | | | |
|---|---|---|---|
| ខ្នាតធំ | គោ-ក្របី: >១.០០០ក្បាល<br>ជ្រូក: >៥.០០០ក្បាល<br>បសុបក្សី: >៥០.០០០ក្បាល | >១០.០០០ | > ១.០០០ ម៣ |

ស្របតាមគោលបំណងនៃគោលនយោបាយនេះ វិធានការមួយចំនួនត្រូវបានកំណត់ឡើងសម្រាប់កសិដ្ឋានមិនមែនជាលក្ខណៈពាណិជ្ជកម្ម ឡជីវឧស្ម័នលក្ខណៈគ្រួសារ និងកសិដ្ឋានជាលក្ខណៈពាណិជ្ជកម្ម ឬកសិធុរកិច្ចដែលមានឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម ឬខ្នាតធំ។ តារាងខាងក្រោមបង្ហាញពីចំនួនសរុបនៃឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នដែលបានដំឡើងរួច។

**តារាងទី៣៖ តួលេខនៃឡជីវឧស្ម័នសរុបដែលបានដំឡើងរួចដោយស្ថាប័នមួយចំនួនគិតត្រឹមឆ្នាំ២០២០**

| ស្ថាប័ន | ឡគ្រួសារ | ឡខ្នាតតូច មធ្យម និងធំ |
|---|---|---|
| កម្មវិធីឡជីវឧស្ម័នជាតិ (NBP) | ២៨.៦៨៣[១៤] | កសិដ្ឋានចិញ្ចឹមជ្រូក៦កន្លែង (៨៥-១៨០ kVA[១៥]) |
| ក្រុមហ៊ុន ATEC | ១.៨០០[១៦] | - |
| អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | ៣៤០[១៧] | - |
| ក្រុមហ៊ុន VW Gas | - | កសិដ្ឋានចិញ្ចឹមជ្រូក១០កន្លែង (១០០ ទៅ ៣០០ kVA)<br>រោងចក្រដំឡូងមី១កន្លែង(១,៥MVA និងឡចំហាយដែលប្រើជីវឧស្ម័ន ៣០០ ម៣/ម៉ោង)<br>រោងចក្រម្សៅអង្ករ១ប្រព័ន្ធ (ឡចំហាយប្រើជីវឧស្ម័ន១២០ម៣/ម៉ោង) |
| កសិដ្ឋានដែលមានកិច្ចសន្យាជាមួយក្រុមហ៊ុនចិញ្ចឹមសត្វ | - | - ក្រុមហ៊ុន CP៖កសិដ្ឋាន៧៣កន្លែង[១៨] (ប្រហែល២២កន្លែងមានប្រព័ន្ធជីវឧស្ម័ន)<br><br>- ក្រុមហ៊ុន Betagro៖ ប្រព័ន្ធជីវឧស្ម័ន៥កន្លែង [១៩] |
| គម្រោងផ្សេងទៀត[២០] | - | កសិដ្ឋានចិញ្ចឹមជ្រូក៣កន្លែង ដែលមានសមត្ថភាពសរុប ២.១០០ kVA។<br>រោងចក្រកែច្នៃកសិផល៣កន្លែង (ម្សៅមីនិងអេតាណុល)៖<br>១.ថាមពលកំដៅ ២៣ $MW_{thermal}$<br>២.ឡចំហាយប្រើជីវឧស្ម័ន ១.៣៧៥ម៣/ម៉ោងសម្រាប់ សម្ងួតម្សៅមី<br>៣.ម៉ាស៊ីនភ្លើងប្រើជីវឧស្ម័នមានសមត្ថភាព ១,៤ MVA |

---

*[១៤] ទិន្នន័យឡជីវឧស្ម័នដែលបានដំឡើងសរុបដោយកម្មវិធីឡជីវឧស្ម័នជាតិ (NBP)គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ២០២០*

*[១៥] kVA = 1 kilo Volt Ampere។ MVA = 1000 kVA*

*[១៦] សំភាសន៍ក្រុមហ៊ុន ATEC - តួលេខដំឡើងជាក់ស្តែងចន្លោះឆ្នាំ2016-2020*

*[១៧] តួលេខឡជីវឧស្ម័នសរុប ដែលបរិច្ចាគដោយរដ្ឋាភិបាលចិន*

*[១៨] ប្រភព៖ ការអង្កេតទីផ្សាររបស់កម្មវិធីឡជីវឧស្ម័នជាតិ (NBP)ឆ្នាំ២០១៩*

*[១៩] ការប៉ាន់ស្មានរបស់ក្រុមហ៊ុន ប៉ុន្តែពុំមានតួលេខស្តីពីទំហំនិងសមត្ថភាពប្រព័ន្ធទាំងនេះទេ*

*[២០] ប្រភព៖ បញ្ជីគម្រោងការបោនក្រោមយន្តការអភិវឌ្ឍន៍ស្អាត រួមទាំងប្រព័ន្ធជីវឧស្ម័ននៅកសិដ្ឋាន ឧ.ឧកញ៉ា ម៉ុង ឬទ្ធី*

ជីវឧស្ម័នដែលផលិតនៅក្នុងឡជីវឧស្ម័នគ្រួសារភាគច្រើនត្រូវបានប្រើប្រាស់សម្រាប់ចម្អិនអាហារ ដូច្នេះវាជំនួសអុសធ្យូងឬឧស្ម័នធម្មជាតិ ចំណែកឡជីវឧស្ម័នខ្នាតតូច មធ្យម និង ធំ (SMLSB) ត្រូវបានប្រើប្រាស់ដើម្បីផលិតថាមពលអគ្គិសនី ឬកម្តៅសម្រាប់សកម្មភាពផលិតកម្មនិងកែច្នៃផ្សេងៗ។

ការចម្អិនអាហារដោយប្រើប្រាស់ជីវឧស្ម័នមានគុណប្រយោជន៍ជាច្រើន រួមមានទាំងភាពងាយស្រួល ចំណេញពេលវេលាចម្អិនអាហារ មិនធ្វើឲ្យខ្មៅឆ្នាំង សន្សំពេលវេលា និងគ្មានផ្សែង។ ការសិក្សាជាច្រើនដែលបានធ្វើឡើងថ្មីៗនេះនៅប្រទេសកម្ពុជាបានបង្ហាញថាជីវឧស្ម័នគឺជាឥន្ធនៈស្អាតសម្រាប់ចម្អិនអាហារ ដែលជួយកាត់បន្ថយការស្រូបយកភាគល្អិត ឬធូលីដែលមានទំហំតូចជា២,៥មីក្រូម៉ែត្រ(PM2,5)ប្រមាណ៣៦% និងកាត់បន្ថយកំហាប់ PM2,5 ដែលមាននៅក្នុងផ្ទះបាយបាន៨៨% បើធៀបនឹងការចម្អិនអាហារដោយប្រើអុស[២១]។ អំឡុងឆ្នាំ២០០៦-២០១៤ ឡដែលសាងសង់ដោយកម្មវិធីឡជីវឧស្ម័នជាតិបានជួយបញ្ចៀសការស្លាប់មុនអាយុចំនួន២៩នាក់ និងពិការភាពចំនួន ១ ៤៤២នាក់ (គណនាដោយផ្អែកលើចំនួនឆ្នាំនិងជីវិតដែលបញ្ចូលកត្តាពិការភាពផងដែរ - DALYs)។

កសិដ្ឋានខ្នាតតូច មធ្យម និងធំភាគច្រើនបានដំឡើងម៉ាស៊ីនម៉ាស៊ូតជជុះ ហើយខ្លះទៀតប្រើម៉ាស៊ីនភ្លើងជជុះដែល ប្រើ ជីវឧស្ម័ន ដើម្បី ផលិត អគ្គិសនី។ ក្នុងករណី ខ្លះ ម៉ាស៊ីន ភ្លើង ដែល ដើរ ដោយ ឥន្ធនៈពីររួមគ្នា(ជីវឧស្ម័ន និងម៉ាស៊ូត ឬជារបៀបកូនកាត់)ក៏មានការប្រើប្រាស់ផងដែរ។ ម៉ាស៊ីនភ្លើងថ្មីប្រើជីវឧស្ម័នសុទ្ធសាធ គឺមានតម្លៃថ្លៃពេកដែលមួយផ្នែកបណ្តាលមកពីពន្ធនាំចូលខ្ពស់។

ឧស្ម័នអ៊ីដ្រូសែនស៊ុលហ្វីត($H_2S$) ដែលមានក្នុងជីវឧស្ម័នអាចធ្វើឱ្យច្រេះស៊ីផ្នែកសំខាន់ៗ របស់ម៉ាស៊ីនភ្លើង។ ការ ដក ចេញ ឧស្ម័ន នេះ ពី ជីវឧស្ម័ន មាន សារៈសំខាន់ ណាស់ ដើម្បី ធានា បាន នូវ ដំណើរ ការ យូរ អង្វែងរបស់ម៉ាស៊ីនភ្លើង។ ក៏ប៉ុន្តែ ដោយសារតែកង្វះសមត្ថភាពបច្ចេកវិទ្យា និងឧបករណ៍តាមដានប្រសិទ្ធភាព បរិក្ខារដែលដកយកឧស្ម័ននេះមិនត្រូវបានគេប្រើប្រាស់ឱ្យបានត្រឹមត្រូវឬដំណើរការបានល្អទេ ដែលធ្វើឱ្យកាត់បន្ថយប្រសិទ្ធភាពនៃការដកយកឧស្ម័នអ៊ីដ្រូសែនស៊ុលហ្វីត ($H_2S$) ក្រោមកម្រិតបទដ្ឋានបច្ចេកទេស (តិចជាង២០០ppm) នៃម៉ាស៊ីនភ្លើងដែលនៅទីបំផុតធ្វើឱ្យម៉ាស៊ីនភ្លើងឆាប់ខូច។ ជីវឧស្ម័ន ក៏ ត្រូវ បាន ប្រើ ជា ឥន្ធនៈ ក្នុង ឡចំហាយ នៅ តាម រោងចក្រស្រាបៀរមួយចំនួន រោងចក្រដំឡូងមី និងរោងចក្រអេតាណុលផងដែរ។

**អ្នកពាក់ព័ន្ធនឹងជីវឧស្ម័នសំខាន់ៗ៖**

**១. កម្មវិធីឡជីវឧស្ម័នជាតិ**

កម្មវិធីឡជីវឧស្ម័នជាតិ(NBP) គឺជាកម្មវិធីមួយដែលត្រូវបានបង្កើតឡើងដោយអង្គការអភិវឌ្ឍន៍ហូល្លង់ (SNV) ក្នុងឆ្នាំ២០០៦ ដែលគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) និងសម្របសម្រួលដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (GDAHP)។ គិតត្រឹមឆ្នាំ២០២០ កម្មវិធីឡជីវឧស្ម័នជាតិ (NBP)[២២] បានដំឡើងឡជីវឧស្ម័នបានចំនួន២៨,៦៨៣។ យោងតាមរបាយការណ៍ត្រួតពិនិត្យការបោនចុងក្រោយបង្អស់

---

[២១] *Buysman, E (2016) http://www.ccacoalition.org/en/news/report-biogas-and-household-air-quality-rural-cambodia*

[២២] *តួលេខសរុបដកស្រង់ពីរបាយការណ៍ត្រួតពិនិត្យការបោនរបស់កម្មវិធីឡជីវឧស្ម័នជាតិ (NBP)*

ឆ្នាំ២០១៩ បានបង្ហាញថា ៦៤%នៃឡទាំងនេះ បាននិងកំពុងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនចំនួន ៧៨ ៨៥៣នាក់ ចំណែកសំណល់ឡជីវឧស្ម័នត្រូវបានប្រជាជនប្រើប្រាស់លើផ្ទៃដីកសិកម្មសរុបចំនួន១៧ ០៥៥ហិកតា[២៣]។

មូលហេតុចម្បងមួយនៃការមិនបន្តប្រើប្រាស់ឡជីវឧស្ម័នមួយចំនួនដោយសារតែការផ្លាស់ប្តូររបៀបរស់នៅ។ ប្រជាជនឈប់ចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ហើយងាកទៅប្រកបរបរផ្សេងទៀត ឬអាចមកពីគាត់មានវ័យចាស់ពេក មិនអាចមើលថៃទាំឡទាំងនេះ ឬគ្រួសាររបស់ពួកគេបានប្តូរទៅប្រើឧស្ម័នធម្មជាតិ (LPG) សម្រាប់ចម្អិនអាហារ ចំណែកក្មេងជំនាន់ក្រោយបានផ្លាស់ទៅធ្វើការនៅទីក្រុង។ ទោះជាយ៉ាងនេះក៏ដោយឡជីវឧស្ម័នដែលបានដំឡើង ៦ឆ្នាំដំបូងមានអត្រាប្រើប្រាស់ខ្ពស់ដល់ទៅជិត៩០%។ ក្រៅពីនេះ ប្រហែល៣០១២គ្រួសារបានភ្ជាប់បង្គន់របស់ពួកគេទៅនឹងឡជីវឧស្ម័ន។

កម្មវិធីឡជីវឧស្ម័នជាតិ គាំទ្របច្ចេកវិទ្យាឡជីវឧស្ម័នចំនួន៣ប្រភេទគឺ ប្រភេទឡគជ្ជពីរប្រភេទ (ឡមិត្តកសិករ និងឡNBPS1) និងប្រភេទឡធ្វើពីស្អាច់ដែលបានរៀបចំទុកមុន(ឡជីវឧស្ម័នប្រភេទនេះធ្វើនៅប្រទេសវៀតណាម និង ចិន)។ ភ្នាក់ងារសាងសង់ឡជីវឧស្ម័ន (BCAs) ជាអ្នកទទួលបន្ទុកសាងសង់ឬដំឡើងឡទាំងនេះ និងប្រតិបត្តិការក្រោម កិច្ចសន្យាសាងសង់ជាមួយកម្មវិធីឡជីវឧស្ម័នជាតិ (NBP)។ សព្វថ្ងៃនេះ ភ្នាក់ងារសាងសង់ឡជីវឧស្ម័ននេះមានចំនួន ៧៧នាក់ ដែលកំពុងដំណើរការក្នុងរូបភាពពាក់កណ្តាលពាណិជ្ជកម្ម និងបានបង្កើតការងារប្រមាណជាង៨៥៤នាក់ ដែលបានទទួលការបញ្ជាក់សមត្ថភាពសម្រាប់សាងសង់ឡជីវឧស្ម័ន។ ដូច្នេះអត្ថប្រយោជន៍សំខាន់មួយទៀតនៃឡជីវឧស្ម័ន គឺការបង្កើតការងារនៅជនបទ។ ដោយសង្កេតឃើញបម្រែបម្រួលសេដ្ឋកិច្ចជនបទ កម្មវិធីឡជីវឧស្ម័នជាតិ បានសហការជាមួយក្រុមហ៊ុនCP ហើយបានដំឡើងឡខ្នាតមធ្យម និងខ្នាតធំមួយចំនួនផងដែរ នៅតាមកសិដ្ឋាន ចិញ្ចឹមជ្រូក ក្រោមជំនួយពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)។

**២. ក្រុមហ៊ុន ATEC**

ក្រុមហ៊ុន ATEC ដំឡើងឡជីវឧស្ម័នដែលផលិតនៅក្នុងប្រទេសកម្ពុជា សម្រាប់គ្រួសារកសិករ និងផ្តល់ ដំណោះស្រាយហិរញ្ញប្បទានប្រកបដោយភាពច្នៃប្រឌិត ដែលធ្វើការទូទាត់ប្រាក់នៅពេលដែលប្រើប្រាស់ (PayGo)។ ការទូទាត់ប្រាក់PayGoនេះ អនុញ្ញាតឱ្យកសិករសងត្រឡប់ទៅក្រុមហ៊ុនវិញ ដោយបង់រំលស់/ទូទាត់ ប្រចាំខែតាមទូរស័ព្ទចល័ត។ ក្រុមហ៊ុននេះបានដំឡើងឡជីវឧស្ម័នចំនួន១៨០០ឡ នៅអំឡុងឆ្នាំ២០១៦-២០២០។

**៣. ក្រុមហ៊ុន VW Gas**

ក្រុមហ៊ុន VW Gas គឺជាក្រុមហ៊ុនក្នុងស្រុកមួយដែលបានចាប់ផ្តើមដំណើរការយ៉ាងសកម្មនៅឆ្នាំ២០១៨ ក្នុង វិស័យឡជីវឧស្ម័ន ដោយផ្តោតលើកសិដ្ឋានខ្នាតមធ្យម និងធំ និងឧស្សាហកម្មកែច្នៃកសិផល។ គិតមកដល់ពេលនេះ ក្រុមហ៊ុនបានដំឡើងឡជីវឧស្ម័នចំនួន១០ និងមានគោលដៅប្រកបដោយមហិច្ឆតាឈានទៅដំឡើងឡជីវឧស្ម័នឱ្យ បាន៣០% នៃកសិដ្ឋាន និងឧស្សាហកម្មកែច្នៃកសិផលទាំងអស់ឱ្យបានមុនឆ្នាំ២០៣០ ។

**៤. កសិដ្ឋានដែលមានកិច្ចសន្យាជាមួយក្រុមហ៊ុនចិញ្ចឹមសត្វ**

ក្រុមហ៊ុនចិញ្ចឹមសត្វមួយចំនួនបានលើកទឹកចិត្តកសិកររបស់ខ្លួនឱ្យសាងសង់ឡជីវឧស្ម័ន ដើម្បីបរិស្ថានកាន់ តែល្អ បង្កើនផលិតភាពសត្វ និងផ្តល់ការគាំទ្រដើមទុនផងដែរ។ ផ្អែកតាមការអង្កេត ប្រហែល៣០% នៃកសិដ្ឋាន ដែលមានកិច្ចសន្យាជាមួយក្រុមហ៊ុនCP មានស្រះ/អាងលាមកសត្វដែលគ្របដោយកៅស៊ូប្រភេទប៉ូលីអេទីឡែន

---

[២៣] *របាយការណ៍ត្រួតពិនិត្យកម្មវិធីឡជីវឧស្ម័នជាតិ (NBP) CPIII MPI*

(HDPE) នាំចូលពីប្រទេសថៃ សម្រាប់ចាប់យកជីវឧស្ម័ននិងកាត់បន្ថយការបំពុលក្លិន[២៤]។ គួរកត់សម្គាល់ផងដែរថា ជីវឧស្ម័នដែលផលិតពីឡមួយចំនួនមិនត្រូវបានប្រើប្រាស់ឬផលិតជាអគ្គិសនីនោះទេ ផ្ទុយទៅវិញ ជីវឧស្ម័នទាំងនេះបែរជាត្រូវគេដុតចោលឬបញ្ចេញចោលទៅក្នុងបរិយាកាសតែម្តង។ ក្រៅពីនេះ ព័ត៌មានស្តីពីការដំឡើងឡជីវឧស្ម័នដោយភាគីឬក្រុមហ៊ុនដទៃទៀតនៅមានកង្វះខាតនៅឡើយ។

## ១.៥ កាលានុវត្តភាព និងការប្រឈម

### *កាលានុវត្តភាព*

- មានការជំរុញ និងលើកទឹកចិត្តដល់ការអនុវត្តល្អក្នុងផលិតកម្មកសិកម្ម ដែលបង្កើតនូវបរិយាកាសអំណោយផលដល់ការដំឡើងនិងប្រើប្រាស់ឡជីវឧស្ម័នគ្រប់ប្រភេទ និងខ្នាត។
- ឧស្សាហកម្មកែច្នៃកសិផល និងការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មកំពុងរីកចម្រើន ដែលចាំបាច់ត្រូវការគ្រប់គ្រងកាកសំណល់ប្រកបដោយចីរភាព។
- រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ទៅលើវិស័យកសិកម្មក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់ផ្នែកសង្គមសេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺរលាកផ្លូវដង្ហើមកូវីដ-១៩។
- ទីផ្សារអាហារកែច្នៃពីកសិផលរបស់កម្ពុជាកំពុងតែត្រូវបានធ្វើសមាហរណកម្មជាមួយទីផ្សារពិភពលោក ដែលនឹងបង្កើតកាលានុវត្តភាពនាំចេញ និងវិនិយោគលើវិស័យកសិកម្ម ។
- ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងប្រកាសលេខ៥៤៩ ចែងថា កសិដ្ឋានលក្ខណៈពាណិជ្ជកម្មទាំងអស់ត្រូវមានកន្លែងស្តុកកាកសំណល់/លាមក ឬឡ/អាងជីវឧស្ម័ន។ ច្បាប់នេះក៏ចែងពីការបង្កើតមូលនិធិដែលអាចគាំទ្រដល់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ឡជីវឧស្ម័នផងដែរ។
- ការ ប្រើប្រាស់ ជីវឧស្ម័ន ត្រូវ បាន លើក ទឹក ចិត្ត នៅ ក្នុង ឯកសារ គោលនយោបាយ ជា ច្រើន ដូចជា ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ វិស័យកសិកម្ម ឆ្នាំ២០១៩-២០២៣ ផែនការមេ វិស័យ កសិកម្មឆ្នាំ២០៣០ គោលនយោបាយជាតិ ស្តីពីជំឡូងមី របាយការណ៍នៃការចូលរួមចំណែករបស់កម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (NDC) គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា (សម្រាប់កសិឧស្សាហកម្ម) ។
- ថាមពលអគ្គិសនី ពីឡជីវឧស្ម័នត្រូវបានម្ចាស់កសិដ្ឋានចាត់ទុកថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការកាត់បន្ថយចំណាយលើថ្លៃអគ្គិសនី និងកាត់បន្ថយថ្លៃប្រតិបត្តិការ។
- វត្តមានប្រាក់កម្ចីសម្រាប់កសិដ្ឋានខ្នាតតូច មធ្យម និងធំសម្រាប់ប្រើក្នុងការកែលម្អកសិដ្ឋាន ក៏ដូចជាការគ្រប់គ្រងលាមកសត្វ និងសំណល់រាវ។ ប្រាក់កម្ចីសម្រាប់កសិដ្ឋានខ្នាតតូច មធ្យម និងធំ អាចរកបានពីធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម (ARDB) និងធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) ចំណែកការសាងសង់ឡជីវឧស្ម័នលក្ខណៈគ្រួសារអាចរកបានពីធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម (ARDB) និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន។
- គំរូហិរញ្ញប្បទានដែលមានភាពច្នៃប្រឌិតមួយចំនួនកំពុងមានវត្តមានដូចជា ភតិសន្យាឈានទៅធ្វើជាម្ចាស់កម្មសិទ្ធិ ការទូទាត់ប្រាក់នៅពេលដែលប្រើប្រាស់ (PayGo) និងគំរូផ្តល់សេវាកម្មថាមពល (ESCO) ដែលផ្តល់ជាជម្រើសដ៏ទាក់ទាញក្រៅពីកម្ចីពីធនាគារ។

---

[២៤] *ប្រភព៖ កម្មវិធីឡជីវឧស្ម័នជាតិ(NBP) -ការអង្កេតទីផ្សារ និងវង្វាយតម្លៃឥណទាននៃឡជីវឧស្ម័នខ្នាតមធ្យមនិងធំនៅកម្ពុជា ឆ្នាំ២០១៩*

- ការប្រើប្រាស់សំណល់ឡជីវឧស្ម័នជាជីសរីរាង្គដើម្បីដោះស្រាយការថយចុះជីជាតិដី និងបរិមាណសរីរាង្គក្នុងដី ដោយសារការប្រតិបត្តិកសិកម្មពុំមានចីរភាព ការប្រែប្រួលអាកាសធាតុ និងការប្រើប្រាស់ជីគីមី។
- មជ្ឈមណ្ឌលជំនាញសម្រាប់ឡជីវឧស្ម័នខ្នាតមធ្យម និងធំត្រូវបានបង្កើតឡើង (មានឈ្មោះថា មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ ដែលស្ថិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម) សម្រាប់ផ្តល់ជំនួយបច្ចេកទេស ការកសាងសមត្ថភាព និងការគាំទ្រកម្មវិធីសិក្សាកម្រិតសាកលវិទ្យាល័យលើឯកទេសជីវឧស្ម័នខណៈដែលមានសាកលវិទ្យាល័យ វិទ្យាស្ថាន មន្ទីរពិសោធន៍ និងសាលាបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមួយចំនួន ក៏ផ្តល់ជូនវគ្គសិក្សាបន្ថែម ឬហេដ្ឋារចនាសម្ព័ន្ធគាំទ្រលើផ្នែកវិស្វកម្មសំណង់ស៊ីវិល មេហ្គាត្រូនិចធុរកិច្ច និងជំនាញបច្ចេកទេស (ផ្សារដែក ពិសោធន៍ ។ល។ )។
- តម្រូវការក្នុងការបង្កើនផលិតកម្មជីសរីរាង្គក្នុងប្រទេសដើម្បីបំពេញសេចក្តីត្រូវការទីផ្សារ និងកាត់បន្ថយការពឹងផ្អែកលើការនាំចូលជី។
- គម្រោងឥណទានកាបោនដែលបានបង្កើតឡើងសម្រាប់កម្មវិធីឡជីវឧស្ម័នជាតិ និងក្រុមហ៊ុនATECជួយធានានូវការផ្តល់ហិរញ្ញប្បទានរយៈពេលវែងគាំទ្រដល់សកម្មភាពរបស់ស្ថាប័នទាំងនេះ។
- ការធ្វើប្រព្រឹត្តកម្មសំណល់រាវដោយគ្មានអុកស៊ីសែននៅក្នុងឡជីវឧស្ម័ន អាចកាត់បន្ថយហានិភ័យនៃជម្ងឺនានាពីសត្វនិងរុក្ខជាតិ រួមទាំងជម្ងឺស៊ូណូស។

***ការប្រឈម***

- ការបន្តពឹងផ្អែកលើមូលនិធិម្ចាស់ជំនួយ និងការឧបត្ថម្ភធនក្នុងការសាងសង់ឡជីវឧស្ម័ន។
- កង្វះ បទប្បញ្ញត្តិ ដែល មាន សង្គតិភាព សម្រាប់ គ្រប់ អ្នកពាក់ព័ន្ធ និងជីវឧស្ម័នទាំងអស់ដែលធ្វើឱ្យការប្រកួតប្រជែងមិនស្មើភាពដោយសារពួកគេទទួលបានការឧបត្ថម្ភធន និងមានកម្រិតបង់ពន្ធខុសគ្នា។
- ពន្ធនាំចូលនិងអាករសម្រាប់វត្ថុធាតុដើម/បរិក្ខារថ្មីមួយចំនួន រួមទាំងម៉ាស៊ីនភ្លើងប្រើប្រាស់ជីវឧស្ម័ន (សម្រាប់ឡខ្នាតតូច មធ្យម និងធំ) មិនទាន់មានគោលនយោបាយលើកទឹកចិត្តពីរដ្ឋាភិបាលនៅឡើយ។
- កង្វះបទប្បញ្ញត្តិ ស្តីពីមូលដ្ឋានគុណភាពឡជីវឧស្ម័ន សុវត្ថិភាព បទដ្ឋានបច្ចេកទេស ធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តនៃបច្ចេកវិទ្យាឡជីវឧស្ម័នខ្នាតតូច មធ្យម និងធំ ពីសំណាក់ធនាគារ វិនិយោគិន ឬកសិករ។
- កង្វះក្របខ័ណ្ឌសម្រាប់ការលក់ថាមពលអគ្គិសនីដែលផលិតបានពីជីវឧស្ម័នទៅបណ្តាញរដ្ឋដូចនេះអគ្គិសនីដែលផលិតបាន គឺសម្រាប់តែប្រើប្រាស់ក្នុងផលិតកម្មផ្ទាល់ខ្លួនតែប៉ុណ្ណោះ។
- ការទទួលបានហិរញ្ញប្បទានសម្រាប់ការសាងសង់ឡជីវឧស្ម័ននៅជួបការលំបាកនៅឡើយ ដោយសារកសិករមានកម្ចីលើតម្រូវការផ្សេងៗរួចហើយ ទាមទារឱ្យមានទ្រព្យបញ្ចាំខ្ពស់ និងជាគម្រោងមានហានិភ័យខ្លាំងជាពិសេសកសិដ្ឋានចិញ្ចឹមជ្រូក (ធនាគារមិនដែលផ្តល់ហិរញ្ញប្បទានដល់គម្រោងជីវឧស្ម័ន ឬចាត់ទុកគម្រោងជីវឧស្ម័នជាគម្រោងមានហានិភ័យ)។
- សំណល់បានមកពីឡជីវឧស្ម័ននៅមិនទាន់ត្រូវបានប្រើប្រាស់ទូលំទូលាយនៅឡើយ ដោយសារការយល់ដឹងអំពីអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងបរិស្ថាននៅមានកម្រិត ម្យ៉ាងទៀតបច្ចេកវិទ្យា/វិធីសាស្ត្រក្នុងការកែច្នៃការរក្សាទុកនិងការលក់ផលិតផលនេះនៅខ្វះខាតនៅឡើយ។
- ការប្រើប្រាស់ឡជីវឧស្ម័នគ្រួសារ អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម និងធំមានការជួបប្រទះនូវឧបសគ្គមួយចំនួនរួមមានតម្លៃថ្លៃ បទពិសោធន៍ និងសមត្ថភាពក្នុងស្រុកនៅមានកម្រិត និងមិនទាន់ស្គាល់បច្ចេកវិទ្យាច្បាស់។

## ១.៦ ឡជីវឧស្ម័ននិងការរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា

ឡជីវឧស្ម័នផ្តល់អត្ថប្រយោជន៍យ៉ាងច្រើន មិនថាអ្នកប្រើប្រាស់ ជាងដំឡើង សេដ្ឋកិច្ច និងបរិស្ថាន ហើយពិតជាបាននិងកំពុងចូលរួមចំណែកដោយផ្ទាល់ដល់គោលដៅចំនួន៨ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDG)៖

| CSDG | ការរួមចំណែកនៃឡជីវឧស្ម័ន |
|---|---|
| ១. គ្មានភាពក្រីក្រ | ឡជីវឧស្ម័នខ្នាតតូចផ្តល់ថាមពលកកើតឡើងវិញ និងជាប្រភពថាមពលស្អាតសម្រាប់ការចម្អិនអាហារដែលជួយកាត់បន្ថយការចំណាយលើឥន្ធនៈ ដោះស្រាយភាពក្រីក្រ ថាមពល និងកាត់បន្ថយការចំណាយលើសុខភាពបើប្រៀបធៀបនឹងការចម្អិនដែលប្រើអុស ដោយសារសារធាតុបំពុលខ្យល់ដែលចេញពីចង្ក្រានជីវម៉ាស។ |
| ២. គ្មានភាពអត់ឃ្លាន | ការប្រើប្រាស់សំណល់ឡជីវឧស្ម័នជួយធ្វើឱ្យប្រសើរឡើងនូវសុខភាពដី និងប្រើប្រាស់ឡើងវិញនូវសារធាតុចិញ្ចឹមដែលជួយកសិករឱ្យទទួលកំណើនទិន្នផល និងធ្វើឱ្យដីកាន់តែមានជីជាតិធន់និងការប្រែប្រួលអាកាសធាតុ |
| ៣. សុខភាពល្អ និងសុខុមាលភាព | ប្រព្រឹត្តកម្មសំណល់លាមកសត្វដែលមិនត្រូវការអុកស៊ីសែនជួយកាត់បន្ថយហានិភ័យ ការចម្លងជម្ងឺ និងជួយធ្វើឱ្យសុខភាពមនុស្ស និងសត្វកាន់តែប្រសើរ។ ការចម្អិនអាហារដោយប្រើជីវឧស្ម័នធ្វើ ឱ្យ កាត់ បន្ថយ ការ បំពុល ខ្យល់ ក្នុង អគារបានយ៉ាងច្រើនដែលជួយធ្វើឱ្យ សុខភាពកាន់តែប្រសើរ និងបន្ថយការចំណាយខាងវេជ្ជសាស្ត្រ។ |
| ៥. សមភាពយេនឌ័រ | ការទទួលបានបច្ចេកវិទ្យាឡជីវឧស្ម័ននឹងរួមចំណែកដល់ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ព្រោះវាជួយលើកកម្ពស់ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រីនិងសមភាពកាលា-នុវត្តភាព។ ឧទាហរណ៍ បន្ទុកការងាររបស់ស្ត្រី (រួមបញ្ចូលទាំងកុមារ) ក្នុងការរកឬទិញអុសនឹងត្រូវបានកាត់បន្ថយ ការចម្អិនអាហារបានលឿនជាងមុន ហើយមិនចាំបាច់ចំណាយ ពេលសំអាតគូថឆ្នាំងច្រើនដូចមុនព្រោះគ្មានស្នាមប្រឡាក់ធ្យូងគូថឆ្នាំងនាំឱ្យស្ត្រីមានពេលវេលា ច្រើនជាងមុនដើម្បីកែលម្អជីវភាពរស់នៅរបស់គាត់និងគ្រួសារ។ |
| ៧. ថាមពលស្អាត និងមានតម្លៃសមរម្យ | ជីវឧស្ម័នគឺជាថាមពលស្អាតនិងកកើតឡើងវិញ និងអាចយកមកសម្រាប់ចម្អិនអាហារ ឬផលិតកំដៅផ្សេងទៀត ឬ/និងអាចផលិតអគ្គិសនីផងដែរ។ |
| ៨. ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច | ការសាងសង់ឡជីវឧស្ម័នជួយបង្កើតកាលានុវត្តភាពការងារដល់កសិករ និងកម្មករជំនាញនៅទីជនបទដែលជាលទ្ធផលជួយលើកកម្ពស់សេដ្ឋកិច្ចជនបទ។ |
| ១៣. សកម្មភាពអាកាសធាតុ | ឡជីវឧស្ម័នអាចបន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានច្រើន ដោយបន្ថយការបញ្ចេញឧស្ម័នមេតានចេញពីវិស័យបសុសត្វ និងជំនួសការប្រើប្រាស់ថាមពលជីវម៉ាស់ និងឥន្ធនៈ ផូស៊ីលដែលមិនកកើតឡើងវិញក្នុងការចម្អិនអាហារ ឬជំនួសការប្រើប្រាស់អគ្គិសនីរដ្ឋបានចំពោះឡជីវឧស្ម័នខ្នាតធំ។ |
| ១៥.ជីវិតនៅលើដី | ការកាត់បន្ថយអុសដែលប្រើប្រាស់សម្រាប់ចម្អិនអាហារ ជួយកាត់បន្ថយសម្ពាធលើព្រៃឈើ ហើយការប្រើប្រាស់ជីកាកសំណល់ឡជីវឧស្ម័នជួយធ្វើឲ្យប្រសើរឡើងនូវគុណភាពដី (រួមទាំងសុខភាពអតិសុខុមប្រាណក្នុងដីផងដែរ)។ |

## ២. ចក្ខុវិស័យ

គ្រួសារកសិករ សហគមន៍ជនបទ និងកសិធុរជនមានជីវភាពរស់នៅកាន់តែប្រសើរឡើង និងបង្កើនផលចំណេញពីធុរកិច្ចរបស់ខ្លួនក្នុងបរិស្ថានល្អ និងមាននិរន្តរភាពតាមរយៈការប្រើប្រាស់ឡជីវឧស្ម័នប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងចីរភាព។

## ៣. គោលបំណង និងគោលដៅ

### ៣.១ គោលបំណង

លើកកម្ពស់ការប្រើប្រាស់ឡជីវឧស្ម័នប្រកបដោយប្រសិទ្ធភាព និងចីរភាពសំដៅផ្គត់ផ្គង់ថាមពលកកើតឡើងវិញនៅជនបទ និងធ្វើឱ្យប្រសើរឡើងផលិតកម្មកសិកម្ម ព្រមទាំងរួមចំណែកបង្កើនកម្រិតជីវភាពរស់នៅដល់គ្រួសារកសិករ សហគមន៍ជនបទ និងកសិធុរកិច្ច ដែលនឹងចូលរួមសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា។

### ៣.២ គោលដៅ

១. ផ្លាស់ប្តូរ/ពង្រឹងការគ្រប់គ្រងសំណល់សត្វ និងដំណាំតាមរយៈការដំឡើង និងប្រើប្រាស់ឡជីវឧស្ម័នដែលមាន គុណភាព ដើម្បី ផលិត ជីវឧស្ម័ន និង ជីកាក សំណល់ ឡជីវឧស្ម័ន ឆ្ពោះ ទៅ ការ បង្កើន ការ សាងសង់ឡជីវឧស្ម័នដែលមានគុណភាព។

២. ពង្រីកការស្រាវជ្រាវ និងអភិវឌ្ឍន៍លើបច្ចេកវិទ្យាឡជីវឧស្ម័ន រួមទាំងបរិក្ខារប្រើប្រាស់ជីវឧស្ម័ន និងសំណល់ជីឡដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីឡជីវឧស្ម័ន។

៣. បង្កើត បរិយាកាស ដែល ទាក់ទាញ និង អំណោយផល ដល់វិស័យឯកជនដែលអនុញ្ញាតឱ្យធនាគារ ក្រុមហ៊ុនផ្គត់ផ្គង់ប្រព័ន្ធជីវឧស្ម័ន និងតួអង្គឯកជនដទៃទៀតបង្កើនការវិនិយោគលើឡជីវឧស្ម័ន។

៤. បង្កើនការផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍ក្នុងវិស័យជីវឧស្ម័នដោយឆ្លៀតទាញយកផលចំណេញពីការងារទាក់ទង នឹងការប្រែប្រួលអាកាសធាតុ និងបង្កើនការវិភាជន៍ថវិកាជាតិសម្រាប់ការអភិវឌ្ឍឡជីវឧស្ម័ន។

**តារាង៤៖ សូចនាករសមិទ្ធកម្មសំខាន់ៗត្រូវសម្រេចឱ្យបាននៅត្រឹមឆ្នាំ២០២៥ និង២០៣០**

| # | សូចនាករ | ២០២០ [២៥] | ២០២៥ [២៦] | ២០៣០ [២៧] |
|---|---|---|---|---|
| ១ | ឧស្ម័នផ្ទះកញ្ចក់ត្រូវបានកាត់បន្ថយ (ពាន់តោនសមមូលឧស្ម័នកាបូនិច) | ៨២៤ | ១ ៦៨៩ | ២ ៥៥៤ |

[២៥] *តួលេខបូកបន្តចន្លោះឆ្នាំ២០០៦-២០២០ ផ្អែកលើរបាយការណ៍ការបានរបស់កម្មវិធីឡជីវឧស្ម័នជាតិ*

[២៦] *តួលេខព្យាករណ៍នៃគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា ២០១៦-២០២៥*

[២៧] *ព្យាករណ៍ផ្អែកលើតួលេខឆ្នាំ២០២០ និង២០២៥*

| | | | | |
|---|---|---|---|---|
| ២ | បរិមាណអុសត្រូវបានកាត់បន្ថយ (ពាន់តោន) | ២៧៣ | ៤៨៩ | ៧០៥ |
| ៣ | បរិមាណជីកាកសំណល់ឡជីវឧស្ម័នត្រូវបានប្រើប្រាស់ (ពាន់តោន) | ៧ ៧៦០ | ១៣ ៨៨៨ | ២០ ០១៦ |
| ៤ | សមត្ថភាពប្រព័ន្ធជីវឧស្ម័នសរុប (មេកាវ៉ាត់) | ៨[២៨] | ៥២ | ១០៥ |
| ៥ | ចំនួនឡជីវឧស្ម័នគ្រួសារត្រូវបានសាងសង់សរុប (ពាន់ឡ) តាំងពីឆ្នាំ ២០០៦ | ៣១[២៩] | ៤៣ | ៦៥ |
| ៦ | ចំនួនឡជីវឧស្ម័នខ្នាតតូច និងមធ្យមត្រូវបានសាងសង់សរុបនៅកសិដ្ឋានចិញ្ចឹមសត្វ | ៤៣[៣០] | ២៥០ | ៥០០ |
| ៧ | ចំនួនឡជីវឧស្ម័នខ្នាតធំត្រូវបានសាងសង់សរុបនៅកសិដ្ឋានចិញ្ចឹមសត្វ | | ១០ | ២០ |
| ៨ | ចំនួនឡជីវឧស្ម័នខ្នាតមធ្យមនិងធំត្រូវបានសាងសង់សរុបនៅតាមឧស្សាហកម្មកែច្នៃកសិចំណីអាហារ | ៤ | ១០ | ២០ |
| ៩ | ចំនួនសត្តឃាតដ្ឋានមានឡជីវឧស្ម័ន (ឡ) | ១[៣១] | ៥០ | ៧៦ |
| ១០ | ចំនួនសហគមន៍អ្នកប្រើប្រាស់ឡជីវឧស្ម័នត្រូវបានបង្កើត (សហគមន៍) | ១[៣២] | ៥ | ១០ |

## ៤. យុទ្ធសាស្ត្រដើម្បីសម្រេចគោលដៅ

គោលនយោបាយនេះនឹងកំណត់យុទ្ធសាស្ត្រចំនួន៥រួមមាន៖

### ៤.១ ពង្រឹងការងារអភិបាលកិច្ច

វិស័យជីវឧស្ម័ននៅកម្ពុជាបានឆ្លងកាត់ដំណាក់កាលជាច្រើន ដែលរួមមាន៖

១. ដំណាក់កាលសាកល្បង(អំឡុងឆ្នាំ១៩៨៦-២០០៥)៖ ការផ្សព្វផ្សាយពីឡជីវឧស្ម័នដែលមានតម្លៃទាបតែមិនសង្កត់ធ្ងន់លើគុណភាព

២. ដំណាក់កាលសមាហរណកម្ម (អំឡុងឆ្នាំ២០០៦-២០១៣)៖ ការបង្កើតកម្មវិធីឡជីវឧស្ម័នជាតិ (NBP) ដោយជំរុញបច្ចេកវិទ្យាមួយដែលអាចទុកចិត្តបាននិងមានការត្រួតពិនិត្យគុណភាពច្បាស់លាស់

៣. ដំណាក់កាលទីផ្សារប្រកួតប្រជែង (អំឡុងឆ្នាំ២០១៤-បច្ចុប្បន្ន)៖ ដោយមានទាំងកម្មវិធីឡជីវឧស្ម័នជាតិ និងក្រុមហ៊ុនថ្មីៗមួយចំនួនលក់ប្រព័ន្ធជីវឧស្ម័នខ្នាតផ្សេងៗគ្នា និងបច្ចេកវិទ្យាជីវឧស្ម័នថ្មីៗក៏ច្រើនប្រភេទដែរ។

---

[២៨] *កិច្ចសន្យាជាមួយក្រុមហ៊ុនCPមិនត្រូវបានបញ្ចូលទេដោយសារកង្វះខាតទិន្នន័យ។ តួលេខឆ្នាំ២០២៥ និង២០៣០ត្រូវបានគណនាដោយសន្មតយកប្រព័ន្ធឡជីវឧស្ម័នទំហំ100kVA ចំពោះកសិដ្ឋានខ្នាតមធ្យម 250kVAចំពោះកសិដ្ឋានខ្នាតធំ និង 500kVAចំពោះកសិធុរកិច្ច។*

[២៩] *តួលេខសរុបនៃ NBP (28,863) និង ATEC (1,800)*

[៣០] *ប៉ាន់ស្មានផ្អែកលើតារាងទី២ - តួលេខមិនបានបរិយាយពីទំហំកសិដ្ឋាន និងមានតែកសិដ្ឋានក្រុមហ៊ុនCPប៉ុណ្ណោះដែលបានដំឡើងបរិក្ខារផលិតអគ្គិសនីពីជីវឧស្ម័ន*

[៣១] *សត្តឃាតដ្ឋានខ្នាតតូចមួយកន្លែងនៅឃុំឈូកក្នុងខេត្តកំពត*

[៣២] *ទំព័រហ្វេសប៊ុក ATEC Smart Farmer*

ភាពចម្រុះនៃបច្ចេកវិទ្យាបែបនេះផ្តល់នូវជម្រើសដល់កសិករ និងអាជីវករ ហើយការប្រកួតប្រជែងក៏បាននាំមកនូវសេវាកម្ម និង/ឬតម្លៃប្រសើរជាងមុនផងដែរ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើតគណៈកម្មការតម្រង់ទិស និងពង្រឹកតួនាទីរបស់កម្មវិធីឡជីវឧស្ម័នជាតិ(NBP)ឱ្យក្លាយជាអង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័នដែលនៅក្រោមអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វសម្រាប់គ្រប់គ្រង និងសម្របសម្រួលការអភិវឌ្ឍវិស័យឡជីវឧស្ម័ន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបាន និងកំពុងបង្កើតបទដ្ឋានបច្ចេកទេសសំណង់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នដោយបានសហការយ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធទាំងអស់ដើម្បីធានាថា ការប្រកួតប្រជែងមានការផ្គត់ផ្គង់ឡជីវឧស្ម័ន ឬសេវាកម្មដែលមានគុណភាពឱ្យកាន់តែប្រសើរឡើង។ បទដ្ឋានបច្ចេកទេសបែបនេះ នឹងផ្តល់នូវគោលការណ៍ណែនាំសម្រាប់ចង្អុលបង្ហាញពីតម្រូវការដែលស៊ីចង្វាក់គ្នា ដើម្បីការពារផលប្រយោជន៍មិនត្រឹមតែអ្នកប្រើប្រាស់ចុងក្រោយទេ ថែមទាំងអ្នកផ្គត់ផ្គង់បច្ចេកវិទ្យា បរិស្ថាន និងសេដ្ឋកិច្ចជនបទទៀតផង។ អង្គភាពនេះត្រូវអនុវត្តបទដ្ឋានបច្ចេកទេសតាមគោលការណ៍អព្យាក្រឹត្យ។

## ៤.២ ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន

គ្រួសារកសិករ កសិដ្ឋាន សត្តឃាតដ្ឋាន និងរោងចក្រកែច្នៃកសិផលមួយចំនួនធំនៅមិនទាន់មានឡជីវឧស្ម័ននៅឡើយទេ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសម្របសម្រួលជំរុញការសាងសង់ឡជីវឧស្ម័នដើម្បីគ្រប់គ្រងកាកសំណល់/លាមកសត្វ សំណល់រាវ និងបង្កើនប្រាក់ចំណូលបន្ថែម ដោយកាត់បន្ថយចំណាយលើអុសធ្យូង ថាមពលអគ្គិសនី និងការប្រើប្រាស់ជីគីមី។

ម្យ៉ាងទៀត ការលើកកម្ពស់ការយល់ដឹងអំពីអត្ថប្រយោជន៍ដែលបានពីឡជីវឧស្ម័ន នឹងត្រូវបានធ្វើឡើងជាពិសេស ដើម្បីបំពេញសេចក្តីត្រូវការនិងតម្រូវការរបស់ស្ថាប័នឬតួអង្គទាំងឡាយដែលពាក់ព័ន្ធ។ ចំពោះគ្រួសារកសិករ សកម្មភាពនេះនឹងផ្តោតលើការកែលម្អផលិតកម្មកសិកម្ម ការរក្សាវត្ថុសារធាតុចិញ្ចឹម ការបង្ការការបំពុលខ្យល់ក្នុងអគារ ការសន្សំពេលវេលា និងចំណាយលើឥន្ធនៈរួមទាំងភាពងាយស្រួលផង។ សម្រាប់អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម និងធំវិញ សកម្មភាពនេះ នឹងផ្តោតលើការលើកកម្ពស់សេដ្ឋកិច្ចជារួមរបស់កសិដ្ឋាន ឬកសិធុរកិច្ច តាមរយៈផលិតកម្មអគ្គិសនីសម្រាប់ប្រើប្រាស់នៅមូលដ្ឋានទាំងនេះ ព្រមទាំងការប្រើប្រាស់សំណល់ឡជីវឧស្ម័ន។

បន្ថែមពីនេះទៀត ការលើកកម្ពស់ការយល់ដឹងក៏នឹងផ្តោតលើបញ្ហាមួយចំនួនដើម្បីចៀសវាងការបំពុលប្រភពទឹកនៅមូលដ្ឋាន ដែលឈានដល់ការបង្កើតអ៊ីត្រូពីកាស្យុង (កំណើនសារធាតុចិញ្ចឹមក្នុងទឹក) ការបំពុលក្លិន និងការកាប់បំផ្លាញព្រៃឈើ។ ជាមួយគ្នានេះសំណល់ឡជីវឧស្ម័នមានសក្តានុពលកាត់បន្ថយសំណឹកដីដូច្នេះការបង្កើនគុណភាពដីនឹងត្រូវបានយកចិត្តទុកដាក់។ លើសពីនេះទៀត ឡជីវឧស្ម័ននឹងត្រូវបានជំរុញជាវិធីសាស្ត្រពេញនិយមក្នុងការបំពេញនូវបទប្បញ្ញត្តិគ្រប់គ្រងកាកសំណល់/លាមកសត្វ ដូចដែលមានចែងក្នុងប្រកាស លេខ៥៤៩។

## ៤.៣ លើកកម្ពស់គុណភាពឡជីវឧស្ម័ន និងប្រយោជន៍ឡជីវឧស្ម័ន

ការស្រាវជ្រាវ និងអភិវឌ្ឍន៍ដើម្បីកែលម្អបច្ចេកវិទ្យាឡជីវឧស្ម័ន គឺជាការចាំបាច់ដើម្បីធានាថាបច្ចេកវិទ្យានេះនៅតែអាចបំពេញបានតាមការរំពឹងទុករបស់ទីផ្សារ ហើយមិនតែប៉ុណ្ណោះ វាក៏ធ្វើឱ្យបច្ចេកវិទ្យារីកចម្រើន ដើម្បីឆ្លើយ

តបនឹងការវិវត្តនៅក្នុងវិស័យនេះផងដែរ។ ជាមួយគ្នានេះ ការកសាងសមត្ថភាពនៅគ្រប់កម្រិត (ចាប់ពីកម្រិតជាងសាងសង់ រហូតដល់អ្នកបច្ចេកទេស វិស្វករជីវឧស្ម័ន និងអ្នកប្រើប្រាស់ចុងក្រោយ) នៅតែចាំបាច់នៅឡើយ ដើម្បីបង្កើនសមិទ្ធកម្មនៃបច្ចេកវិទ្យាទាំងនេះ និងក៏ដើម្បីជំរុញដំណើរការស្រាវជ្រាវនិងអភិវឌ្ឍន៍ផងដែរ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបន្តធ្វើការវិភាជន៍ថវិកាចាំបាច់សម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដោយសហការជាមួយមជ្ឈមណ្ឌលជំនាញដែលមានស្រាប់ដូចជា កម្មវិធីឡជីវឧស្ម័នជាតិ (NBP) និងមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) ក្នុងការបង្កើតរបៀបវារៈស្រាវជ្រាវសម្រាប់ដោះស្រាយបញ្ហាប្រឈមសំខាន់ៗរបស់វិស័យនេះ។ ចំពោះឡជីវឧស្ម័នខ្នាតតូច មធ្យម និងធំ ការងារនេះរាប់បញ្ចូលទាំងការកែលម្អប្រសិទ្ធភាពនិងតម្លៃនៃឧបករណ៍ចម្រោះឧស្ម័នអ៊ីដ្រូសែនស៊ុលហ្វីត ($H_2S$) ម៉ាស៊ីនភ្លើងជីវឧស្ម័ន ម៉ាស៊ីនបូមទឹកជីវឧស្ម័ន នាឡិកាកត់ត្រាបរិមាណឧស្ម័ន ការដុតឧស្ម័នចោល (ក្នុងករណីឧស្ម័ននៅសល់លើសពីកម្រិតកំណត់) ការរក្សាទុក និងការប្រើប្រាស់សំណល់ឡជីវឧស្ម័នឱ្យមានប្រសិទ្ធភាព ការស្រាវជ្រាវនិងអភិវឌ្ឍន៍ដើម្បីការកែលម្អការរចនាប្លង់រំដោះទឹក ចេញដើម្បីបង្កើនទិន្នផលជីវឧស្ម័នឱ្យដល់កម្រិតអតិបរិមា និងដើម្បីទប់ស្កាត់ការបំពុលទឹកក្រោមដីផងដែរ។ ចំណែកឯឡជីវឧស្ម័នគ្រួសារវិញ ការស្រាវជ្រាវនិងអភិវឌ្ឍន៍គួរគាំទ្រការផ្លាស់ប្តូរបន្តិចម្តងៗនៃឡឥដ្ឋបេតុងទៅជាឡដំឡើងទុកជាមុនដែលធ្វើពីស្វាច់ ដែលអាចជួយដោះស្រាយបញ្ហាមួយចំនួនទាក់ទងនឹងការខ្វះខាតជាងសាងសង់ និងកម្រិតប្រាក់ចំណេញទាបនៃឡឥដ្ឋបេតុង ។

ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ក៏នឹងបែងចែកដើម្បីគាំទ្រនូវកាលានុវត្តភាពមួយចំនួនសម្រាប់រយៈពេលមធ្យម និងវែង រួមមានការបន្សុទ្ធនិងបណ្ណែនជីវឧស្ម័នសម្រាប់ប្រើជាឥន្ធនៈយានជំនិះ ឬសម្រាប់គោលបំណងផ្សេងៗទៀត (ឧទាហរណ៍ឥន្ធនៈសម្រាប់ឡចំហាយក្នុងរោងចក្រកាត់ដេរ)។

ការកសាងសមត្ថភាពនៅតែត្រូវការជាចាំបាច់សម្រាប់គ្រប់កម្រិតទាំងអស់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើការជាមួយវិទ្យាស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) និងសហការជាមួយវិទ្យាស្ថានអប់រំកសិកម្ម បរិស្ថាន និងវិស្វកម្ម រួមទាំងមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) ដើម្បីបង្កើតកម្មវិធីសិក្សាពាក់ព័ន្ធជីវឧស្ម័ន។

## ៤.៤ លើកកម្ពស់ការលើកទឹកចិត្ត និងការឧបត្ថម្ភធន

ការគាំទ្រហិរញ្ញប្បទានជាការចាំបាច់សម្រាប់ការអភិវឌ្ឍ ការបណ្តុះបណ្តាល ការឧបត្ថម្ភធន ការត្រួតពិនិត្យគុណភាព ការអភិវឌ្ឍបទដ្ឋានបច្ចេកទេស ជំនួយបច្ចេកទេស រួមនឹងការអនុវត្តសកម្មភាពជាក់ស្តែងផងដែរ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើការកៀរគរធនធាន និងបន្តផ្តល់ជំនួយតាមលទ្ធភាពដើម្បីអភិវឌ្ឍវិស័យនេះ។ ក្រសួងនឹងខិតខំបង្កើនថវិកាជាតិសម្រាប់វិស័យជីវឧស្ម័ន ព្រមទាំងសម្របសម្រួលជាមួយដៃគូ អភិវឌ្ឍន៍នានាដើម្បីបន្តផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្មផងដែរ។

ការឧបត្ថម្ភធនដល់អ្នកប្រើប្រាស់ចុងក្រោយ ឬការផ្តល់ហិរញ្ញប្បទានសម្រាប់ក្រុមហ៊ុន ដោយផ្អែកលើលទ្ធផលដែលសម្រេចបាន នៅតែចាំបាច់ក្នុងរយៈពេលខ្លី និងត្រូវការការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ ទោះបីជាយ៉ាងនេះក៏ដោយ ការឧបត្ថម្ភធនដល់អ្នកប្រើប្រាស់ចុងក្រោយ នឹងបញ្ឈប់ជាបណ្តើរៗ ដោយមានបរិធានតម្រង់ទីផ្សារដូចជា ភតិសន្យាឈានទៅធ្វើជាម្ចាស់កម្មសិទ្ធ ក្រុមហ៊ុន ផ្តល់សេវាកម្មថាមពល (ESCO) និងការទូទាត់ប្រាក់នៅពេលដែលប្រើប្រាស់ (Pay As You Go) អាចអនុវត្តបាន។ ការឧបត្ថម្ភធនអាចផ្តល់ជូនចំពោះតែគ្រួសារកសិករដែលបំពេញបាននូវលក្ខខណ្ឌម៉ត់ចត់ និងមាន

តម្លាភាពប៉ុណ្ណោះ ឧទាហរណ៍ ប្រាក់ចំណូលមិនគ្រប់គ្រាន់ ស្ត្រីមេម៉ាយ ឬអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) ថ្នាក់ជាតិរបស់ក្រសួងផែនការតែប៉ុណ្ណោះ។

វិធានការទីផ្សារផ្សេងទៀតនឹងយកមកពិចារណាផងដែរ ដែលរួមមានការលើកលែងពន្ធ (នាំចូល) លើបរិក្ខារបច្ចេកទេស (ម៉ាស៊ីនភ្លើងជីវឧស្ម័ន ម៉ាស៊ីនបូមទឹកជីវឧស្ម័ន បរិក្ខារប្រើប្រាស់ជីវឧស្ម័ន នាឡិកាស្ទង់ជីវឧស្ម័ន ឧបករណ៍ចម្រោះឧស្ម័នអ៊ីដ្រូសែនស៊ុលហ្វីត ($H_2S$) និងសារធាតុចាប់យក ($H_2S$) ឧបករណ៍ និងសម្ភារៈសាងសង់ ឡជីវឧស្ម័ន និងការលើកលែងអាករលើតម្លៃបន្ថែម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើការជាមួយក្រសួងរ៉ែ និងថាមពល ដើម្បីរៀបចំបទប្បញ្ញត្តិសម្រាប់ការលក់អគ្គិសនីពីជីវឧស្ម័នទៅបណ្តាញអគ្គិសនីជាតិ ដោយមានលក្ខខណ្ឌទាក់ទាញ និងតម្លៃសមរម្យ។

### ៤.៥ បង្កើនទីផ្សារឥណទានកាបូនដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់

ឡជីវឧស្ម័ន ត្រូវបានគេទទួលស្គាល់ថាជាបច្ចេកវិទ្យាដែលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និង បង្កើនសមត្ថភាពបន្សុាំនឹងការប្រែប្រួលអាកាសធាតុរបស់កសិដ្ឋាន ហើយការប្រើប្រាស់សំណល់ឡជីវឧស្ម័នធ្វើឱ្យគុណភាពដីប្រសើរឡើងផងដែរ។

យុទ្ធសាស្ត្រស្តីពីសកម្មភាពអាកាសធាតុ នឹងផ្តោតលើការកែលម្អផលប៉ះពាល់អវិជ្ជមាននៃឡជីវឧស្ម័នទៅលើអាកាសធាតុ ការដោះស្រាយការបញ្ចេញជីវឧស្ម័ន កែលម្អការទុកដាក់សំណល់ឡជីវឧស្ម័ន និងការកៀរគរមូលធនតាមរយៈយន្តការទីផ្សារកាបូន ឬហិរញ្ញវត្ថុអាកាសធាតុដ៏ទៃទៀត រួមទាំងការអនុវត្តកាតព្វកិច្ចដែលបានចែងក្នុងរបាយការណ៍រួមចំណែករបស់កម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (NDC) ដើម្បីទទួលបានហិរញ្ញប្បទានសម្រាប់វិស័យនេះ។

## ៥. ផែនការសកម្មភាព

### ៥.១ ការបង្កើតយន្តការអនុវត្តន៍

ដើម្បីអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព រចនាសម្ព័ន្ធអភិបាលកិច្ចចាំបាច់សម្រាប់វិស័យនេះត្រូវដំណើរការ សម្របសម្រួល និងគ្រប់គ្រងឱ្យបាននូវអន្តរកម្មដែលមានលក្ខណៈចម្រុះ និងស្មុគស្មាញ ក្នុងចំណោមអ្នកពាក់ព័ន្ធ ទាំងឡាយដើម្បីដោះស្រាយបញ្ហាប្រឈម និងបន្តអភិវឌ្ឍវិស័យនេះប្រកបដោយនិរន្តរភាព។ អង្គភាព/ស្ថាប័ន/ទីភ្នាក់ងារ ដែលមានស្រាប់ ត្រូវបានចាត់ចែងឱ្យទទួលខុសត្រូវលើការងារដែលពាក់ព័ន្ធ នឹងអាណត្តិរបស់អង្គភាពទាំងនោះ ហើយធនធានមនុស្សត្រូវបានចាត់តាំងតាមការចាំបាច់ និងជាសារវន្តដើម្បីបំពេញភារកិច្ច។ ដើម្បីអនុវត្តគោលនយោបាយនេះឱ្យជោគជ័យ យន្តការខាងក្រោមនឹងត្រូវបានបង្កើតឡើង៖




គណៈកម្មាធិការតម្រង់ទិសថ្នាក់ជាតិ(NSC)មានតួនាទីសម្របសម្រួល និងផ្តល់ឱវាទដល់អង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័ន (កម្មវិធីឡជីវឧស្ម័នជាតិ) ក្នុងការអនុវត្តគោលនយោបាយឡជីវឧស្ម័ននិងផែនការយុទ្ធសាស្ត្រ។ ចំណែកក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ (NATWG)មានតួនាទីជួយគណៈកម្មាធិការនេះលើផ្នែកបច្ចេក-ទេស និងការរៀបចំថវិកា។ អង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័ន (កម្មវិធីឡជីវឧស្ម័នជាតិ) មានតួនាទី អនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិនិងថ្នាក់ខេត្ត ហើយនៅខេត្តនីមួយៗ កម្មវិធីឡជីវឧស្ម័នថ្នាក់ខេត្តនឹងត្រូវបានបង្កើតនៅក្រោមការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសាមី ដើម្បីអនុវត្តគោលនយោបាយ និងផែនការសកម្មភាពនៅថ្នាក់ខេត្តផងដែរ[៣៣]។

ដោយអនុលោមតាមគោលនយោបាយបញ្ជ្រាបយេនឌ័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការបង្កើតគណៈកម្មាធិការនិងក្រុមការងារខាងលើ នឹងត្រូវមានតុល្យភាពយេនឌ័រ ដោយយ៉ាងហោចណាស់ត្រូវមានសមាជិក៣០%ជាស្ត្រី។

### ក) គណៈកម្មាធិការតម្រង់ទិសថ្នាក់ជាតិ (NSC)

គណៈកម្មាធិការតម្រង់ទិសថ្នាក់ជាតិ គឺជាយន្តការសម្របសម្រួល ប្រកបដោយប្រសិទ្ធភាព សម្រាប់ការអនុវត្ត គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០។ គណៈកម្មាធិការនេះបង្កើតឡើងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | សមាជិកអចិន្ត្រៃយ៍ |
| អគ្គលេខាធិការ/អគ្គលេខាធិការរងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| នាយកកម្មវិធីឡជីវឧស្ម័នជាតិ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

[៣៣] *n ជាចំនួន កម្មវិធីឡជីវឧស្ម័នថ្នាក់ខេត្ត*

ប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
តំណាងវិស័យឯកជនពាក់ព័ន្ធឡជីវឧស្ម័ន	សមាជិក
តំណាងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងតំណាងធនាគារសហគ្រាសធុនតូច និងមធ្យម	សមាជិក
តំណាងក្រសួងបរិស្ថាន	សមាជិក

គណៈកម្មាធិការតម្រង់ទិសថ្នាក់ជាតិនឹងអនុវត្តកិច្ចការអាទិភាពសំខាន់ៗដូចខាងក្រោម៖

- តម្រង់ទិស សម្របសម្រួល និងណែនាំ ការអនុវត្ត គោលនយោបាយ អភិវឌ្ឍន៍ ឡជីវឧស្ម័ន នៅកម្ពុជាឆ្នាំ ២០២១-២០៣០ ដើម្បីសម្រេចគោលដៅនិងគោលបំណងដូចមានចែងក្នុងគោលនយោបាយនេះ
- សម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ឱ្យមានគោលការណ៍អនុវត្តតែមួយ
- ពិនិត្យ និងអនុម័តផែនការសកម្មភាពប្រចាំឆ្នាំ ៣ឆ្នាំ និង៥ឆ្នាំ រួមទាំងផែនការថវិកាដែលបានស្នើដោយក្រុមការងារ បច្ចេកទេស ថ្នាក់ជាតិ និងថ្នាក់ខេត្ត ដើម្បី ធានា ថា សកម្មភាព ដែល បាន ស្នើ ឡើង ឆ្លើយ តប នឹង គោលនយោបាយនេះ
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធនានា ក្រោមយន្តការក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ជាមួយនឹងយន្តការដទៃទៀត ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ និងជំរុញការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជាប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព
- តាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាព ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាពរបស់អង្គភាពពាក់ព័ន្ធ។

**ខ) ក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ (NATWG)**

ក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ គឺជាយន្តការមួយសម្រាប់ជួយដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០។ ក្រុមការងារនេះនឹងត្រូវបង្កើតឡើងតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានសមាសភាពដូចខាងក្រោម៖

- រដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	ប្រធាន
- អនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	អនុប្រធាន
- អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	អនុប្រធាន
- អគ្គលេខាធិការ/អគ្គលេខាធិការរងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
- នាយកកម្មវិធីឡជីវឧស្ម័នជាតិ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
- ប្រធានកម្មវិធីឡជីវឧស្ម័នជាតិ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
- សមាជិកសកម្មនៃក្រុមសកម្មភាពបញ្ញាបយេនឌ័រនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក

- ប្រធាននាយកដ្ឋាន ឬវិទ្យាស្ថានដែលពាក់ព័ន្ធនៅក្រោម អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ — សមាជិក
- ប្រធានការិយាល័យ ឬ តំណាងការិយាល័យពាក់ព័ន្ធនៃនាយកដ្ឋាន និងវិទ្យាស្ថាននៅក្រោមអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ — សមាជិក
- តំណាងក្រសួងរ៉ែ និងថាមពល (MME) — សមាជិក
- តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) — សមាជិក
- តំណាងក្រសួងបរិស្ថាន (MoE) — សមាជិក
- ប្រធានការិយាល័យគ្រប់គ្រងសំណល់សត្វនៃអ.ស.ផ.ស. — សមាជិកអចិន្ត្រៃយ៍
- តំណាងអ្នកទីផ្សារនៃកម្មវិធីឡជីវឧស្ម័នជាតិ — សមាជិក
- តំណាងអ្នកបច្ចេកទេសនៃកម្មវិធីឡជីវឧស្ម័នជាតិ — លេខាធិការ
- តំណាងវិស័យឯកជន (ក្រុមហ៊ុនផ្គត់ផ្គង់ឡជីវឧស្ម័ន) — សមាជិក
- តំណាងនៃមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ — សមាជិក
- តំណាងអគ្គនាយកដ្ឋានពន្ធដារ — សមាជិក
- ទីប្រឹក្សានៃកម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ — អ្នកសង្កេតការណ៍

ក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិត្រូវអនុវត្តការងារសំខាន់ៗដូចខាងក្រោម៖

- សហការយ៉ាងជិតស្និទ្ធជាមួយ គណៈកម្មាធិការ តម្រង់ទិស ថ្នាក់ជាតិ ក្នុង ការរៀបចំ គោលនយោបាយ បទប្បញ្ញត្តិបទដ្ឋានបច្ចេកទេស និងសំណើផ្សេងៗដែលទាក់ទងនឹងការអភិវឌ្ឍន៍ឡជីវឧស្ម័ន តម្លៃសម្រាប់លក់ទៅបណ្តាញអគ្គិសនីជាតិ ការលើកលែងពន្ធ និងយន្តការគាំទ្រសារពើពន្ធ និងមិនមែនសារពើពន្ធផ្សេងៗ
- សម្របសម្រួលការអនុវត្តកម្មវិធីឡជីវឧស្ម័នជាតិ អង្គភាពទទួលបន្ទុករួមទាំងអ្នកពាក់ព័ន្ធនឹងជីវឧស្ម័នផ្សេងទៀត ដើម្បីបង្កើនវឌ្ឍនភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់
- ត្រួតពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តផែនការសកម្មភាពដែលសម្រេចបានដោយកម្មវិធីឡជីវឧស្ម័នជាតិនិងខេត្ត ដើម្បីធានាថាការអនុវត្តមានប្រសិទ្ធភាព។

**គ) អង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័ន (កម្មវិធីឡជីវឧស្ម័នជាតិ)**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងពង្រីកតួនាទីរបស់កម្មវិធីឡជីវឧស្ម័នជាតិឱ្យក្លាយជាអង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័ន (apex biodigester body) នៅក្នុងអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីទំនាក់ទំនងផ្ទាល់ជាមួយក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ។ អង្គភាពនេះជាភ្នាក់ងារអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ន ហើយនឹងធ្វើកិច្ចការដោយមិនលំអៀងតំណាងឱ្យគ្រប់តួអង្គដែលទាក់ទងនឹងជីវឧស្ម័ន និងដើរតួនាទីគាំទ្រ និងជួយសម្របសម្រួលដើម្បីធានាគុណភាពសំណង់ឡជីវឧស្ម័ន រួមទាំងគុណភាពព័ត៌មាន សេវាកម្មក្រោយពេលសាងសង់ព្រមទាំងអនុវត្តការត្រួតពិនិត្យជាប្រចាំផងដែរ។ អង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័ននឹងអនុវត្តសកម្មភាពមួយចំនួនបន្ថែមទៀតដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ៣ឆ្នាំ និង៥ឆ្នាំ ដើម្បីអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០ ដោយជោគជ័យ

- អនុវត្តផែនការសកម្មភាពដែលបានអនុម័ត គ្រប់គ្រង និងប្រើប្រាស់មូលនិធិឡជីវឧស្ម័នឱ្យមានតម្លាភាព ដោយបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងៗដើម្បីផ្សព្វផ្សាយអំពីការប្រើប្រាស់ឡជីវឧស្ម័ននៅកម្ពុជា
- គ្រប់គ្រងឥណទានកាបូនសម្រាប់ឡជីវឧស្ម័នដែលបានសាងសង់ដោយម្ចាស់ជំនួយសាធារណៈ និងដៃគូអភិវឌ្ឍន៍នានា។

**ឃ) កម្មវិធីឡជីវឧស្ម័នខេត្ត**

ប្រធាន/ថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានឋានៈជាប្រធានកម្មវិធីឡជីវឧស្ម័នខេត្ត ហើយប្រធាន/ថ្នាក់ដឹកនាំការិយាល័យផលិតកម្ម និងបសុព្យាបាល មានឋានៈជាអនុប្រធាន/អ្នកសម្របសម្រួល ចំណែកមន្ត្រីនៃក្រុមការងារនេះរួមមានមន្ត្រីដែលមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី/ខេត្តសាមី។ កម្មវិធីឡជីវឧស្ម័នខេត្ត នឹងអនុវត្តសកម្មភាពអាទិភាពដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ស្របតាមការណែនាំរបស់អង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័ន (NBP) ដើម្បីអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០។
- អនុវត្តផែនការសកម្មភាពដែលបានអនុម័តរួច ដោយសហការ យ៉ាង ជិតស្និទ្ធ ជាមួយ អង្គភាពទទួលបន្ទុកអភិបាលកិច្ច និងភាគីផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលការអនុវត្តបច្ចេកទេស ពីទីប្រឹក្សាកម្មវិធីឡជីវឧស្ម័នជាតិ
- តាមដាន និងវាយតម្លៃលើការអនុវត្តសកម្មភាពសាងសង់ឡជីវឧស្ម័ន និងប្រតិបត្តិការនៅមូលដ្ឋាន
- សហការជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ដើម្បីដាក់បញ្ចូលថវិកាសម្រាប់សាងសង់ឡជីវឧស្ម័នក្នុងផែនការវិនិយោគឃុំ/សង្កាត់ ព្រមទាំងផ្តល់បច្ចេកទេសសាងសង់ និងបណ្តុះបណ្តាលអ្នកប្រើប្រាស់ឡជីវឧស្ម័ន
- សហការ និងគាំទ្រក្រុមហ៊ុន ភ្នាក់ងារ និងជាងសាងសង់ឡជីវឧស្ម័ន រួមទាំងវិស័យឯកជនពាក់ព័ន្ធនានាដែលស្ថិតក្នុងតំបន់ដែលមានសក្តានុពលសាងសង់ឡជីវឧស្ម័ន។

**ង) យន្តការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍**

ការគាំទ្រហិរញ្ញវត្ថុរបស់ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍សម្រាប់វិស័យឡជីវឧស្ម័នគួរផ្តល់ទៅអង្គភាពទទួលបន្ទុក អភិបាលកិច្ចឡជីវឧស្ម័ន (កម្មវិធីឡជីវឧស្ម័នជាតិ) តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននេះ បានបង្កើតឡើងក្រោមជំនួយហិរញ្ញវត្ថុដែលផ្តល់ដោយអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO)។ គោលនយោបាយនេះរំពឹងថា នឹងសហការស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍មួយចំនួនទៀតដូចជា មូលនិធិអាកាសធាតុបៃតង (GCF) មូលនិធិសម្រាប់សកម្មភាពជាតិក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់កម្រិតសមរម្យ (NAMA) មូលនិធិបរិស្ថានសកល (GEF) មូលនិធិអភិវឌ្ឍន៍កសិកម្មអន្តរជាតិ (IFAD) និងថវិកាជំនួយរបស់ប្រទេសផ្សេងៗ ក្នុងការអនុវត្តគោលនយោបាយនេះប្រកបដោយប្រសិទ្ធភាព ដើម្បីអត្ថប្រយោជន៍ នៃសន្តិសុខ និងសុវត្ថិភាពថាមពលស្អាតនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងវិស័យកសិកម្មទាំងមូល។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងបន្តសម្របសម្រួល និងកៀរគរម្ចាស់ជំនួយនានាអំពីហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ និងការគាំទ្រវិស័យនេះ។

## ៥.២ ក្របខ័ណ្ឌគតិយុត្ត

ការអនុវត្តគោលនយោបាយនេះត្រូវអនុលោមតាមច្បាប់ និងក្របខ័ណ្ឌគតិយុត្តដែលមានជាធរមាន។ ក្រសួង/ទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាលកម្ពុជាអាចបង្កើតច្បាប់ និងបទប្បញ្ញត្តិថ្មីៗបន្ថែមសម្រាប់ជីវឧស្ម័នក្នុងករណីត្រូវការឬចាំបាច់។ ដើម្បីអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាន និងរៀបចំ ក្របខ័ណ្ឌគតិយុត្តដើម្បីសម្របសម្រួលការងារអនុវត្ត និងគ្រប់គ្រងដូចខាងក្រោម៖

- សេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតគណៈកម្មាធិការតម្រង់ទិសថ្នាក់ជាតិដើម្បីសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ន
- សេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ (NATWG) សម្រាប់ជួយដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០។ សេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការបន្ថែមភារកិច្ចដល់កម្មវិធីឡជីវឧស្ម័នជាតិក្នុងការទទួលបន្ទុកអភិបាលកិច្ចគ្រប់គ្រង និងសម្របសម្រួលក្នុងវិស័យនេះ
- សេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតកម្មវិធីឡជីវឧស្ម័នថ្នាក់ខេត្តដើម្បីគ្រប់គ្រងសម្របសម្រួល និងអនុវត្តសកម្មភាពនៅថ្នាក់មូលដ្ឋានដើម្បីរួមចំណែកអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ន
- ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតមូលនិធិឡជីវឧស្ម័នដើម្បីគាំទ្រដល់វិស័យជីវឧស្ម័ន។

## ៥.៣ ហិរញ្ញវត្ថុ

ថវិកា ជាតិ ដែល មាន ប្រភព ពី រាជរដ្ឋា ភិបាល កម្ពុជា នឹង ក្លាយ ជា ប្រភព ហិរញ្ញវត្ថុដ៏សំខាន់សម្រាប់អនុវត្តន៍សកម្មភាពជាក់ស្តែង ដូចមានកំណត់ក្នុងផែនការសកម្មភាព ដែលនឹងធ្វើឡើងតាមរយៈយន្តការថវិកាកម្មវិធីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រសួងនឹងទទួលបន្ទុកដោះស្រាយបញ្ហាទាក់ទងនឹងហិរញ្ញប្បទាន យោងតាមចក្ខុវិស័យនៃគោលនយោបាយនេះ។ជាមួយគ្នានេះដែរហិរញ្ញវត្ថុក៏នឹងត្រូវបានកៀរគរពីដៃគូអភិវឌ្ឍន៍វិស័យឯកជន និងប្រភពស្របច្បាប់ផ្សេងទៀតផងដែរ។

លើសពីនេះទៅទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងបង្កើតមូលនិធិឡជីវឧស្ម័នដើម្បីគាំទ្រដល់វិស័យនេះក្នុងការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ដែលធ្វើឡើងក្នុងក្របខ័ណ្ឌរបស់អង្គភាពទទួលបន្ទុកជីវឧស្ម័ន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើកទឹកចិត្តដល់ការចូលរួមវិភាគទានថវិកាសម្រាប់មូលនិធិឡជីវឧស្ម័នពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនពាក់ព័ន្ធ និងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព។

នៅថ្នាក់មូលដ្ឋាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ត្រូវបង្កើនការផ្សព្វផ្សាយទៅគណៈអភិបាលខេត្ត-ក្រុង ស្រុក-ខណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ រួមទាំងមន្ទីរនិងអ្នកពាក់ព័ន្ធ អំពីអត្ថប្រយោជន៍ដែលបានពីឡជីវឧស្ម័ន នឹងលើកទឹកចិត្តឱ្យមានការវិភាជន៍ថវិកាវិនិយោគឃុំសង្កាត់ប្រចាំឆ្នាំ ដោយដាក់គោលដៅសាងសង់ឡជីវឧស្ម័នយ៉ាងតិចមួយឡក្នុងមួយឆ្នាំនៅឃុំ/សង្កាត់នីមួយៗ។

លើសពីនេះទៀត អង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័ននឹងសម្របសម្រួលជាមួយធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងវិនិយោគិនដែលគិតគូរពីផលប៉ះពាល់ដល់បរិស្ថាននិងសង្គម ដើម្បីប្រមូលមូលធនសម្រាប់ការសាងសង់ឡជីវឧស្ម័ននៅតាមកសិដ្ឋាន កសិធុរកិច្ច និងសត្តឃាតដ្ឋានជាដើម។

ការអភិវឌ្ឍន៍ឡជីវឧស្ម័នប្រកបដោយចីរភាពក្នុងរយៈពេលមធ្យម ហិរញ្ញប្បទានកាបូន គឺជាប្រភពដ៏សំខាន់នៃ យុទ្ធសាស្ត្រហិរញ្ញវត្ថុសម្រាប់វិស័យនេះ ដោយមានការសហការជាមួយដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធ និងក្រសួងបរិស្ថាន អង្គភាពទទួលបន្ទុកអភិបាលកិច្ចនេះនឹងស្វះស្វែងរកជម្រើសហិរញ្ញវត្ថុកាបូនផ្សេងទៀត និង/ឬពីហិរញ្ញវត្ថុអាកាសធាតុ។

## ៥.៤ ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍ ធនធាន មនុស្ស គឺ ជា ធាតុ ចូល ដ៏ សំខាន់ មួយ ដើម្បី ចូល រួម សម្រេច ឱ្យ បាន នូវ ចក្ខុវិស័យ គោលនយោបាយនេះ។ កម្មវិធីឡជីវឧស្ម័នជាតិ (NBP) វិទ្យាស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVETs) មជ្ឈមណ្ឌលបច្ចេកវិទ្យានិងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) ព្រមទាំងសាកលវិទ្យាល័យពាក់ព័ន្ធនានាត្រូវរៀបចំវគ្គបណ្តុះបណ្តាលទស្សនកិច្ចសិក្សា សន្និសីទ កម្មសិក្សា និងការស្រាវជ្រាវបែបទ្រឹស្តី និងអនុវត្តន៍ជាក់ស្តែង ដើម្បីផ្តល់បច្ចេកទេស បទពិសោធន៍ថ្មីៗដល់ជាងសាងសង់ ព្រមទាំងទ្រឹស្តីដើម្បីកែលម្អជំនាញ និងផលិតភាពរបស់ជាងសាងសង់ អ្នកបច្ចេកទេស និងវិស្វករ រួមទាំងបង្កើតបទដ្ឋានបច្ចេកទេស និងផលិតផលឱ្យស្របតាមតម្រូវការ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសអង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័នមានភារកិច្ចដូចខាងក្រោម៖

- រៀបចំវាយតម្លៃតម្រូវការបណ្តុះបណ្តាលសមត្ថភាពសម្រាប់អ្នកជំនាញបច្ចេកទេស ម្ចាស់កសិដ្ឋាន អតិថិជនឡជីវឧស្ម័ន និងអ្នកពាក់ព័ន្ធផ្សេងទៀត
- សម្របសម្រួល និងសហការក្នុងកម្មវិធីហាត់ការប្រចាំឆ្នាំសម្រាប់និស្សិតសាកលវិទ្យាល័យនិងសិស្សវិជ្ជាជីវៈ ដោយមានកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនព្រមទាំងបង្កើនការចូលរួមរបស់និស្សិតស្រីឱ្យបានដល់៣០%
- កៀរគរ និងរៀបចំធនធានហិរញ្ញវត្ថុសម្រាប់កម្មវិធីបណ្តុះបណ្តាលដែលទាក់ទងនឹងការអភិវឌ្ឍឡជីវឧស្ម័ន
- រៀបចំ និងអនុវត្តផែនការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេស និងអ្នកពាក់ព័ន្ធលើបច្ចេកទេស ឡជីវឧស្ម័នគ្រួសារ ជាពិសេសកម្មវិធីបណ្តុះបណ្តាលដែលបានកំណត់ក្នុងកម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ
- សម្របសម្រួល និងសហការរៀបចំអភិវឌ្ឍកម្មវិធីសិក្សា និងមុខវិជ្ជាសិក្សាស្តីពីឡជីវឧស្ម័នសម្រាប់វិទ្យាស្ថានអប់រំនានា និងគ្រឹះស្ថានបណ្តុះបណ្តាលកសិកម្ម (សាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានជាតិកសិកម្មព្រែកលៀបនិងវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម ។ល។) ដោយកិច្ចសហការជិតស្និទ្ធជាមួយមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC)
- រៀបចំ និងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិក្នុងវិស័យជីវឧស្ម័ន
- បង្កើតកម្មវិធីផ្សព្វផ្សាយនានាដើម្បីពង្រឹងសមត្ថភាពដល់ភ្នាក់ងារសាងសង់ឡជីវឧស្ម័ន ក្រុមហ៊ុនឡជីវឧស្ម័ននឹង រៀបចំទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ក្នុងចំណោមភ្នាក់ងារសាងសង់ឡជីវឧស្ម័នដូចគ្នា និងអ្នកផ្សេងទៀតដែលមិនមែនជាអ្នកអនុវត្តជាមួយកម្មវិធីឡជីវឧស្ម័នជាតិ
- បណ្តុះបណ្តាលក្រុមហ៊ុនឡជីវឧស្ម័ន និងភ្នាក់ងារសាងសង់ឡជីវឧស្ម័នលើជំនាញធុរកិច្ច និងជួយសម្របសម្រួលអ្នកដែលមានសក្តានុពលឱ្យក្លាយជាក្រុមហ៊ុនចុះបញ្ជីត្រឹមត្រូវ។

## ៥.៥ ការអនុវត្តគោលនយោបាយ

ការអភិវឌ្ឍវិស័យឡជីវឧស្ម័នទាក់ទងយ៉ាងជិតស្និទ្ធជាមួយវិស័យកសិកម្មទាំងមូលដូច្នេះគោលនយោបាយនេះ នឹងត្រូវតែស្របនឹងយុទ្ធសាស្ត្រថ្នាក់ជាតិ និងគោលនយោបាយអភិវឌ្ឍន៍វិស័យនានាដែលពាក់ព័ន្ធ ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមកសំដៅប្រសិទ្ធភាពនៃការអនុវត្ត។

### *៥.៥.១ ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន*

#### *១. ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័នគ្រួសារ*

ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទតាមរយៈអង្គភាពទទួលបន្ទុកអភិបាលកិច្ចនឹងបន្តជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័នគ្រួសារ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនដោយ អញ្ជ្រើញ ដើម្បី បង្កើន ការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ននៅតំបន់ជនបទ។ អង្គភាពទទួលបន្ទុកអភិបាលកិច្ចត្រូវ ផ្តោតលើកត្តាដូចខាងក្រោម៖

- ក) ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័នគ្រួសារដើម្បីកាត់បន្ថយការចម្លងជម្ងឺសត្វ ជម្ងឺស៊ូណូស និងជម្ងឺរុក្ខជាតិ។
- ខ) ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័នគ្រួសារដើម្បីកាត់បន្ថយការពឹងផ្អែកលើធនធានព្រៃឈើដែលគ្មានចីរភាព កាត់បន្ថយចំណាយលើឧស្ម័នធម្មជាតិ និងបង្កើនគុណភាពខ្យល់ក្នុងអគារ។
- គ) ពង្រឹងការផ្សព្វផ្សាយឡជីវឧស្ម័នដល់កសិករតាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី/ខេត្ត ឱ្យពួកគាត់យល់ដឹងអំពីអត្ថប្រយោជន៍ និងបច្ចេកវិទ្យាឡជីវឧស្ម័ន។
- ឃ) អនុញ្ញាតឱ្យក្រុមហ៊ុន និងភ្នាក់ងារសាងសង់ឡអាចដំឡើងឡជីវឧស្ម័នតាមបច្ចេកវិទ្យាប្រភេទផ្សេងៗគ្នាក្រៅពីប្រភេទបច្ចេកវិទ្យាដែលបានផ្តត់ផ្គង់ដោយកម្មវិធីឡជីវឧស្ម័នជាតិ បើបច្ចេកវិទ្យានោះបំពេញតាមបទដ្ឋានបច្ចេកទេសសំណង់ឡជីវឧស្ម័នដែលទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឬអង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័ន។
- ង) ធានាថាការផ្សព្វផ្សាយ និងការបង្កើនកម្រិតយល់ដឹងត្រូវបានអនុវត្តនៅគ្រប់កម្រិតទាំងអស់ដោយដាក់បញ្ចូលឡជីវឧស្ម័នទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់។
- ច) ធានាឱ្យឡជីវឧស្ម័ននៅបន្តប្រើប្រាស់យូរអង្វែងដោយកែលម្អសេវាកម្មក្រោយពេលសាងសង់និងបង្កើតមធ្យោបាយទំនាក់ទំនងនានា ដើម្បីផ្តល់ព័ត៌មានអំពីឡជីវឧស្ម័ន។
- ឆ) ប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធជីវឧស្ម័ននៅទូទាំងប្រទេសរបស់កម្មវិធីឡជីវឧស្ម័នជាតិ ក្នុងការជំរុញ និងការផ្សព្វផ្សាយអំពីជីវឧស្ម័ន។

### ២. ជំរុញការវិនិយោគឡជីវឧស្ម័នខ្នាតតូច មធ្យម និងធំ ដែលអាចទុកចិត្តបាននៅកសិដ្ឋានចិញ្ចឹមសត្វ និងឧស្សាហកម្មកែច្នៃកសិផល

ឡជីវឧស្ម័នខ្នាតតូច មធ្យម និងធំ អាចជាដំណោះស្រាយឆ្លើយតបនឹងបញ្ហាជាច្រើន ដែលកសិដ្ឋាន ឬរោងចក្រកែច្នៃកសិផលទាំងឡាយកំពុងប្រឈម ក្នុងការធ្វើប្រព្រឹត្តកម្មសំណល់រាវ ដើម្បីបង្ការអឺត្រូពីកាស្យុង[34] ការទប់ស្កាត់ក្លិនស្អុយដូចដែលចែងក្នុងប្រកាសលេខ៥៤៩ និងដោះស្រាយថ្លៃដំណើរការខ្ពស់។ ដើម្បីជំរុញការសាងសង់ និងប្រើប្រាស់ ជីវឧស្ម័ននៅតាមមូលដ្ឋានខាងលើ អង្គភាពទទួលបន្ទុកអភិបាលកិច្ច ត្រូវផ្តោតលើកត្តាដូចខាងក្រោម៖

ក) បង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃឡជីវឧស្ម័ន ក្នុងការធ្វើឱ្យប្រតិបត្តិការអាជីវកម្ម និងបរិស្ថានប្រសើរឡើងព្រមទាំងអត្ថប្រយោជន៍ដទៃទៀតទៅធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុវិនិយោគិន និងកសិករជាដើម។

ខ) ជំរុញការប្រើប្រាស់ឡជីវឧស្ម័នឱ្យក្លាយជាដំណោះស្រាយក្នុងការគ្រប់គ្រងសំណល់កសិកម្ម (សត្វ និងដំណាំ) ប្រកបដោយនិរន្តរភាព និងជាកាលានុវត្តភាពដើម្បីកាត់បន្ថយថ្លៃដើមប្រតិបត្តិការក្នុងការពង្រីកឧស្សាហកម្មបសុសត្វ និងកសិឧស្សាហកម្មស្របតាមគោលនយោបាយ ផែនការ និងគោលដៅរបស់វិស័យកសិកម្ម។

គ) ជំរុញការប្រើប្រាស់ឡជីវឧស្ម័នខ្នាតតូច មធ្យម និងខ្នាតធំ ដោយរៀបចំរបាយការណ៍ចង្អុលផ្លូវ (White Paper) ដែលបង្ហាញនូវបច្ចេកវិទ្យា និងជូនដំណឹងដល់ស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍អំពីផលចំណេញផ្នែក សេដ្ឋកិច្ចសំខាន់ៗដែលកសិដ្ឋានចិញ្ចឹមសត្វបែបពាណិជ្ជកម្មអាចទទួលបាននៅពេលប្រើប្រាស់ ជីវឧស្ម័ន។

ឃ) ជំរុញការធ្វើពាណិជ្ជូបនីយកម្មលើសំណល់ឡជីវឧស្ម័ន ដោយចាត់ទុកជាប្រភពចំណូលមួយផ្សេងទៀតសម្រាប់អ្នកវិនិយោគក្នុងឡជីវឧស្ម័នខ្នាតតូច មធ្យម និងធំ។

ង) ជំរុញនិងលើកទឹកចិត្តកសិករដែលប្រើប្រាស់ឡជីវឧស្ម័ន និងបង្កើតជាសហគមន៍ ដែលអនុវត្តវិធានការចម្រុះគ្រប់គ្រងដំណាំ និងកសិកម្មសរីរាង្គដោយភ្ជាប់ឡជីវឧស្ម័នដើម្បីដាំដំណាំ។

### ៣. ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន នៅតាមសត្តឃាតដ្ឋាន

ការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យចិញ្ចឹមសត្វ ក៏មានន័យថា សត្តឃាតដ្ឋានបញ្ចេញសំណល់កាន់តែច្រើនផងដែរ។ សំណល់នៅសត្តឃាតដ្ឋានភាគច្រើនមិនបានគ្រប់គ្រងឱ្យបានត្រឹមត្រូវនោះទេ ដែលបណ្តាលឱ្យមានការបំពុលបរិស្ថាន ការបង្កជំងឺដោយរុយ និងមានក្លិនស្អុយផងដែរ។ ដើម្បីចូលរួមដោះស្រាយបញ្ហានេះ អង្គភាពទទួលបន្ទុកអភិបាលកិច្ចមានភារកិច្ចដូចខាងក្រោម៖

ក) រៀបចំបទប្បញ្ញត្តិអប្បបរមា ស្តី ពី ការ គ្រប់គ្រង សំណល់ ចេញ ពី សត្តឃាតដ្ឋាន ឱ្យស្របតាមអនុក្រឹត្យ ១០៨និងប្រកាសលេខ២២៥និងពិចារណាពីការដាក់កំហិតឱ្យសាងសង់ឡជីវឧស្ម័ន ដើម្បីធ្វើប្រព្រឹត្តកម្មសំណល់ចេញពីសត្តឃាតដ្ឋាន និងទាញយកថាមពលមកប្រើប្រាស់ឡើងវិញ។

---

*[34] ជាកំណើននៃសារធាតុចិញ្ចឹមនៅក្នុងទឹក ដែលបណ្តាលអោយឱ្យសារាយលូតលាស់យ៉ាងច្រើន និងឆាប់រហ័ស។ នៅពេលរលួយសារាយស្រូបយកអុកស៊ីសែនរលាយក្នុងទឹកនូវបរិមាណដ៏ច្រើន ធ្វើអោយខូចគុណភាពទឹក ប៉ះពាល់ដល់ជីវិតរបស់ត្រីនិងភាវៈរស់ក្នុងទឹកដទៃទៀត។*

ខ) បង្កើនការយល់ដឹងអំពីការប្រើប្រាស់ឡជីវឧស្ម័ន ដែលជាដំណោះស្រាយសម្រាប់ការគ្រប់គ្រងសំណល់ចេញពីសត្តឃាតដ្ឋាន រួមទាំងបង្កើនកម្រិតយល់ដឹងអំពីអត្ថប្រយោជន៍នៃការប្រើជីវឧស្ម័នផងដែរ។

គ) អភិវឌ្ឍបច្ចេកវិទ្យាឡជីវឧស្ម័នសមស្របតាមទំហំសត្តឃាតដ្ឋានផ្សេងៗគ្នា ដោយសហការជាមួយកម្មវិធីឡជីវឧស្ម័នជាតិ មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) និងភាគីឯកជននានារួមទាំងវិធានការដែលតម្រូវឱ្យប្រើប្រាស់ជីវឧស្ម័នទាំងអស់ និងការទុកដាក់ព្រមទាំងការប្រើប្រាស់សំណល់ឡជីវឧស្ម័នផងដែរ។

## *៥.៥.២ ជំរុញអភិបាលកិច្ច ការសម្របសម្រួល និងការធ្វើរបាយការណ៍*

ទីផ្សារឡជីវឧស្ម័នកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័សនៅកម្ពុជា តាមរយៈគម្រោង និងកម្មវិធីផ្សេងៗគ្នាដែលមានយន្តការអនុវត្តន៍ឧបត្ថម្ភធន យន្តការគ្រប់គ្រងគុណភាព និងកម្រិតខុសៗគ្នានៃសេវាកម្មក្រោយពេលសាងសង់។ ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យនេះក្នុងល្បឿនដូចដែលចង់បាន ដោយមានកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងត្រូវអនុវត្តវិធានខាងក្រោម៖

១. បន្ថែមភារកិច្ចដល់កម្មវិធីឡជីវឧស្ម័នជាតិដើម្បីទទួលបន្ទុកអភិបាលកិច្ចដែលនៅក្រោមការគ្រប់គ្រង និងចង្អុលបង្ហាញ របស់គណៈកម្មាធិការតម្រង់ទិសថ្នាក់ជាតិ ដោយមានការទទួលខុសត្រូវដូចខាងក្រោម៖
   - ក) បង្កើតនិងជំរុញការអនុវត្តគោលនយោបាយគាំទ្រជីវឧស្ម័ន ដែលរាប់បញ្ចូលទាំងបទដ្ឋានបច្ចេកទេសសម្រាប់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ការត្រួតពិនិត្យអនុលោមភាព និងអធិការកិច្ចបទដ្ឋានបច្ចេកទេស។
   - ខ) សម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាល(ឬស្ថាប័នរដ្ឋ) ជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។
   - គ) ត្រួតពិនិត្យនិងធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃកម្មវិធីជីវឧស្ម័នរបស់ខ្លួន និងដៃគូដទៃទៀត។
   - ឃ) សម្របសម្រួលលើការស្នើសុំ លើកលែងពន្ធសម្រាប់ឧបករណ៍ និងបរិក្ខារជីវឧស្ម័ន
   - ង) គ្រប់គ្រង និងចាត់ចែងការឧបត្ថម្ភធនសម្រាប់ វិស័យជីវឧស្ម័ន
   - ច) សម្របសម្រួលជាមួយក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងបរិស្ថាន ស្តីពីជីវឧស្ម័ន ថាមពលកកើតឡើងវិញ និងការប្រែប្រួលអាកាសធាតុ។ល។

២. ធានានូវការប្រកួតប្រជែងក្នុងទីផ្សារស្ថិតក្រោមការគ្រប់គ្រង ដែលលក្ខខណ្ឌនៃការឧបត្ថម្ភធន និងពន្ធដារក្នុងកម្រិតប្រហាក់ប្រហែលសម្រាប់ក្រុមហ៊ុនសាងសង់ ផ្គត់ផ្គង់ជីវឧស្ម័នទាំងអស់។

៣. ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលនិងកិច្ចសន្ទនារវាងភាគីពាក់ព័ន្ធនានាដោយផ្តួចផ្តើមនូវការបង្កើតសហគមន៍/សមាគមជីវឧស្ម័ន ។

៤. សហការជាមួយមជ្ឈមណ្ឌលឯកទេសដែលមានស្រាប់ក្នុងស្រុក ដូចជាមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) ដើម្បីអនុវត្តសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ ព្រមទាំងសេវាកម្មពិគ្រោះយោបល់ក្នុងគោលបំណងជំរុញការអភិវឌ្ឍឧស្សាហកម្មជីវឧស្ម័ននៅក្នុងប្រទេស។

៥. ជូនដំណឹងភ្ជាប់នឹងការបណ្តុះបណ្តាលក្រុមហ៊ុនឡជីវឧស្ម័ន អំពីគោលនយោបាយនិងបទប្បញ្ញត្តិពាក់ព័ន្ធ។

៦. បង្កើតប្រព័ន្ធព័ត៌មានស្តីពីបច្ចេកទេសសាងសង់ និងប្រតិបត្តិការនៃឡជីវឧស្ម័ន និងផ្សព្វផ្សាយទៅបណ្តាអ្នកពាក់ព័ន្ធទូទាំងប្រទេស ដោយសហការជាមួយ មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) សម្រាប់អាងប្រព្រឹត្តិកម្មជីវឧស្ម័ន ខ្នាតតូច មធ្យម និងធំ។

៧. បង្កើតមូលដ្ឋានទិន្នន័យជាតិ ដែលគ្របដណ្តប់គ្រប់សកម្មភាពជីវឧស្ម័នទាំងអស់ ដើម្បីតាមដានការអនុវត្តគោលនយោបាយនេះរួមទាំងការរៀបចំរបាយការណ៍។

### *៥.៥.៣ លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធគុណភាពឡជីវឧស្ម័ន*

ចរិតលក្ខណៈមួយសម្រាប់សម្គាល់ទីផ្សារដែលដំណើរការល្អ គឺការប្រកួតប្រជែងគ្នាក្នុងចំណោមក្រុមហ៊ុន។ ទោះយ៉ាងណាក៏ដោយ គេត្រូវការបទប្បញ្ញត្តិនិងបទដ្ឋានបច្ចេកទេស ដើម្បីធានាគុណភាពរបស់ផលិតផលនិងសេវាកម្មកាន់តែល្អប្រសើរ។ ក្នុងទិសដៅនេះ អង្គភាពទទួលបន្ទុកអភិបាលកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងផ្តោតជាសំខាន់លើការអនុវត្តវិធានការយុទ្ធសាស្ត្រចំនួន៥ គឺ៖

១. រៀបចំ និងអនុវត្តបទដ្ឋានបច្ចេកទេសឡជីវឧស្ម័នឱ្យមានប្រសិទ្ធភាព ដោយបទដ្ឋានបច្ចេកទេសនេះត្រូវមានភាពច្បាស់លាស់ និងធានាលើគុណភាពសំណង់ សម្ភារឧបករណ៍បំពាក់ឡ ការប្រើប្រាស់ជីវឧស្ម័ន និងការបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់គ្រប់ប្រភេទ/ខ្នាតនៃឡជីវឧស្ម័នទាំងអស់។

២. រៀប ចំ យុទ្ធសាស្ត្រ អភិវឌ្ឍន៍ បទដ្ឋាន បច្ចេកទេស ឡជីវឧស្ម័ន រួម មួយ សម្រាប់ គ្រប់ ប្រភេទ/ ខ្នាត នៃឡជីវឧស្ម័នក្នុងវិស័យកសិកម្មទាំងមូល។

៣. ធ្វើអធិការកិច្ច ដើម្បីធានាបាននូវគុណភាពនៃឡជីវឧស្ម័ន ដោយប្រើប្រាស់បទដ្ឋានបច្ចេកទេស និងរៀបចំយន្តការផ្តល់វិញ្ញាបនបត្រដល់ ភ្នាក់ងារសាងសង់ឡជីវឧស្ម័នឱ្យប្រែក្លាយជាសហគ្រិន។

៤. លើកទឹកចិត្តដល់ការប្រើប្រាស់បទដ្ឋានបច្ចេកទេសឡជីវឧស្ម័នដើម្បី អភិវឌ្ឍន៍ធុរកិច្ចក្នុងវិស័យជីវឧស្ម័នឱ្យកាន់ តែល្អប្រសើរឡើង។

៥. បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពក្រុមបច្ចេកទេសនិងក្រុមអធិការកិច្ចដើម្បីត្រួតពិនិត្យតាមដាន និងវាយតម្លៃ ការអនុវត្តបទដ្ឋានបច្ចេកទេសឡជីវឧស្ម័ន។

### *៥.៥.៤ យន្តការគាំទ្រសារពើពន្ធ និងមិនមែនសារពើពន្ធ*

#### *៥.៥.៤.១ ឡជីវឧស្ម័នគ្រួសារ*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងបន្តគាំទ្រវិស័យឡជីវឧស្ម័នតាមវិធានការយុទ្ធសាស្ត្រដូចខាងក្រោម៖

១. វាយតម្លៃឡើងវិញនូវតម្រូវការនិងទំហំនៃការឧបត្ថម្ភធនចំពោះឡជីវឧស្ម័នគ្រួសារដោយផ្អែកលើគោលការណ៍ហិរញ្ញវត្ថុនិងសេដ្ឋកិច្ចក្នុងការផ្តល់ការឧបត្ថម្ភធនដែលមានភាពសមរម្យព្រមទាំងរៀបចំបង្កើតគោលការណ៍ណែនាំស្តីពីកម្រិតឧបត្ថម្ភធន[៣៥]និងអាចមានករណីលើកលែងសម្រាប់ក្រុមងាយរងគ្រោះ។

---

[៣៥] *សំដៅលើរយៈពេលសងត្រលប់និងអត្រាផលចំណេញផ្ទៃកហិរញ្ញវត្ថុសមរម្យ (financial internal rate of return and pay-back period)*

២. ប្រើប្រាស់ចំណូលពីឥណទានកាបោនសម្រាប់ការឧបត្ថម្ភធនក្នុងរយៈពេលខ្លី ឬមធ្យម ករណីមូលនិធិពីដៃគូអភិវឌ្ឍន៍នានាត្រូវបានកាត់បន្ថយ។

៣. សម្របសម្រួលលើការស្នើសុំការលើកលែងអាករលើតម្លៃបន្ថែមសម្រាប់ក្រុមហ៊ុនសាងសង់ឡជីវឧស្ម័នគ្រួសារជាពិសេសការលើកលែងពន្ធនាំចូលចំពោះ
វត្ថុធាតុដើមសម្រាប់ការសាងសង់ឡចង្ក្រាន និងម៉ាស៊ីនភ្លើងប្រើជីវឧស្ម័ន ឧបករណ៍កត់ត្រា (Pay As You Go) ដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម។

៤. បង្កើនកិច្ចសហប្រតិបត្តិការជាមួយធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងវិនិយោគិនដែលគិតពីផលប៉ះពាល់ផ្នែកសង្គមនិងបរិស្ថានដើម្បីផ្តល់ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបដល់កសិករ និងអ្នកពាក់ព័ន្ធក្នុងវិស័យឡជីវឧស្ម័ន។ ការប្រើប្រាស់មូលនិធិឡជីវឧស្ម័នដើម្បីបង្កើតកម្ចីថ្មីៗសម្រាប់ការងារជីវឧស្ម័នដូចជា ភតិសន្យាឈានទៅធ្វើជាម្ចាស់កម្មសិទ្ធិ សម្រាប់ការបង់ប្រាក់នៅពេលប្រើប្រាស់ (Pay As You Go) និងគំរូហិរញ្ញប្បទានដែលមាននវានុវត្តន៍ផ្សេងៗទៀត។

### *៥.៥.៤.២ ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម និងធំ*

យន្តការ ខាងក្រោមនឹងអនុវត្តដើម្បីគាំទ្រដល់ការប្រើប្រាស់ឡ/អាងប្រព្រឹត្តិកម្មជីវឧស្ម័នជីវឧស្ម័ន ៖

១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងសហការជាមួយក្រសួងរ៉ែ និងថាមពល ជាពិសេសអាជ្ញាធរអគ្គិសនីកម្ពុជា ក្នុង ការ អភិវឌ្ឍ គោលនយោបាយ ថ្លៃលក់ អគ្គិសនី សម្រាប់អគ្គិសនីដែលផលិតថាមពលកកើតឡើងវិញក្នុងតម្លៃសមរម្យ ឬអនុញ្ញាតឱ្យលក់អគ្គិសនីពីជីវឧស្ម័នទៅគ្រួសារឬសហគមន៍ដែលនៅក្បែរនោះដោយផ្ទាល់ក្នុងតម្លៃដូចគ្នានឹងអត្រាដែលផ្គត់ផ្គង់ដោយសេវាករអគ្គិសនីឯកជន និង/ឬរដ្ឋនៅមូលដ្ឋាន។

២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងសហការជាមួយក្រសួងបរិស្ថាន រួមទាំងក្រសួងពាក់ព័ន្ធនានា ដើម្បីជំរុញនិងសម្របសម្រួលដំណើរការវាយតម្លៃផលប៉ះពាល់សង្គមនិងបរិស្ថានសម្រាប់កសិដ្ឋានចិញ្ចឹមសត្វខ្នាតតូច មធ្យម និងធំ និងរោងចក្រកែច្នៃកសិផល ដើម្បីដោះស្រាយបញ្ហាប្រឈមនឹងការគ្រប់គ្រងសំណល់ ការបំពុល និងផលប៉ះពាល់លើសុខភាព និងសុខុមាលភាពរបស់ប្រជាជនដែលកំពុងរស់នៅក្នុងតំបន់នោះ។

៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសម្របសម្រួលលើការស្នើសុំការលើកលែងអាករលើតម្លៃបន្ថែមសម្រាប់ក្រុមហ៊ុនដែលដំឡើងឡ/អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម និងធំ ជាពិសេសពន្ធនាំចូលវត្ថុធាតុដើមសម្រាប់ការសាងសង់ (ឧទាហរណ៍ កៅស៊ូប៉ូលីអេទីឡែន (HDPE) កៅស៊ូក្រាល (Geotextile) និងបរិក្ខារ (ចង្ក្រាន ម៉ាស៊ីនភ្លើងប្រើជីវឧស្ម័ន ម៉ាស៊ីនបូមទឹកប្រើជីវឧស្ម័ន ឧបករណ៍កត់ត្រា (Pay As You Go) ឧបករណ៍ ដកយកឧស្ម័ន $H_2S$ និងសារធាតុចាប់យក $H_2S$។ល។) ដើម្បីកាត់បន្ថយថ្លៃដើមសាងសង់ឡជីវឧស្ម័ន។

៤. សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុដើម្បីផ្តល់កម្ចីក្នុងអត្រាការប្រាក់ទាបដល់កសិករ និងក្រុមហ៊ុនសាងសង់ឡ។

### ៥.៥.៥ បង្កើតនិងជំរុញសហគមន៍អ្នកប្រើប្រាស់ឡជីវឧស្ម័ន

សហគមន៍ អ្នក ប្រើប្រាស់ ឡជីវឧស្ម័នគ្រួសារ ជាមូលដ្ឋានគ្រឹះដើម្បីទទួលបាននូវព័ត៌មានចំណេះដឹងអំពីបច្ចេកវិទ្យា និងបទពិសោធន៍ទាក់ទងនឹងការអភិវឌ្ឍឡជីវឧស្ម័ន។ ការរៀបចំភ្ជាប់ម្ចាស់ឡជីវឧស្ម័ននៅមូលដ្ឋានតាមបណ្តាញទាំងនេះក៏នឹងជួយការពារពួកគេនៅចំពោះមុខក្រុមហ៊ុនសាងសង់។ ដូច្នេះអង្គភាពទទួលបន្ទុកអភិបាលកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹង៖

១. រៀបចំបណ្តាញអ្នកប្រើប្រាស់ឡជីវឧស្ម័ន

២. គាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុក្នុងការបង្កើតសហគមន៍អ្នកប្រើប្រាស់ឡជីវឧស្ម័ន

៣. បង្កើនការគាំទ្រជំនាញបច្ចេកវិទ្យាលើការប្រើប្រាស់ឡជីវឧស្ម័នដោយភ្ជាប់ពួកគេទៅនឹងជាងសាងសង់ឡដែលបានបណ្តុះបណ្តាលត្រឹមត្រូវឬក្រុមហ៊ុនសាងសង់ឡជីវឧស្ម័នដែលមាននៅក្នុងតំបន់នោះ

៤. ជំរុញការអនុវត្តប្រព័ន្ធកសិកម្មចម្រុះនៅក្នុងសហគមន៍ ដើម្បីបង្កើនផលិតកម្មសត្វ និងកសិកម្មសរីរាង្គ/សុវត្ថិភាព

### ៥.៥.៦ ជំរុញការស្រាវជ្រាវ អភិវឌ្ឍន៍ និងការប្រើប្រាស់ឡជីវឧស្ម័ន

ការស្រាវជ្រាវ និងអភិវឌ្ឍន៍លើការសាងសង់ និងប្រតិបត្តិការឡជីវឧស្ម័ន គឺជាធាតុផ្សំដ៏សំខាន់ដើម្បីលើកកម្ពស់គុណភាពកាត់បន្ថយការចំណាយ និងបង្កើនអត្ថប្រយោជន៍ពីឡជាអតិបរមា។ ដើម្បីសម្រេចបានគោលដៅនេះអង្គភាពទទួលបន្ទុកអភិបាលកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងផ្តោតលើការអនុវត្តលើវិធានការយុទ្ធសាស្ត្រចំនួន៤ ដូចខាងក្រោម៖

១. សហការជាមួយមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) លើការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឡជីវឧស្ម័នខ្នាតតូច មធ្យម និងធំ រួមទាំងឧបករណ៍ដកយកឧស្ម័ន $H_2S$ ម៉ាស៊ីនភ្លើង/ម៉ាស៊ីនបូមទឹកប្រើជីវឧស្ម័នការរចនាឡជីវឧស្ម័ននិងការប្រើប្រាស់ជីកាកសំណល់ឡជីវឧស្ម័ន។

២. ជំរុញការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងបង្កើតខ្សែច្រវាក់តម្លៃនៃជីកាកសំណល់ឡជីវឧស្ម័នជាពិសេសសម្រាប់កសិដ្ឋានខ្នាតតូច មធ្យម និងធំនិងឧស្សាហកម្មកែច្នៃកសិផលដើម្បីកាត់បន្ថយការពឹងផ្អែកលើជីនាំចូលការថែរក្សាវដ្តជីជាតិដី[៣៦] កែលម្អគុណភាពនិងជីវជាតិដី និងបង្កើនភាពធន់របស់ដីទល់នឹងការប្រែប្រួលអាកាសធាតុតាមរយៈថវិកាមូលនិធិឡជីវឧស្ម័ន។ ជំរុញជីកាកដើម្បីផលិតជីសរីរាង្គកាត់បន្ថយការប្រើប្រាស់ជីគីមី

[៣៦] ការថែរក្សាវដ្តជីជាតិដីជាការអនុវត្តកសិកម្មដែលប្រើប្រាស់សារធាតុចិញ្ចឹមទាំងអស់សាជាថ្មី ដោយបញ្ចូលសារធាតុចិញ្ចឹមសរីរាង្គទាំងនោះត្រលប់ទៅក្នុងស្រទាប់ដីវិញ។ ការអនុវត្តកសិកម្មរបៀបនេះជួយថែរក្សាសារធាតុចិញ្ចឹមនិងកម្រិតកាបោនដែលមានក្នុងស្រទាប់ដី ដែលធ្វើឱ្យការដាំដុះប្រព្រឹត្តទៅដោយនិរន្តភាព

៣. ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការប្រើប្រាស់ជីវឧស្ម័ន ដូចជាការបន្សុទ្ធជីវឧស្ម័នធ្វើជាឥន្ធនៈយានជំនិះ ឥន្ធនៈសម្រាប់ឡចំហាយ ឬច្រកជាកំប៉ុង/ធុងសម្រាប់ជាឥន្ធនៈចម្អិនអាហារ និងផ្សព្វផ្សាយបច្ចេកវិទ្យាថ្មី ដែលបានកែលម្អទៅដល់ភាគីពាក់ព័ន្ធនៅក្នុងវិស័យឯកជន។

### ៥.៥.៧ បង្កើនការវិភាជន៍ថវិកាទៅអគ្គនាយដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីអភិវឌ្ឍន៍ជីវឧស្ម័ន

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបន្តការកៀរគរធនធានដើម្បីធានាការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា និងគ្រោងបង្កើនធនធានហិរញ្ញវត្ថុ រួមទាំងការវិភាជន៍ថវិកា ពី៤%ទៅ ១០% នៃថវិកាជាតិសម្រាប់អនុវិស័យសុខភាពសត្វនិងផលិតកម្មសត្វមុនឆ្នាំ២០៣០។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏នឹងលើកទឹកចិត្តដល់ដៃគូអភិវឌ្ឍន៍នានាឱ្យចូលរួមយ៉ាងផុសផុលក្នុងការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជាទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស។

### ៥.៥.៨ ការកៀរគរហិរញ្ញប្បទានអាកាសធាតុ

ការកៀរគរហិរញ្ញប្បទានកាបោនឬអាកាសធាតុ ជាវិធានការយុទ្ធសាស្ត្រថវិកាដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍន៍ ឡជីវឧស្ម័ន។ ការសាងសង់ឡជីវឧស្ម័នកាន់តែច្រើននឹងជួយកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានកាន់តែច្រើនទៅតាមនោះដែរ ដូច្នេះវានឹងផ្តល់នូវកាលានុវត្តភាពច្រើនជាងមុនក្នុងការចាប់យកហិរញ្ញប្បទានអាកាសធាតុផ្សេងៗ។ ទោះយ៉ាងណាក៏ដោយនេះមិនមែនមានន័យថាគ្រប់ឡជីវឧស្ម័នសុទ្ធតែត្រូវបានគ្រប់គ្រង និងប្រើប្រាស់បានត្រឹមត្រូវទាំងអស់នោះទេ ហើយក្នុងករណីខ្លះជីវឧស្ម័នត្រូវបានបញ្ចេញចោលទៅបរិយាកាស ដែលធ្វើឱ្យប៉ះពាល់អវិជ្ជមានដល់អាកាសធាតុទៅវិញ។ ដូច្នេះ វិធានការគោលនយោបាយខាងក្រោមនឹងត្រូវដាក់ចេញ៖

១. ជំរុញនិងចាត់ទុកការសាងសង់ឡជីវឧស្ម័នជាមធ្យោបាយដ៏មានប្រសិទ្ធភាព ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងបង្កើនភាពធន់នឹងអាកាសធាតុឱ្យស្របជាមួយរបាយការណ៍រួមចំណែករបស់កម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ(NDC)។

២. ជំរុញនូវការប្រើឧបករណ៍ដុតជីវឧស្ម័នដែលមិនបានប្រើប្រាស់ ដើម្បីបង្ការការបង្ហុយឧស្ម័នមេតានទៅក្នុងបរិយាកាស និងបង្កើនសុវត្ថិភាពដល់មនុស្ស/សត្វ។

៣. ជំរុញការប្រើប្រាស់ជីវឧស្ម័នឱ្យអស់លទ្ធភាព ដើម្បីបញ្ចៀសការបង្ហុយជីវឧស្ម័នដែលសល់មិនប្រើប្រាស់ទៅក្នុងបរិយាកាស ដោយអភិវឌ្ឍនិងផ្សព្វផ្សាយបច្ចេកវិទ្យាជីវឧស្ម័នបន្ថែមលើចង្ក្រាន និង/ឬលើកទឹកចិត្តឱ្យមានការចែករំលែកជីវឧស្ម័នដែលនៅសល់ជាមួយអ្នកជិតខាង ឬលក់អគ្គិសនីទៅឱ្យរោងចក្រកែច្នៃកសិផល ឬសេវាករ។

៤. ត្រូវគ្រប់គ្រងសំណល់ឡជីវឧស្ម័នដែលបានធ្វើប្រព្រឹត្តិកម្មរួចឱ្យបានត្រឹមត្រូវ ដើម្បីទប់ស្កាត់មិនឱ្យមានការប៉ះពាល់ដល់បរិស្ថានបន្តទៀត។ អង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័នជាតិនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នឹងបង្កើតគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសំណល់ឡជីវឧស្ម័ន។

៥. អង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័នជាតិនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នឹងជាអ្នកទទួលសិទ្ធិគ្រប់គ្រងឥណទានកាបោនសម្រាប់ឡជីវឧស្ម័ន ដែលបានសាងសង់ដោយម្ចាស់ជំនួយសាធារណៈ និងដៃគូអភិវឌ្ឍន៍នានានៅពេលដែលសិទ្ធិកាបោនត្រូវបានផ្ទេរ និងគួរជាអ្នកទទួលហិរញ្ញប្បទានអាកាសធាតុ។

៦. កម្មវិធីឡជីវឧស្ម័នជាតិត្រូវផ្សព្វផ្សាយ និងបណ្តុះបណ្តាលលើការប្រើប្រាស់និងការថែទាំឡជីវឧស្ម័ន គ្រួសារដល់កសិករជាម្ចាស់ឡ ដោយប្រើប្រាស់ថវិកាហិរញ្ញប្បទាន និងឥណទានកាបោន ។

៧. លើកកម្ពស់ការធ្វើទីផ្សារឥណទានកាបោន និងស្វែងរកទីផ្សារផ្សេងៗទៀតដើម្បីបង្កើនតម្លៃ និងប្រភព ហិរញ្ញវត្ថុដែលរួមមានទាំងទីផ្សារក្នុងស្រុកផងដែរ។ សហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយ ចីរភាព/ក្រសួងបរិស្ថានលើ ការ អនុវត្ត ផែនការ ជីវឧស្ម័ន នៅ ក្នុង របាយការណ៍ រួម ចំណែក របស់ កម្ពុជាក្នុងការឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុ(NDC)ដើម្បីទាក់ទាញហិរញ្ញប្បទានអាកាសធាតុ។

## ៦. ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃគោលនយោបាយ

ដើម្បីអនុវត្តគោលនយោបាយ អភិវឌ្ឍឡជីវឧស្ម័ន ប្រកប ដោយ ប្រសិទ្ធភាព ប្រព័ន្ធ ត្រួត ពិនិត្យ សម្រាប់ តាមដាន និងវាយតម្លៃវឌ្ឍនភាព និងលទ្ធផល នឹងត្រូវបានបង្កើតឡើង រួមមាន៖

- គោលដៅ និងគោលបំណង
- សូចនាករធៀបនឹងផែនការសកម្មភាព
- របាយការណ៍វឌ្ឍនភាព
- របាយការណ៍បង្ហាញពីសមិទ្ធផលអភិវឌ្ឍន៍ (គោលដៅដើមគ្រា និងចុងគ្រា)
- ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ
- ការវាយតម្លៃគោលនយោបាយចុងក្រោយ

ក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ (NATWG) នឹងទទួលខុសត្រូវលើការត្រួតពិនិត្យ វាយតម្លៃ និង សម្របសម្រួល កម្រិត គោលនយោបាយ អនុវត្ត ដោយ កម្មវិធីឡជីវឧស្ម័នជាតិ និងខេត្តដើម្បីធានាឱ្យមានសង្គតិភាព និងភាពបន្សុីនៃគោលនយោបាយនេះជាមួយគោលនយោបាយនិងយុទ្ធសាស្ត្រនានា។ គ្រប់ទិន្នន័យទាំងអស់ដែល បានប្រមូលសម្រាប់ធ្វើរបាយការណ៍នឹងត្រូវលម្អិតទៅតាមភេទដោយស្របទៅនឹងឯកសារណែនាំនៃគម្រោងបញ្ជ្រាប យេនឌ័រ របស់ក្រសួងកិច្ចការនារីឆ្នាំ២០០៥ ស្តីពីគោលនយោបាយឆ្លើយតបនឹងយេនឌ័រតាមវិស័យ។

មន្ត្រីផ្នែកត្រួតពិនិត្យនៃក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ(NATWG)នឹងមានតួនាទីជាន់ខ្ពស់ និង/ឬ ជាអ្នកជំនាញផ្នែកត្រួតពិនិត្យ និងវាយតម្លៃ (M&E) ដែលអាចចូលរួមគ្រប់សកម្មភាពទាំងអស់ និងអាចផ្តល់យោបល់ ឬគំនិតដើម្បីស្ថាបនា ក៏ដូចជាធាតុចូលសម្រាប់ដាក់ក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពបន្តទៀត។

ក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ (NATWG) នឹងរៀបចំផែនការត្រួតពិនិត្យតាមដាននិងវាយតម្លៃ ដែលប្រើប្រាស់សូចនាករគុណភាព SMART[៣៧] រួមមានសូចនាករសមិទ្ធកម្មសំខាន់ៗ (KPI)នៅក្នុងតារាងទី៤ និង សូចនាករសមិទ្ធកម្មនៅក្នុងឧបសម្ព័ន្ធ "ក" និង "ខ" ការរៀបចំវិធីសាស្ត្រ ការប្រមូលទិន្នន័យ មធ្យោបាយ នៃការផ្ទៀងផ្ទាត់ និងការធ្វើរបាយការណ៍បច្ចុប្បន្នភាពជូនប្រធានគណៈកម្មាធិការតម្រង់ទិស (NSC)និង/ឬ ក្រសួង/ ទីភ្នាក់ងារដែលពាក់ព័ន្ធ។ ក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ (NATWG) អាចជ្រើសរើសទីប្រឹក្សាផ្តល់ យោបល់ និងអ្នកជំនាញ ដើម្បីបង្កើតផែនការត្រួតពិនិត្យតាមដាននិងវាយតម្លៃ (M&E) និងសម្រួលសកម្មភាព ត្រួតពិនិត្យនានា។

---

[៣៧] *សូចនាករគុណភាព SMART សំដៅលើ Specific (ដែលជាក់លាក់) Measurable (អាចវាស់វែងបាន) Achievable (អាចធ្វើទៅរួច) Relevant (ដែលពាក់ព័ន្ធឬសំខាន់) និង Time-bound (មានបញ្ជាក់ពេលកំណត់)។*

ប្រព័ន្ធ រាយ ការណ៍ ស្តីពីប្រសិទ្ធភាព និង ប្រសិទ្ធផលនៃការប្រើប្រាស់ឡជីវឧស្ម័ននឹងត្រូវបានកំណត់យ៉ាងច្បាស់លាស់ដើម្បីណែនាំការអនុវត្តឱ្យស្របតាមវឌ្ឍនភាពនៃការអភិវឌ្ឍឡជីវឧស្ម័នជាសកល។ របាយការណ៍វឌ្ឍនភាព នឹង ត្រូវបានរៀបចំប្រចាំឆ្នាំ ប្រចាំ៥ឆ្នាំដោយអង្គភាពទទួលបន្ទុកអភិបាលកិច្ច។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តនឹងសហការជាចាំបាច់ក្នុងការវាយតម្លៃការអនុវត្តគោលនយោបាយនេះ។ អង្គភាពទទួលបន្ទុកអភិបាលកិច្ចនឹងពិនិត្យពិចារណានូវការប្រើប្រាស់យន្តការនៃការធ្វើរបាយការណ៍នៃមូលដ្ឋានទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ(ODA) ដែលគ្រប់គ្រងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) សម្រាប់បង្កើនតម្លាភាព[៣៨]។

របាយការណ៍សង្ខេបនឹងផ្សព្វផ្សាយនៅលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយព័ត៌មាននឹងចែករំលែកជាមួយក្រសួងបរិស្ថានសម្រាប់តាមដានការអនុវត្តការចូលរួមចំណែករបស់កម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (NDC)។ បន្ថែមពីនេះព័ត៌មានក៏នឹងបានចែករំលែកជាមួយក្រសួង ផែនការសម្រាប់តាមដានការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDG) ឧទាហរណ៍គោលដៅទី៧.១.២ ស្តីពីការពឹងអាស្រ័យលើឥន្ធនៈស្អាតនិងបច្ចេកវិទ្យា ព្រមទាំងគោលដៅផ្សេងៗទៀតដែរ។

នាយកដ្ឋានផែនការ និងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងមានតួនាទីសំខាន់ក្នុងការសម្របសម្រួល ប្រមូលផ្តុំទិន្នន័យដែលលម្អិតតាមប្រភេទ និងការអនុវត្តការងារត្រួតពិនិត្យនិងវាយតម្លៃយ៉ាងជិតស្និទ្ធតាមរយៈកិច្ចសហការជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និង/ឬ អង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័ន។

## ៧. សេចក្តីសន្និដ្ឋាន

គោលនយោបាយនេះ គឺជាការធ្វើបច្ចុប្បន្នភាពនៃ "គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥" ដែលត្រូវបានអភិវឌ្ឍឡើងដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងវិស័យកសិកម្ម រួមបញ្ចូល ទាំងផ្នែកចិញ្ចឹមសត្វ និងឧស្សាហកម្មកែច្នៃកសិផល។ "គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០"នេះ ត្រូវបានរៀបចំឡើងដោយឈរលើចក្ខុវិស័យ គោលបំណង និងយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីបំពេញបេសកកម្មក្នុងរយៈពេលមធ្យម និងវែង របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ គោលនយោបាយនេះ ត្រូវបានបញ្ចូលនូវវិធានការជាច្រើនដែលត្រូវបានបង្កើត និងរួមបញ្ចូលនូវការអនុវត្តនូវផ្នែកផ្សេងៗនៃអនុវិស័យទាំងអស់ក្រោមឱវាទរបស់ក្រសួង។ គោលនយោបាយនេះតម្រូវឱ្យមានការអនុវត្តរួមគ្នាទាំងវិស័យសាធារណៈ ដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ និងវិស័យឯកជន សំដៅជំរុញការអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹម និងជឿជាក់ថា រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តល់អាទិភាពខ្ពស់ដល់គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០។ ក្រសួងនឹងបន្តគាំទ្រយ៉ាងសកម្មដល់ការអនុវត្ត គោលនយោបាយនេះ ក្នុងការជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននានា និងដើម្បីធានាកំណើនវិស័យកសិកម្ម ទាំងការលើកស្ទួយជីវភាពគ្រួសារកសិកររួមជាមួយនឹងការកែលម្អសមិទ្ធកម្មសេដ្ឋកិច្ច និងបរិស្ថានជារួមផងដែរនៅតាមកសិដ្ឋានខ្នាតតូច មធ្យម និងធំ សត្តឃាតដ្ឋាន និងកសិធុរកិច្ច តាមរយៈការបង្កើតបរិយាកាសអំណោយផលសម្រាប់វិស័យឯកជន រួមទាំងការបង្កើតបរិយាកាសស្មើភាពគ្នា នឹងធ្វើឱ្យវិស័យនេះអាចបន្តអភិវឌ្ឍ និងទាក់ទាញ

---

[៣៨] *http://odacambodia.com/*

ការវិនិយោគពីប្រភពនានា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្តេជ្ញាយ៉ាងមុតមាំក្នុងការអនុវត្ត គោលនយោបាយនេះដោយមានបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំណល់សត្វ និងកសិកម្មដោយអនុលោម តាមបទប្បញ្ញត្តិបច្ចេកទេសត្រឹមត្រូវ និងប្រកបដោយអនាម័យល្អព្រមទាំងសង្ឃឹមថាសមិទ្ធផលដែលកើតដោយ ក្របខ័ណ្ឌគោលនយោបាយនេះនឹងផ្តល់ផ្លែផ្កា ជាវិជ្ជមានចាប់ពីពេលនេះតទៅ។

## ពាក្យសរសេរកាត់

| ពាក្យកាត់ | ពាក្យពេញ (ភាសាអង់គ្លេស) | ពាក្យពេញ (ភាសាខ្មែរ) |
|---|---|---|
| BCA | Biodigester Construction Agent | ភ្នាក់ងារសាងសង់ឡជីវឧស្ម័ន |
| BTIC | Biogas Technology & Information Center | មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ |
| COVID-19 | Worldwide pandemic of coronavirus disease 2019 | កូវីដ-១៩ |
| CSDG | Cambodian Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា |
| DSB | Domestic Scale Biodigester | ឡជីវឧស្ម័នគ្រួសារ |
| EDC | Electricit– du Cambodge | អគ្គិសនីកម្ពុជា |
| ESCO | Energy Service COmpany | ក្រុមហ៊ុនផ្តល់សេវាថាមពល |
| EVAP | Evaporative cooling system | ប្រព័ន្ធត្រជាក់ស្ងួត |
| GDAHP | General Directorate of Animal Health and Production | អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ |
| GDP | Gross domestic product | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) |
| GHG | Greenhouse gas | ឧស្ម័នផ្ទះកញ្ចក់ |
| $H_2S$ | Hydrogen sulfide gas | ឧស្ម័នអ៊ីដ្រូសែនស៊ុលហ្វីត |
| IPCC | Intergovernmental Panel on Climate change | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| kVA | Kilovolt Ampere | គីឡូវ៉ុលអំពែរ |
| KPI | Key performance indicator | សូចនាករសមិទ្ធកម្មសំខាន់ៗ |

| | | |
|---|---|---|
| NATWG | National Technical Advisory Working Group | ក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ |
| NSC | National Steering Committee | គណៈកម្មាធិការតម្រង់ទិសថ្នាក់ជាតិ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MISTI | Ministry of Industry, Science and Technology and Innovation | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| SMLSB | Small, Medium and large scale biodigesters | ឡជីវឧស្ម័នខ្នាតតូច មធ្យម និងធំ |
| MME | Ministry of Mines and Energy | ក្រសួងរ៉ែ និងថាមពល |
| NBP | National Biodigester Program | កម្មវិធីឡជីវឧស្ម័នជាតិ |
| NDC | Nationally Determined Contribution | របាយការណ៍រួមចំណែករបស់កម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| ODA | Official Development Aid | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| R&D | Research and Development | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| UNIDO | United Nationals Industrial Development Organization | អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម |

## ឧបសម្ព័ន្ធ "ក" ម៉ាទ្រីសនៃការអនុវត្តក្របខ័ណ្ឌគតិយុត្ត

| ក្របខ័ណ្ឌគតិយុត្ត | ឆ្នាំ | ស្ថាប័នដឹកនាំ ឬទទួលខុសត្រូវ |
|---|---|---|
| សេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតគណៈកម្មាធិការប្រឹក្សា តម្រង់ទិសថ្នាក់ជាតិដើម្បីសម្របសម្រួលការអនុវត្ត គោលនយោបាយ អភិវឌ្ឍន៍ឡជីវឧស្ម័នឆ្នាំ២០២១-២០៣០ | 2021 | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ |
| សេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ស្តីពីការបង្កើតក្រុមការងារផ្តល់ប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ ដើម្បីការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័នឆ្នាំ២០២១-២០៣០ | 2021 | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ |
| សេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការពង្រីកតួនាទីរបស់កម្មវិធីឡជីវឧស្ម័នជាតិឱ្យក្លាយជាអង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័ន ដើម្បីគ្រប់គ្រង និងសម្របសម្រួលក្នុងវិស័យនេះ។ | 2021 | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ |
| សេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីការបង្កើតកម្មវិធីឡជីវឧស្ម័នខេត្ត ដើម្បីការសម្របសម្រួល និងអនុវត្តសកម្មភាពនៅ ថ្នាក់មូលដ្ឋានព្រមទាំងរួមចំណែកដល់ការអនុវត្ត គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័នឆ្នាំ២០២១-២០៣០ | 2021 | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ |
| សេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីការបង្កើតមូលនិធិឡជីវឧស្ម័ន ដើម្បីគាំទ្រដល់វិស័យជីវឧស្ម័ន (កម្មវិធីឡជីវឧស្ម័នជាតិ និងកម្មវិធី/ក្រុមហ៊ុនផ្សេងៗ) | 2021 | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ |

# ឧបសម្ព័ន្ធ "ខ" ម៉ាទ្រីសនៃវិធានការគោលនយោបាយ និងផែនការសកម្មភាព

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករ សមិទ្ធកម្ម | ឆ្នាំគោលដៅ | ស្ថាប័ន ដឹកនាំឬ ទទួលខុសត្រូវ |
|---|---|---|---|---|
| ១. ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន៖<br><br>១.១ ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័នគ្រួសារ | ក) ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័នគ្រួសារដើម្បីកាត់បន្ថយការចម្លងជំងឺសត្វនិងរុក្ខជាតិ។ | តារាងទី៤ KPI ទី២ ទី៣ និងទី៥<br><br>តួលេខបញ្ចូលគ្នានៃឡជីវឧស្ម័នដែលបានសាងសង់ចំនួន៦៥,០០០ មុនឆ្នាំ ២០៣០<br><br>បរិមាណអុសដែលត្រូវបានកាត់បន្ថយចំនួន៧០៥ ពាន់តោនមុនឆ្នាំ២០៣០<br><br>បរិមាណសំណល់ឡជីវឧស្ម័នត្រូវបានប្រើប្រាស់ចំនួន ២០,០១៦ពាន់តោន មុនឆ្នាំ ២០៣០ | សកម្មភាពធ្វើជាបន្តបន្ទាប់<br><br>សូចនាករ SMART/គោលដៅប្រចាំឆ្នាំ នឹងត្រូវកំណត់ក្នុងផែនការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ | Apex body<br>NBP/GDAHP<br>PBP/PDAFF |
| | ខ) ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័នគ្រួសារដើម្បីកាត់បន្ថយ ការពឹងផ្អែកលើធនធានព្រៃឈើដែលគ្មានចីរភាព កាត់បន្ថយចំណាយលើឧស្ម័នធម្មជាតិ(LPG) និងបង្កើនគុណភាពខ្យល់ក្នុងអគារ។ | | | |
| | គ) ពង្រឹងការផ្សព្វផ្សាយឡជីវឧស្ម័នដល់កសិករតាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី/ខេត្ត ឱ្យពួកគាត់យល់ដឹងអំពីអត្ថប្រយោជន៍ និងបច្ចេកវិទ្យាឡជីវឧស្ម័ន។ | | | |
| | ឃ) អនុញ្ញាតឱ្យក្រុមហ៊ុន និងភ្នាក់ងារសាងសង់ឡដំឡើង/សាងសង់ឡជីវឧស្ម័នតាមបច្ចេកវិទ្យាប្រភេទផ្សេងៗគ្នាក្រៅពីប្រភេទបច្ចេកវិទ្យាដែលបានផ្គត់ផ្គង់ដោយកម្មវិធីឡជីវឧស្ម័នជាតិបើបច្ចេកវិទ្យានោះបំពេញតាមបទដ្ឋានបច្ចេកទេសសំណង់ឡជីវឧស្ម័នដែលទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬអង្គភាពទទួលបន្ទុកអភិបាលកិច្ចឡជីវឧស្ម័ន។ | | | |
| | ង) ធានាថាការផ្សព្វផ្សាយ និងការបង្កើនកម្រិតយល់ដឹងត្រូវបានអនុវត្តនៅ គ្រប់កម្រិតទាំងអស់ដោយដាក់បញ្ចូលឡជីវឧស្ម័នទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់។ | | | |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករសមិទ្ធកម្ម | ឆ្នាំគោលដៅ | ស្ថាប័នដឹកនាំឬទទួលខុសត្រូវ |
|---|---|---|---|---|
| | ច) ធានាឱ្យឡជីវឧស្ម័ននៅបន្តប្រើប្រាស់យូរអង្វែងដោយកែលម្អសេវាកម្ម ក្រោយពេលសាងសង់និងបង្កើតមធ្យោបាយទំនាក់ទំនងនានាដើម្បីផ្តល់ព័ត៌មានអំពីឡជីវឧស្ម័ន។ | | | |
| | ឆ) ប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធជីវឧស្ម័ននៅទូទាំងប្រទេសរបស់កម្មវិធីឡជីវឧស្ម័នជាតិក្នុងការជំរុញនិងការផ្សព្វផ្សាយអំពីជីវឧស្ម័ន។ | | | |
| ១.២ ជំរុញការវិនិយោគអាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម និងធំ ដែលអាចទុកចិត្តបាននៅកសិដ្ឋានចិញ្ចឹមសត្វ និងឧស្សាហកម្មកែច្នៃកសិផល | ក) បង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃឡជីវឧស្ម័នក្នុងការធ្វើឱ្យប្រតិបត្តិការអាជីវកម្ម និងបរិស្ថានប្រសើរឡើង ព្រមទាំងអត្ថប្រយោជន៍ ដទៃទៀតទៅធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ វិនិយោគិន និងកសិករជាដើម។ | តារាងទី៤ KPIទី៤ ទី៦ ទី៧និងទី៨ ចំនួនអាងប្រព្រឹត្តិកម្មជីវឧស្ម័នដែលបានសាងសង់ក្នុងនោះ៖<br>កសិដ្ឋាន៖ ៥០០ អាងខ្នាតមធ្យម និង២០អាងខ្នាតធំត្រឹមឆ្នាំ២០៣០<br><br>កសិធុរកិច្ច៖ ២០ អាងខ្នាតមធ្យម និងធំ ត្រឹមឆ្នាំ២០៣០<br><br>សមត្ថភាពដំឡើងសរុប៖ ១០៥MW ត្រឹមឆ្នាំ២០៣០ | កម្មភាពធ្វើជាបន្តបន្ទាប់<br><br>សូចនាក SMART/គោលដៅប្រចាំឆ្នាំនឹងត្រូវកំណត់ក្នុងផែនការត្រួតពិនិត្យតាមដាននិងការវាយតម្លៃ | Apex body NBP/GDAHP |
| | ខ) ជំរុញការប្រើប្រាស់ឡជីវឧស្ម័នឱ្យក្លាយជាដំណោះស្រាយក្នុងការគ្រប់គ្រងសំណល់កសិកម្ម (សត្វ និងដំណាំ)ប្រកបដោយនិរន្តភាព និងជាកាលានុវត្តភាពដើម្បីកាត់បន្ថយថ្លៃដើមប្រតិបត្តិការក្នុងការពង្រីក ឧស្សាហកម្មបសុសត្វ និងកសិឧស្សាហកម្មស្របតាមគោលនយោបាយ ផែនការ និងគោលដៅរបស់វិស័យកសិកម្ម។ | | | |
| | គ) ជំរុញការប្រើប្រាស់អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម និងខ្នាតធំ ដោយរៀបចំ របាយការណ៍ចង្អុលផ្លូវ (White Paper) ដែលបង្ហាញនូវបច្ចេកវិទ្យា និងជូនដំណឹងដល់ស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ អំពីផលចំណេញ ផ្នែកសេដ្ឋកិច្ចសំខាន់ៗ ដែលកសិដ្ឋានចិញ្ចឹមសត្វបែបពាណិជ្ជកម្មអាចទទួលបាននៅពេលប្រើប្រាស់ជីវឧស្ម័ន។ | | | |
| | ឃ) ជំរុញការធ្វើពាណិជ្ជូបនីយកម្មលើសំណល់អាងប្រព្រឹត្តិកម្មជីវឧស្ម័ន ដោយចាត់ទុកជាប្រភពចំណូលមួយផ្សេងទៀត | | | |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករសមិទ្ធកម្ម | ឆ្នាំគោលដៅ | ស្ថាប័នដឹកនាំឬទទួលខុសត្រូវ |
|---|---|---|---|---|
| | សម្រាប់អ្នកវិនិយោគក្នុងអាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម និងធំ។ | | | |
| | ង) ជំរុញនិងលើកទឹកចិត្តកសិករដែលប្រើប្រាស់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នឱ្យបង្កើតប្រព័ន្ធកសិកម្មចម្រុះ និងកសិកម្មសរីរាង្គដោយភ្ជាប់ឡជីវឧស្ម័នដើម្បីដាំដំណាំ។ | | | |
| ១.៣ ជំរុញការសាងសង់ និងប្រើប្រាស់ ឡជីវឧស្ម័ន នៅតាមសត្តឃាតដ្ឋាន | ក) រៀបចំបទប្បញ្ញត្តិអប្បបរមាស្តីពីការគ្រប់គ្រងសំណល់ចេញពីសត្តឃាតដ្ឋានឱ្យស្របតាមប្រកាសលេខ១០៨ និងប្រកាសលេខ២២៥ និងពិចារណាពីដាក់កំហិតឱ្យសាងសង់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន ដើម្បីធ្វើប្រព្រឹត្តកម្មសំណល់និងទាញយកថាមពលមកប្រើប្រាស់ឡើងវិញ។ | តារាងទី៤ KPI ទី៩<br><br>ចំនួនឡ/អាងដែលត្រូវសាងសង់មាន ៧៦ មុនឆ្នាំ២០៣០ | សកម្មភាពធ្វើជាបន្តបន្ទាប់<br><br>សូចនាករ SMART/គោលដៅប្រចាំឆ្នាំ នឹងត្រូវកំណត់ក្នុងផែនការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ | Apex body<br>NBP/GDAHP<br>BTIC/RUA<br>Private sector |
| | ខ) បង្កើនការយល់ដឹងអំពីការប្រើប្រាស់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នដែលជាដំណោះស្រាយសម្រាប់ការធ្វើប្រព្រឹត្តកម្មសំណល់ចេញពីសត្តឃាតដ្ឋាន រួមទាំងបង្កើនកម្រិតយល់ដឹងអំពីអត្ថប្រយោជន៍នៃការប្រើជីវឧស្ម័នផងដែរ។ | | | |
| | គ) អភិវឌ្ឍបច្ចេកវិទ្យាឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នសមស្របតាមទំហំសត្តឃាតដ្ឋានផ្សេងៗគ្នា ដោយសហការជាមួយកម្មវិធីឡជីវឧស្ម័នជាតិ មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) និងភាគីឯកជននានា រួមទាំងវិធានការដែលតម្រូវឱ្យប្រើប្រាស់ជីវឧស្ម័នទាំងអស់ និងការទុកដាក់ព្រមទាំងការប្រើប្រាស់សំណល់ឡជីវឧស្ម័នផងដែរ។ | | | |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករ សមិទ្ធកម្ម | ឆ្នាំគោលដៅ | ស្ថាប័ន ដឹកនាំឬ ទទួលខុសត្រូវ |
|---|---|---|---|---|
| **២. ជំរុញអភិបាលកិច្ច ការសម្របសម្រួល និងការធ្វើរបាយការណ៍** | ១. បន្ថែមភារកិច្ចដល់កម្មវិធីឡជីវឧស្ម័នជាតិដើម្បីទទួលបន្ទុក អភិបាលកិច្ច ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នដែលនៅក្រោម ការគ្រប់គ្រង និងចង្អុលបង្ហាញរបស់គណៈកម្មាធិការតម្រង់ទិស ថ្នាក់ជាតិ | សេចក្តីសម្រេចស្តីពីការបង្កើត អង្គភាពទទួលបន្ទុកអភិបាល កិច្ចឡជីវឧស្ម័ន/អាង ប្រព្រឹត្តិកម្ម ជីវឧស្ម័ន | ២០២២ | MAFF<br>NSC |
| | ២.ធានានូវការប្រកួតប្រជែងក្នុងទីផ្សារស្ថិតក្រោមការគ្រប់គ្រងដែល លក្ខខណ្ឌនៃការឧបត្ថម្ភធន និងពន្ធដារក្នុងកម្រិតប្រហាក់ប្រហែល សម្រាប់ក្រុមហ៊ុនសាងសង់ និងផ្គត់ផ្គង់ជីវឧស្ម័នទាំងអស់។ | សេចក្តីសម្រេចស្តីពីការគ្រប់ គ្រងនៃការឧបត្ថម្ភធន ថ្នាក់ជាតិសម្រាប់ឧស្សាហកម្ម ជីវឧស្ម័ន | ២០២២ | NSC<br>Apex body<br>GDAHP/NBP |
| | ៣. ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលនិងកិច្ចសន្ទនារវាង ភាគីពាក់ព័ន្ធនានា ដោយផ្តួចផ្តើមនូវការបង្កើតសហគមន៍/ សមាគមឡជីវឧស្ម័ន ។ | សហគមន៍/សមាគម ឡជីវឧស្ម័នត្រូវបានបង្កើត | ២០២២ | Apex body/NBP<br>BTIC/RUA<br>Private sector |
| | ៤. សហការជាមួយមជ្ឈមណ្ឌលឯកទេសដែលមានស្រាប់ក្នុងស្រុក ដូចជាមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC)ដើម្បីអនុវត្តសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ ព្រមទាំងសេវាកម្មពិគ្រោះយោបល់ក្នុងគោលបំណងជំរុញការអភិវ ឌ្ឍឧស្សាហកម្មជីវឧស្ម័ននៅក្នុងប្រទេស។ | ផែនការស្រាវជ្រាវ និង អភិវឌ្ឍន៍ ដោយធ្វើ បច្ចុប្បន្នភាពប្រចាំឆ្នាំ | ប្រចាំឆ្នាំ<br>សូចនាករ SMART/គោលដៅប្រចាំឆ្នាំ នឹងត្រូវកំណត់ក្នុងផែនការ ត្រួតពិនិត្យតាមដាន និងការវាយតម្លៃ | Apex body/NBP<br>BTIC/RUA |
| | ៥. ជូនដំណឹងភ្ជាប់នឹងការបណ្តុះបណ្តាលក្រុមហ៊ុនឡជីវឧស្ម័ន អំពីគោលនយោបាយ និងបទប្បញ្ញត្តិពាក់ព័ន្ធ។ | ផែនការអនុវត្តប្រចាំឆ្នាំរបស់ អង្គភាពទទួលបន្ទុកអភិបាល កិច្ច | ប្រចាំឆ្នាំ<br>សូចនាករ SMART/គោលដៅ | Apex body/NBP<br>BTIC/RUA |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករសមិទ្ធកម្ម | ឆ្នាំគោលដៅ | ស្ថាប័នដឹកនាំឬទទួលខុសត្រូវ |
|---|---|---|---|---|
| | | | ប្រចាំឆ្នាំ នឹងត្រូវកំណត់ក្នុងផែនការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃ | |
| | ៦. បង្កើតប្រព័ន្ធព័ត៌មានស្តីពីបច្ចេកទេសសាងសង់ និងប្រតិបត្តិការនៃឡជីវឧស្ម័ន និងផ្សព្វផ្សាយទៅបណ្តាអ្នកពាក់ព័ន្ធទូទាំងប្រទេស ដោយសហការជាមួយមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) សម្រាប់អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម និងធំ។ | ឯកសារស្តីពីបច្ចេកវិទ្យា ដោយធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ | ប្រចាំឆ្នាំ | NBP/GDAHP<br>Private sector<br>BTIC/RUA |
| | ៧. បង្កើតមូលដ្ឋានទិន្នន័យជាតិដែលគ្របដណ្តប់គ្រប់សកម្មភាពជីវឧស្ម័នទាំងអស់ ដើម្បីតាមដានការអនុវត្តគោលនយោបាយនេះ រួមទាំងការរៀបចំរបាយការណ៍ | មូលដ្ឋានទិន្នន័យឡជីវឧស្ម័នជាតិ | ឆ្នាំ២០២២ដោយធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ | Apex body/NBP |
| ៣. លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធគុណភាពឡជីវឧស្ម័ន | ១. រៀបចំ និងអនុវត្តបទដ្ឋានបច្ចេកទេសសំណង់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នឱ្យមានប្រសិទ្ធភាព ដោយបទដ្ឋានបច្ចេកទេសនេះត្រូវមានភាពច្បាស់លាស់ និងធានាលើគុណភាពសំណង់ សម្ភារឧបករណ៍បំពាក់ឡ ការប្រើប្រាស់ជីវឧស្ម័ន និងការបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់គ្រប់ប្រភេទ/ខ្នាតនៃឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នទាំងអស់។ | បទដ្ឋានបច្ចេកទេសសំណង់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន | បទដ្ឋានបច្ចេកទេសសំណង់សម្រាប់ឡជីវឧស្ម័នជាលក្ខណៈគ្រួសារនៅឆ្នាំ២០២២ ដោយត្រួតពិនិត្យឡើងវិញរៀងរាល់ឆ្នាំ | MAFF<br>Apex body<br>NBP/GDAHP<br>Private sector |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករ សមិទ្ធកម្ម | ឆ្នាំគោលដៅ | ស្ថាប័ន ដឹកនាំឬ ទទួលខុសត្រូវ |
|---|---|---|---|---|
| | ២. រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍បទដ្ឋានបច្ចេកទេសសំណង់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នរួមមួយ សម្រាប់គ្រប់ប្រភេទ/ខ្នាតនៃឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នក្នុងវិស័យកសិកម្មទាំងមូល។ | | បទដ្ឋានបច្ចេកទេសសំណង់សម្រាប់អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច ខ្នាតមធ្យម និងធំ នៅ ឆ្នាំ២០២៣ ដោយត្រួតពិនិត្យឡើងវិញ រៀងរាល់ឆ្នាំ | Apex body NBP/GDAHP |
| | ៣. ធ្វើអធិការកិច្ច ដើម្បីធានាបាននូវគុណភាពនៃឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន ដោយប្រើប្រាស់បទដ្ឋានបច្ចេកទេសសំណង់ឡជីវឧស្ម័ន/ អាងប្រព្រឹត្តិកម្មជីវឧស្ម័ន និងរៀបចំយន្តការផ្តល់វិញ្ញាបនបត្រដល់ ភ្នាក់ងារសាងសង់ ឡជីវឧស្ម័នឱ្យប្រែក្លាយជាសហគ្រិន។<br>៤. លើកទឹកចិត្តដល់ការប្រើប្រាស់បទដ្ឋានបច្ចេកទេសសំណង់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន ដើម្បីអភិវឌ្ឍន៍ធុរកិច្ចក្នុងវិស័យជីវឧស្ម័នឱ្យកាន់តែល្អប្រសើរឡើង ។ | នីតិវិធីស្តីពីការធ្វើអធិការកិច្ចគុណភាពត្រូវបានរៀបចំនិង អនុវត្ត | ឆ្នាំ២០២២តទៅ សូចនាករ SMART/ គោលដៅប្រចាំឆ្នាំ នឹងត្រូវកំណត់ក្នុងផែនការត្រួតពិនិត្យតាមដាន និងការវាយ តម្លៃ | Apex body NBP/GDAHP |
| | ៥. បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពក្រុមបច្ចេកទេស និងក្រុមអធិការកិច្ចដើម្បីត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តបទដ្ឋាន បច្ចេកទេសសំណង់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន។ | នីតិវិធីស្តីពីការចុះវិញ្ញាបនបត្រត្រូវបានរៀបចំ មូលដ្ឋានទិន្នន័យនៃអ្នកបច្ចេកទេស និងវិស្វករ | ២០២៣ | Apex body NBP/GDAHP |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករសមិទ្ធកម្ម | ឆ្នាំគោលដៅ | ស្ថាប័នដឹកនាំឬទទួលខុសត្រូវ |
|---|---|---|---|---|
| | | ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់នឹងត្រូវរៀបចំ | | |
| ៤. យន្តការគាំទ្រសារពើពន្ធ និងមិនមែនសារពើពន្ធ៖<br><br>៤.១ ឡជីវឧស្ម័នគ្រួសារ | ១. វាយតម្លៃឡើងវិញនូវតម្រូវការ និងទំហំនៃការឧបត្ថម្ភធនចំពោះឡជីវឧស្ម័នគ្រួសារ ដោយផ្អែកលើគោលការណ៍ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ផ្តល់ការឧបត្ថម្ភធនដែលមានភាពសមរម្យ ព្រមទាំងរៀបចំបង្កើតគោលការណ៍ណែនាំ ស្តីពីកម្រិតឧបត្ថម្ភធន និងអាចមានករណីលើកលែងសម្រាប់ក្រុមងាយរងគ្រោះ។<br>២. ប្រើប្រាស់ចំណូលពីឥណទានកាបោនសម្រាប់ការឧបត្ថម្ភធនក្នុងរយៈពេលខ្លី ឬមធ្យម ក្នុងករណីមូលនិធិពីដៃគូអភិវឌ្ឍន៍នានាត្រូវបានកាត់បន្ថយ | ផែនការអនុវត្តរបស់អង្គភាពទទួលបន្ទុកអភិបាលកិច្ច<br><br>របាយការណ៍ត្រួតពិនិត្យតាមដាន និងការវាយតម្លៃ | ប្រចាំឆ្នាំ | NSC<br>NATWG<br>Apex body<br>NBP/GDAHP |
| | ៣. សម្របសម្រួលលើការស្នើសុំការលើកលែងអាករលើតម្លៃបន្ថែមសម្រាប់ក្រុមហ៊ុនសាងសង់ឡជីវឧស្ម័នគ្រួសារ/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន ជាពិសេសការលើកលែងពន្ធនាំចូលចំពោះវត្ថុធាតុដើមសម្រាប់ការសាងសង់ឡ/អាង ចង្ក្រាន និងម៉ាស៊ីនភ្លើងប្រើជីវឧស្ម័ន ឧបករណ៍កត់ត្រា (Pay As You Go) ដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម។ | បទប្បញ្ញត្តិស្តីពីការលើកលែងពន្ធលើតម្លៃបន្ថែម<br>បទប្បញ្ញត្តិស្តីពីការលើកលែងពន្ធនាំចូល | ២០២២ | NSC<br>NATWG<br>Apex body<br>NBP/GDAHP |
| | ៤. បង្កើនកិច្ចសហប្រតិបត្តិការជាមួយធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងវិនិយោគិនដែលគិតពីផលប៉ះពាល់ផ្នែកសង្គមនិងបរិស្ថានដើម្បីផ្តល់ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបដល់កសិករ និងអ្នកពាក់ព័ន្ធក្នុងវិស័យឡជីវឧស្ម័ន។និងប្រើប្រាស់មូលនិធិឡជីវឧស្ម័នដើម្បីបង្កើតកម្ចីថ្មីៗ សម្រាប់ ការងារជីវឧស្ម័នដូចជាភតិសន្យាឈានទៅធ្វើជាម្ចាស់កម្មសិទ្ធិ សម្រាប់ការបង់ប្រាក់ | ផលិតផលកម្ចីថ្មី | ឆ្នាំ២០២២តទៅ<br>សូចនាករ SMART/គោលដៅប្រចាំឆ្នាំ នឹងត្រូវកំណត់ក្នុងផែនការត្រួតពិនិត្យ | NSC<br>NATWG<br>Apex body<br>NBP/GDAHP<br>Banks |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករ<br>សមិទ្ធកម្ម | ឆ្នាំគោលដៅ | ស្ថាប័ន<br>ដឹកនាំឬ<br>ទទួលខុសត្រូវ |
|---|---|---|---|---|
| | នៅពេលប្រើប្រាស់ (Pay As You Go) និងគំរូហិរញ្ញប្បទាន ដែលមាននវានុវត្តន៍ផ្សេងៗទៀត។ | | តាមដាន<br>និងការវាយ តម្លៃ | |
| ៤.២ ឡជីវឧស្ម័ន/ អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម និងធំ | ១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងសហការជាមួយ ក្រសួងរ៉ែ និងថាមពល ជាពិសេសអាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការអភិវឌ្ឍគោលនយោបាយថ្លៃលក់អគ្គិសនី សម្រាប់អគ្គិសនី ដែលផលិតថាមពលកកើតឡើងវិញក្នុងតម្លៃសមរម្យ ឬអនុញ្ញាត ឱ្យលក់អគ្គិសនីពីជីវឧស្ម័ន ទៅគ្រួសារឬសហគមន៍ ដែលនៅក្បែរ នោះដោយផ្ទាល់ក្នុងតម្លៃដូចគ្នានឹងអត្រាដែលផ្គត់ផ្គង់ដោយ សេវាករអគ្គិសនីឯកជន និង/ឬរដ្ឋនៅមូលដ្ឋាន។ | បទប្បញ្ញត្តិស្តីពីការលក់ អគ្គិសនី (ថ្លៃបន្ថែមសម្រាប់ លក់ទៅបណ្តាញអគ្គិសនីជាតិ (Feed-in Tariff) និង ការលក់អគ្គិសនីនៅមូលដ្ឋាន | ២០២២ | NATWG<br>Apex body<br>NBP/GDAHP |
| | ២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងសហការ ជាមួយក្រសួងបរិស្ថាន រួមទាំងក្រសួងពាក់ព័ន្ធនានា ដើម្បីជំរុញ និងសម្របសម្រួលដំណើរការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន សម្រាប់កសិដ្ឋានចិញ្ចឹមសត្វខ្នាតតូច មធ្យម និងធំ និងរោងចក្រកែច្នៃកសិផល ដើម្បីដោះស្រាយបញ្ហាប្រឈមនឹង ការគ្រប់គ្រងសំណល់ ការបំពុល និងផលប៉ះពាល់លើសុខភាព និង សុខុមាលភាពរបស់ ប្រជាជនដែលកំពុងរស់នៅក្នុងតំបន់នោះ ។ | បទប្បញ្ញត្តិស្តីពីផលប៉ះពាល់ បរិស្ថាននិងសង្គមត្រូវបាន អនុវត្តសម្រាប់ឡជីវឧស្ម័ន/ អាងប្រព្រឹត្តិកម្មជីវឧស្ម័ន ខ្នាតតូច មធ្យម និងធំ | ២០២២ | NATWG<br>Apex body<br>NBP/GDAHP |
| | ៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងសម្របសម្រួល លើការស្នើសុំការលើកលែងអាករលើតម្លៃបន្ថែមសម្រាប់ក្រុមហ៊ុនដែលដំឡើងឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម និងធំ ជាពិសេសពន្ធនាំចូល វត្ថុធាតុដើមសម្រាប់ការសាងសង់ (ឧទាហរណ៍ កៅស៊ូប៉ូលីអេទីឡែន (HDPE) កៅស៊ូក្រាល (Geotextile) និងបរិក្ខារ (ចង្ក្រាន ម៉ាស៊ីនភ្លើងប្រើជីវឧស្ម័ន ម៉ាស៊ីនបូមទឹកប្រើជីវឧស្ម័ន ឧបករណ៍គត់ត្រា (Pay As You Go) | បទប្បញ្ញត្តិស្តីពីការលើកលែង ពន្ធនាំចូល | ២០២២ | NATWG<br>Apex body<br>NBP/GDAHP |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករ សមិទកម្ម | ឆ្នាំគោលដៅ | ស្ថាប័ន ដឹកនាំឬ ទទួលខុសត្រូវ |
|---|---|---|---|---|
| | ឧបករណ៍ជកយកឧស្ម័ន H2S និងសារធាតុចាប់ យក H2S។ល។) ដើម្បីកាត់បន្ថយថ្លៃដើមសាងសង់ឡជីវឧស្ម័ន។ | | | |
| | ៤. សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុ ដើម្បីផ្តល់កម្ចីក្នុងអត្រាការប្រាក់ទាបដល់កសិករ និងក្រុមហ៊ុនសាងសង់ឡ។ | ផលិតផលកម្ចីដែលមានការប្រាក់សមរម្យ | ២០២២ សូចនាករ SMART/គោលដៅប្រចាំឆ្នាំ នឹងត្រូវកំណត់ក្នុងផែនការត្រួតពិនិត្យតាមដាន និងការវាយ តម្លៃ | Apex body<br>NATWG<br>NBP/GDAHP<br>Banks |
| ៥. បង្កើតនិងជំរុញសហគមន៍អ្នកប្រើប្រាស់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន | ១. រៀបចំបណ្តាញអ្នកប្រើប្រាស់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន។<br>២. គាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុក្នុងការបង្កើតសហគមន៍អ្នកប្រើប្រាស់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន។<br>៣. បង្កើនការគាំទ្រជំនាញបច្ចេកវិទ្យាលើការប្រើប្រាស់ឡជីវឧស្ម័ន ដោយភ្ជាប់ពួកគេទៅនឹងជាងសាងសង់ឡដែលបានបណ្តុះបណ្តាលត្រឹមត្រូវឬក្រុមហ៊ុនសាងសង់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន ដែលមាននៅក្នុងតំបន់នោះ។<br>៤. ជំរុញការអនុវត្តប្រព័ន្ធកសិកម្មចម្រុះក្នុងសហគមន៍ដើម្បីបង្កើនផលិតកម្មសត្វ និងកសិកម្មសរីរាង្គ/សុវត្ថិភាព។ | តារាងទី៤ KPIទី១០ សហគមន៍អ្នកប្រើប្រាស់ឡជីវឧស្ម័នចំនួន១៥ ត្រូវបានបង្កើតមុនឆ្នាំ២០៣០ | ២០២២ ដោយធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ សូចនាករ SMART/ គោលដៅប្រចាំឆ្នាំ នឹងត្រូវកំណត់ក្នុងផែនការត្រួតពិនិត្យតាមដាន និងការវាយ តម្លៃ | Apex body<br>NBP/GDAHP<br>PBP/PDAFF |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករ សមិទ្ធកម្ម | ឆ្នាំគោលដៅ | ស្ថាប័ន ដឹកនាំឬ ទទួលខុសត្រូវ |
|---|---|---|---|---|
| ៦. ជំរុញការស្រាវជ្រាវ អភិវឌ្ឍន៍ និងការប្រើប្រាស់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន | ១. សហការជាមួយមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) លើការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នខ្នាតតូច មធ្យម និងធំ រួមទាំងឧបករណ៍ដកយកឧស្ម័ន H2S ម៉ាស៊ីនភ្លើង/ម៉ាស៊ីនបូមទឹកប្រើជីវឧស្ម័ន ការរចនាឡជីវឧស្ម័ន និងការប្រើប្រាស់ជីកាកសំណល់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន។ | ផែនការសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ប្រចាំឆ្នាំ | ២០២២ ដោយធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ សូចនាករ SMART/ គោលដៅប្រចាំឆ្នាំនឹងត្រូវកំណត់ក្នុងផែនការត្រួតពិនិត្យតាមដាន និងការវាយ តម្លៃ | Apex body<br>NBP/GDAHP<br>BTIC/RUA |
| | ២. ជំរុញការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងបង្កើតខ្សែច្រវាក់តម្លៃនៃជីកាកសំណល់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន ជាពិសេសសម្រាប់កសិដ្ឋានខ្នាតតូច មធ្យម និងធំ និងឧស្សាហកម្មកែច្នៃកសិផល ដើម្បីកាត់បន្ថយការពឹងផ្អែកលើជីនាំចូល ការថែរក្សាដីជាតិដី កែលម្អគុណភាពនិង ជីវជាតិដី និងបង្កើនភាពធន់របស់ដីទល់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈថវិកាមូលនិធិឡជីវឧស្ម័ន។ | ឯកសារបច្ចេកវិទ្យាស្តីពីការប្រតិបត្តិល្អប្រសើរ និងបច្ចេកវិទ្យាថ្មី | ប្រចាំឆ្នាំ | Apex body<br>NBP/GDAHP<br>BTIC/RUA |
| | ៣. ជំរុញការការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការប្រើប្រាស់ជីវឧស្ម័ន ដូចជាការ បន្សុទ្ធជីវឧស្ម័នធ្វើជាឥន្ទនៈយានជំនិះឥន្ទនៈសម្រាប់ឡចំហាយ ឬ ច្រកជាកំប៉ុង/ធុងសម្រាប់ជាឥន្ទនៈចម្អិនអាហារ និងផ្សព្វផ្សាយបច្ចេកវិទ្យាថ្មីដែលបានកែលម្អទៅដល់ភាគី ពាក់ព័ន្ធនៅក្នុងវិស័យឯកជន។ | | | |
| ៧. បង្កើនការវិភាជន៍ថវិកាទៅ អគ្គនាយដ្ឋាន សុខភាពសត្វ និងផលិតកម្មសត្វ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបន្តការកៀរគរធនធានដើម្បីធានា ការអភិវឌ្ឍឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ននៅកម្ពុជា និងគ្រោងបង្កើនធនធានហិរញ្ញវត្ថុ រួមទាំងការវិភាជន៍ថវិកា ពី៤%ទៅ ១០% នៃថវិកាជាតិសម្រាប់អនុវិស័យ សុខភាពសត្វ និងផលិតកម្មសត្វ មុនឆ្នាំ២០៣០ ។ | ១០%មុនឆ្នាំ២០៣០ | ២០២២-២០៣០ | MAFF<br>NSC<br>GDAHP |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករ សមិទ្ធកម្ម | ឆ្នាំគោលដៅ | ស្ថាប័ន ដឹកនាំឬ ទទួលខុសត្រូវ |
|---|---|---|---|---|
| **ដើម្បីអភិវឌ្ឍន៍ ជីវឧស្ម័ន** | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏នឹងលើកទឹកចិត្តដល់ដៃគូអភិវឌ្ឍន៍នានា ឱ្យចូលរួមយ៉ាងផុសផុលក្នុងការអភិវឌ្ឍឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ននៅកម្ពុជាទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស។ | | | |
| **៨. ការកៀរគរ ហិរញ្ញប្បទាន អាកាសធាតុ** | ១. ជំរុញនិងចាត់ទុកការសាងសង់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន ជាមធ្យោបាយដ៏មានប្រសិទ្ធភាពដើម្បីកាត់បន្ថយការបញ្ចេញ ឧស្ម័នផ្ទះកញ្ចក់ និងបង្កើនភាពធន់នឹងអាកាសធាតុ ឱ្យស្របជាមួយរបាយការណ៍ រួមចំណែករបស់កម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួល អាកាសធាតុ(NDC)។ | តារាងទី៤ KPIទី១ ឧស្ម័នផ្ទះកញ្ចក់ចំនួន២.៥៥៤ $GgCO_2e$ ត្រូវបានកាត់បន្ថយ | ២០២២ ដោយ ធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ សូចនាករ SMART/ គោលដៅប្រចាំឆ្នាំ នឹងត្រូវកំណត់ក្នុងផែនការ ត្រួតពិនិត្យ តាមដាន និង ការវាយតម្លៃ | Apex body NATWG NBP/GDAHP |
| | ២. ជំរុញការប្រើឧបករណ៍ដុតជីវឧស្ម័នដែលមិនបានប្រើប្រាស់ ដើម្បីបង្ការ ការបង្ហុយឧស្ម័នមេតានទៅក្នុងបរិយាកាស និងបង្កើនសុវត្ថិភាពដល់មនុស្ស/សត្វ។ | | | |
| | ៣. ជំរុញការប្រើប្រាស់ជីវឧស្ម័នឱ្យអស់លទ្ធភាពដើម្បីបញ្ចៀសការបង្ហុយ ជីវឧស្ម័នដែលសល់មិនប្រើប្រាស់ទៅក្នុងបរិយាកាស ដោយអភិវឌ្ឍនិង ផ្សព្វផ្សាយបច្ចេកវិទ្យាជីវឧស្ម័នបន្ថែមលើចង្ក្រាន និង/ឬ លើកទឹកចិត្តឱ្យ មានការចែករំលែកជីវឧស្ម័នដែលនៅសល់ជាមួយ អ្នកជិតខាង ឬលក់អគ្គិសនីទៅឱ្យរោងចក្រកែច្នៃកសិផល ឬសេវាករ។ | | | |
| | ៤. ត្រូវគ្រប់គ្រងសំណល់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន ដែលបាន ធ្វើប្រព្រឹត្តកម្មរួចឱ្យបានត្រឹមត្រូវដើម្បីទប់ស្កាត់មិនឱ្យមានការប៉ះពាល់ ដល់បរិស្ថានបន្តទៀត។ អង្គភាពទទួលបន្ទុកអភិបាលកិច្ច ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្ម ជីវឧស្ម័ននៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នឹងបង្កើត | | | |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករ សមិទកម្ម | ឆ្នាំគោលដៅ | ស្ថាប័ន ដឹកនាំឬ ទទួលខុសត្រូវ |
|---|---|---|---|---|
| | គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសំណល់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន។ | | | |
| | ៥. អង្គភាពទទួលបន្ទុកអភិបាលកិច្ច/កម្មវិធីឡជីវឧស្ម័នជាតិនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នឹងជាអ្នកទទួលសិទ្ធិគ្រប់គ្រងឥណទានកាបោនសម្រាប់ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្ម ជីវឧស្ម័នដែលបានសាងសង់ដោយម្ចាស់ជំនួយសាធារណៈ និងដៃគូអភិវឌ្ឍន៍នានានៅពេលដែលសិទ្ធិការបានត្រូវបានផ្ទេរ និងគួរជាអ្នកទទួលហិរញ្ញប្បទានអាកាសធាតុ។ | ផែនការប្រើប្រាស់ថវិកាឥណទានកាបោនប្រចាំឆ្នាំ | ២០២២ | MAFF<br>National Steering Committee<br>Apex body<br>NBP/GDAHP |
| | ៦. កម្មវិធីឡជីវឧស្ម័នជាតិត្រូវផ្សព្វផ្សាយនិងបណ្តុះបណ្តាលលើការប្រើប្រាស់និងការថែទាំឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នដល់ម្ចាស់ឡ/អាង ដោយប្រើប្រាស់ថវិកាហិរញ្ញប្បទាន និងឥណទានកាបោន ។ | ផែនការធ្វើទីផ្សារកាបោនប្រចាំឆ្នាំ | ២០២២ ដោយ ធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ សូចនាករ SMART/ គោលដៅប្រចាំឆ្នាំ នឹង ត្រូវកំណត់ក្នុងផែនការត្រួតពិនិត្យតាមដាន និង ការវាយតម្លៃ | Apex body |
| | ៧. លើកកម្ពស់ការធ្វើទីផ្សារឥណទានកាបោន និងស្វែងរកទីផ្សារផ្សេងៗ ទៀតដើម្បីបង្កើនតម្លៃ និងប្រភពហិរញ្ញវត្ថុដែលរួមមានទាំងទីផ្សារ ក្នុងស្រុកផងដែរ។ សហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយ ចីរភាព/ក្រសួងបរិស្ថានលើការអនុវត្ត | ផែនការអនុវត្តNDCចំពោះជីវឧស្ម័ន | ២០២២ | NATWG<br>NSC<br>Apex body<br>NBP/GDAHP |

| វិធានការជាក់ស្តែង | ផែនការសកម្មភាព | សូចនាករ<br>សមិទកម្ម | ឆ្នាំគោលដៅ | ស្ថាប័ន<br>ដឹកនាំឬ<br>ទទួលខុសត្រូវ |
|---|---|---|---|---|
| | ផែនការជីវឧស្ម័ននៅក្នុង របាយការណ៍រួមចំណែករបស់កម្ពុជាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ(NDC)ដើម្បីទាក់ទាញហិរញ្ញប្បទានអាកាសធាតុ។ | | | |

# សន្ទានុក្រម

| អង់គ្លេស | ភាសាខ្មែរ | ការពន្យល់ |
|---|---|---|
| Apex | អង្គភាពទទួលបន្ទុកអភិបាលកិច្ច | ជាអង្គភាពដែលមានតួនាទីស្នូលក្នុងអភិបាលកិច្ចវិស័យណាមួយ។ ក្នុងគោលនយោបាយនេះ អង្គភាពទទួលបន្ទុកអភិបាលកិច្ចជាអ្នកអនុវត្តសំខាន់ ទទួលបន្ទុក គ្រប់គ្រង និងសម្របសម្រួល ការអភិវឌ្ឍវិស័យ ឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នសម្រាប់គ្រប់តួអង្គជីវឧស្ម័នទាំងឡាយដោយអព្យាក្រិត។ |
| Bio-slurry | ជីកាកសំណល់ឡ | សំណល់ហូរចេញពីឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័នដែលទទួលរងនូវការបំបែកធាតុក្នុងលក្ខខណ្ឌគ្មានអុកស៊ីសែន ហើយគ្មានក្លិនស្អុយ មិនទាក់ទាញសត្វល្អិតដូចជាជីលាមកសត្វ ព្រោះគ្រាប់ស្មៅនិងសត្វល្អិតត្រូវបានសម្លាប់ក្នុងឡជីវឧស្ម័ន/អាងប្រព្រឹត្តិកម្មជីវឧស្ម័ន។ |
| $CO_2e$ | សមមូលឧស្ម័នកាបូនិច | រង្វាស់សម្រាប់ប្រៀបធៀបការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីប្រភពផ្សេងៗដោយផ្អែកលើសក្ដានុពលកំណើនកំដៅផែនដី។ |
| Eutrophi-cation | អឺត្រូពីកាស្យុង | ជាកំណើននៃសារធាតុចិញ្ចឹមនៅក្នុងទឹក ដែលបណ្ដាលឱ្យសារាយលូតលាស់យ៉ាងច្រើននិងឆាប់រហ័ស។ នៅពេលរលួយ សារាយស្រូបយកអុកស៊ីសែនរលាយក្នុងទឹកនូវបរិមាណដ៏ច្រើនធ្វើអោយខូចគុណភាពទឹក ប៉ះពាល់ដល់ជីវិតរបស់ត្រីនិងភាវៈរស់ក្នុងទឹកដទៃទៀត។ |
| Good Animal Husbandry Practice (GAHP) | ការអនុវត្តការចិញ្ចឹមសត្វល្អ | ជាការអនុវត្តតាមបទដ្ឋានបច្ចេកទេសអនាម័យសម្រាប់ផលិតផលសត្វ និងនៅតាមសត្តឃាតដ្ឋាន ក៏ដូចជាការគ្រប់គ្រងលាមកសត្វនិងសំណល់រាវ ដើម្បីបង្ការការចម្លងនៃជំងឺស៊ូណូស សំដៅឆ្លើយតបនឹងតម្រូវការរបស់ទីផ្សារទាំងបរិមាណនិងគុណភាព ទាំងក្នុងស្រុកនិងនាំចេញ ព្រមទាំងកាត់បន្ថយថ្លៃផលិតកម្ម។ |
| PayGo | ការទូទាត់ប្រាក់នៅពេលដែលប្រើប្រាស់ | ជាដំណោះស្រាយហិរញ្ញប្បទានមួយប្រភេទដែលអ្នកប្រើសេវាធ្វើការទូទាត់ប្រាក់ទៅតាមបរិមាណដែលខ្លួនប្រើប្រាស់ជាក់ស្ដែងប៉ុណ្ណោះ ហើយអនុញ្ញាតឱ្យកសិករសងទៅក្រុមហ៊ុនវិញដោយបង់រំលស់ប្រចាំខែទូទាត់តាមទូរស័ព្ទចល័ត។ |
| Leasing | ភតិសន្យា | កិច្ចសន្យាសម្រាប់ប្រើប្រាស់ (ឧ.ដីធ្លីឬអគារ) ប៉ុន្តែមិនផ្ដល់កម្មសិទ្ធិឱ្យទេ |
| Zoonotic disease | ជំងឺស៊ូណូស | បណ្ដាប្រភេទជំងឺដែលឆ្លងពីសត្វទៅមនុស្ស និងមនុស្សទៅសត្វ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ០៩៩៥ សសរ.កសក

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារបច្ចេកទេសរៀបចំកសាង "គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មចិញ្ចឹមសត្វនៅកម្ពុជា ឆ្នាំ២០២១-២០៣០"

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

Scanned with CamScanner

## សម្រេច

**ប្រការ១.**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសរៀបចំកសាង "គោលនយោបាយអភិវឌ្ឍន៍ឧស្ម័នជីវៈនៅកម្ពុជា ឆ្នាំ២០២១-២០៣០" ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឌិប គីមសិា | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងកម្មវិធីឧស្ម័នជីវៈជាតិ | ប្រធាន |
| ២-ឯកឧត្តម | កៅ ផល | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាអនុប្រធានគណៈកម្មាធិការគ្រប់គ្រងកម្មវិធីឧស្ម័នជីវៈជាតិ | អនុប្រធាន |
| ៣-ឯកឧត្តម | តាន់ ផាន់ណារ៉ា | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | អនុប្រធាន |
| ៤-លោក | ឃី វិបុលបុត្រា | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥-លោក | គីម សាវឿន | អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងជានាយកកម្មវិធីឧស្ម័នជីវៈជាតិ | សមាជិក |
| ៦-លោក | រ៉ឹង ទ្រី | អនុប្រធានរដ្ឋបាលជលផល | សមាជិក |
| ៧-លោក | យុន កក្កដា | អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ៨-លោក | ម៉ាក់ សឿន | អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៩-លោក | សៀ រ៉ា | អនុប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ១០-លោក | ជា ច័ន្ទវាសនា | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ១១-លោក | ម៉ក់ ម៉ូនី | ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ | សមាជិក |
| ១២-លោក | ម៉ៅ មិនា | ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣-លោក | ស៊ាង សុខលីម | ប្រធាននាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងជាប្រធានកម្មវិធីឧស្ម័នជីវៈជាតិ | សមាជិក |
| ១៤-លោក | នូ វនិកា | ប្រធាននាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុពេទ្យបាល នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ១៥-លោក | ថោង សំណាង | ប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ១៦-លោក | សូ វិទូ | អនុប្រធាននាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ១៧-លោក | ស៊ា វិសាលរដ្ឋ | អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ១៨-លោក | ឃ្លាំង សុប៊ុណ្ណា | ប្រធានការិយាល័យគ្រប់គ្រងកាកសំណល់ នៃនាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ១៩-លោក | ហ៊ិន លីហួរ | អ្នកបច្ចេកទេសឧស្ម័នជីវៈរបស់មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវៈឧស្ម័នខ្នាតធំ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ២០-លោក | ឆេង រតនៈ | ប្រធានផ្នែករដ្ឋបាល និងគណនេយ្យ នៃកម្មវិធីឧស្ម័នជីវៈជាតិ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ២១-លោក | ហ៊ឹម សម្បត្តិ | ប្រធានផ្នែកបច្ចេកទេសឧស្ម័នជីវៈ នៃកម្មវិធីឧស្ម័នជីវៈជាតិ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ២២-លោក | Eric Buysman | ប្រធានក្រុមការងារកែសម្រួលគោលនយោបាយឧស្ម័នជីវៈ តំណាងអង្គការ UNIDO | សមាជិក |
| ២៣-លោក | ឆេង ង៉ូវវេង | ជំនាញការជីវៈឧស្ម័ន តំណាងអង្គការ UNIDO | សមាជិក |

Scanned with CamScanner

២៤-លោក លោកស្រី តំណាងផែ្នកអភិវឌ្ឍ និងវិស័យឯកជន សមាជិក

២៥-លោកស្រី គង់ រចនា មន្ត្រីគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយជំរុញការវិនិយោគលើជីវឧស្ម័នខ្នាតធំ តំណាងអង្គការ UNIDO លេខាធិការ

២៦-លោក សេង សុភាព ប្រធានផ្នែកអភិវឌ្ឍវិស័យឯកជន និងដឹកាកឡ នៃកម្មវិធីឡជីវ-ឧស្ម័នជាតិ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ លេខាធិការ។

**ប្រការ២ ..**

ក្រុមការងារបច្ចេកទេសរៀបចំកសាង "គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា ឆ្នាំ២០២១-២០៣០" មានភារកិច្ចដូចខាងក្រោម៖

- ប្រមូលទិន្នន័យ ព័ត៌មាន និងឯកសារសំខាន់ៗពីគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីរៀបចំជាធាតុចូលសម្រាប់ធ្វើការរៀបចំកសាងគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំដំណើរការសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ផ្សេងៗ ដើម្បីរៀបចំកសាងគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០ ជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធផ្សេងៗ
- រៀបចំបូកសរុបមតិយោបល់ដែលប្រមូលបានពីសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ផ្សេងៗ ឬទទួលបានពីអង្គភាពជំនាញក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីកែសម្រួលសំដៅធ្វើយ៉ាងណាឱ្យខ្លឹមសារនៃឯកសារគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០ ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន និងឆ្លើយតបបានទៅនឹងតម្រូវការអភិវឌ្ឍន៍ឡជីវឧស្ម័នក្នុងវិស័យកសិកម្មនៅកម្ពុជា។

**ប្រការ៣ ..**

អនុប្រធាន សមាជិក និងលេខាធិការនៃក្រុមការងារខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានភារកិច្ចផ្សេងៗ អនុប្រធានត្រូវដឹកនាំប្រជុំជំនួសតាមការប្រគល់ភារកិច្ចពីប្រធាន។

**ប្រការ៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ ..**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធានអង្គភាពដែលពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៤រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ

CS Scanned with CamScanner

ការប្រជុំលើកទី១ របស់ក្រុមការងារបច្ចេកទេសរៀបចំកសាង
"គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០"
ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ ម៉ោង៨.៣០ព្រឹក ដល់ម៉ោង១២.០០រសៀល
តាមរយៈកម្មវិធីZoom

**អ្នកចូលរួម៖**

| លរ. | ឈ្មោះ | តួនាទី | តួនាទីក្នុងក្រុមការងារបច្ចេកទេស | វត្តមាន |
|---|---|---|---|---|
| ១ | ឯកឧត្តម **ឱម គឹមស៊ា** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មាធិការតម្រង់ទិសកម្មវិធីឡជីវឧស្ម័នជាតិ | - ប្រធាន | អវត្តមាន(មានភារកិច្ចជាមួយឯកឧត្តមរដ្ឋមន្ត្រី) |
| ២ | ឯកឧត្តម **កៅ ផល** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាអនុប្រធានគណៈកម្មាធិការតម្រង់ទិសកម្មវិធីឡជីវឧស្ម័នជាតិ | - អនុប្រធាន | វត្តមាន |
| ៣ | ឯកឧត្តម **ស្រី វុឌ្ឍី** | អគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - អនុប្រធាន | វត្តមាន |
| ៤ | ឯកឧត្តម **តាន់ ផាន់ណារ៉ា** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | អនុប្រធាន | វត្តមាន |
| ៥ | លោក **ឃី វិបុលបុត្រា** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក | |
| ៦ | លោក **គឹម សារឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងជានាយកកម្មវិធីឡជីវឧស្ម័នជាតិ | សមាជិក | វត្តមាន |
| ៧ | លោក **ម៉ាក់ សឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក | វត្តមាន |
| ៨ | លោក **អ៊ឹង ទ្រី** | អនុប្រធានរដ្ឋបាលជលផល | សមាជិក | |
| ៩ | លោក **សៀ រ៉ា** | អនុប្រធានរដ្ឋបាលព្រៃឈើ | - សមាជិក | |
| ១០ | លោក **យុន កក្កដា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ | - សមាជិក | |
| ១១ | លោក **ម៉ក់ ម៉ូនី** | ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ | - សមាជិក | វត្តមាន |

| | | | | |
|---|---|---|---|---|
| ១២ | លោក **ស៊ាង សុខលីម** | ប្រធាននាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងជាប្រធានកម្មវិធីឡជីវឧស្ម័នជាតិ | - សមាជិក | វត្តមាន |
| ១៣ | លោក **នូ វនិកា** | ប្រធាននាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈ បសុព្យាបាលសត្វ នៃ អ.ស.ផ.ស. | - សមាជិក | |
| ១៤ | លោក **ថោង សំណាង** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយ បច្ចេកទេស និងនីតិកម្ម នៃ អ.ស.ផ.ស. | - សមាជិក | |
| ១៥ | លោក **ម៉ៅ មិនា** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - សមាជិក | |
| ១៦ | លោក **ជា ច័ន្ទវាសនា** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - សមាជិក | |
| ១៧ | លោក **សូ វិទូ** | អនុប្រធាននាយកដ្ឋានផលិតកម្មសត្វ នៃ អ.ស.ផ.ស. | - សមាជិក | វត្តមាន |
| ១៨ | លោក **ស៊ា វិសាលរដ្ឋ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ នៃ អ.ស.ផ.ស. | - សមាជិក | |
| ១៩ | លោក **ឃ្លាំង សុប៊ុណ្ណា** | ប្រធានការិយាល័យគ្រប់គ្រងកាកសំណល់នៃនាយកដ្ឋានផលិតកម្មសត្វ នៃ អ.ស.ផ.ស. | - សមាជិក | វត្តមាន |
| ២០ | លោក **ហ៊ិន លីហួរ** | អ្នកបច្ចេកទេសឡជីវឧស្ម័នរបស់មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ(BTIC) នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | - សមាជិក | វត្តមាន |
| ២១ | លោក **ឡោ លីតួ** | ប្រធាន មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ(BTIC) នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | - ភ្ញៀវ | វត្តមាន |
| ២២ | លោក **ឆេង រតនៈ** | ប្រធានផ្នែករដ្ឋបាល និងគណនេយ្យ នៃកម្មវិធីឡជីវឧស្ម័នជាតិ នៃ អស.ផ.ស. | - សមាជិក | វត្តមាន |

| | | | | |
|---|---|---|---|---|
| ២៣ | លោក **ហ៊ឹម សម្បត្តិ** | ប្រធានផ្នែកបច្ចេកទេសឡជីវឧស្ម័ន នៃកម្មវិធីឡជីវឧស្ម័នជាតិ នៃ អស.ផ.ស. | - សមាជិក | វត្តមាន |
| ២៤ | លោក Eric Buysman | ប្រធានក្រុមការងារកែសម្រួលគោលនយោបាយឡជីវឧស្ម័ន តំណាងអង្គការ UNIDO | - សមាជិក | វត្តមាន |
| ២៥ | លោក **ឆេង ង៉ូវវេង** | ជំនាញការជីវឧស្ម័ន តំណាងអង្គការUNIDO | - សមាជិក | វត្តមាន |
| ២៦ | លោកស្រី **គង់ រចនា** | មន្ត្រីគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយជម្រុញការវិនិយោគលើជីវឧស្ម័នខ្នាតធំ តំណាងអង្គការ UNIDO | - លេខាធិការ | វត្តមាន |
| ២៧ | លោក **សេង សុភាព** | ប្រធានផ្នែកអភិវឌ្ឍវិស័យឯកជន និងជីកាកឡជីវឧស្ម័ន នៃកម្មវិធីឡជីវឧស្ម័នជាតិ នៃ អ.ស.ផ.ស | - លេខាធិការ | វត្តមាន |
| ២៨ | លោកស្រី **ប៉ាក សុហៀង** | ជំនាញការយេនឌ័រ | ភ្ញៀវ | វត្តមាន |
| ២៩ | Dr S C Sangha | Deputy Secretary General, ADB Biodigester project | - ភ្ញៀវ | |
| ៣០ | Dr Sothoeun Suon | DDG of GDAHP for ADB Biodigester project | - ភ្ញៀវ | វត្តមាន |
| ៣១ | Mrs Heng Morany | DDG of GDAHP for Chinese Biodigester project and MAFF Gender focal point | - ភ្ញៀវ | វត្តមាន |
| | | **ថ្នាក់ខេត្ត** | | |
| ៤៤ | PDAFF-NPB<br>( 14 provinces )<br>1. ខេត្តបាត់ដំបង<br>2. ខេត្តបន្ទាយមានជ័យ<br>3. ខេត្តកំពង់ចាម<br>4. ខេត្តកំពង់ឆ្នាំង<br>5. ខេត្តកណ្តាល<br>6. ខេត្តកំពត<br>7. ខេត្តកំពង់ស្ពឺ<br>8. ខេត្តកំពង់ធំ<br>9. ខេត្តពោធិសាត់<br>10. ខេត្តព្រៃវែង<br>11. ខេត្តសៀមរាប | | - ភ្ញៀវ | វត្តមាន |

| | | | | |
|---|---|---|---|---|
| | 12. ខេត្តស្វាយរៀង<br>13. ខេត្តត្បូងឃ្មុំ<br>14. ខេត្តតាកែវ។ | | | |
| **វិស័យឯកជន** | | | | |
| ៤៥ | លោក **លី ឡាវីល** | ប្រធានក្រុមប្រឹក្សាភិបាល សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា | - ភ្ញៀវ | |
| ៤៦ | លោក **អ៊ុក វ៉ាន់ដា** | ប្រធាន ផ្នែកកំចីSMEs ធនាគារពាណិជ្ជកម្មក្រៅប្រទេស ) នៃកម្ពុជាFTB) | - ភ្ញៀវ | វត្តមាន |
| ៤៧ | លោក **Nikolai Schwarz** | នាយកក្រុមហ៊ុនATEC | - ភ្ញៀវ | វត្តមាន |
| ៤៨ | លោក **វ៉ាត់ ប៊ុនថង** | នាយកក្រុមហ៊ុន VW Gas | - ភ្ញៀវ | វត្តមាន |

កិច្ចប្រជុំលើកទី២ របស់ក្រុមការងារបច្ចេកទេសរៀបចំកសាង
"គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០"
ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ម៉ោង៨.៣០ព្រឹក ដល់ម៉ោង១២.០០រសៀល
តាមរយៈកម្មវិធីZoom

**អ្នកចូលរួម៖**

| លរ. | ឈ្មោះ | តួនាទី | តួនាទីក្នុងក្រុមការងារបច្ចេកទេស | វត្តមាន |
|---|---|---|---|---|
| ១ | ឯកឧត្តម **ឋិម គឹមស៊ា** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មាធិការ តម្រង់ទិសកម្មវិធីឡជីវឧស្ម័នជាតិ | - ប្រធាន | វត្តមាន |
| ២ | ឯកឧត្តម **កៅ ផល** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាអនុប្រធានគណៈកម្មាធិការ តម្រង់ទិសកម្មវិធីឡជីវឧស្ម័នជាតិ | - អនុប្រធាន | វត្តមាន |
| ៣ | ឯកឧត្តម **ស្រី វុឌ្ឍី** | អគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - អនុប្រធាន | វត្តមាន |
| ៤ | ឯកឧត្តម **តាន់ ផាន់ណារ៉ា** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | អនុប្រធាន | វត្តមាន |
| ៥ | លោក **ឃី វិបុលបុត្រា** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក | វត្តមាន |
| ៦ | លោក **គឹម សារឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងជានាយកកម្មវិធីឡជីវឧស្ម័នជាតិ | សមាជិក | វត្តមាន |
| ៧ | លោក **ម៉ាក់ សឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក | វត្តមាន |
| ៨ | លោក **អ៊ឹង ទ្រី** | អនុប្រធានរដ្ឋបាលជលផល | សមាជិក | វត្តមាន |
| ៩ | លោក **សៀ រ៉ា** | អនុប្រធានរដ្ឋបាលព្រៃឈើ | - សមាជិក | អវត្តមាន |
| ១០ | លោក **ឃុន កក្កដា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ | - សមាជិក | អវត្តមាន |
| ១១ | លោក **ម៉ក់ ម៉ូនី** | ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ | - សមាជិក | វត្តមាន |

| | | | | |
|---|---|---|---|---|
| ១២ | លោក **ស៊ាង សុខលីម** | ប្រធាននាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងជាប្រធានកម្មវិធីឡជីវឧស្ម័នជាតិ | - សមាជិក | វត្តមាន |
| ១៣ | លោក **នូ និកា** | ប្រធាននាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈ បសុព្យាបាលសត្វ នៃ អ.ស.ផ.ស. | - សមាជិក | អវត្តមាន |
| ១៤ | លោក **ថោង សំណាង** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយ បច្ចេកទេស និងនីតិកម្ម នៃ អ.ស.ផ.ស. | - សមាជិក | វត្តមាន |
| ១៥ | លោក **ម៉ៅ មិនា** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - សមាជិក | អវត្តមាន |
| ១៦ | លោក **ជា ច័ន្ទវាសនា** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - សមាជិក | អវត្តមាន |
| ១៧ | លោក **សូ រិទ្ធ** | អនុប្រធាននាយកដ្ឋានផលិតកម្មសត្វ នៃ អ.ស.ផ.ស. | - សមាជិក | វត្តមាន |
| ១៨ | លោក **ស៊ា វិសាលរដ្ឋ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ នៃ អ.ស.ផ.ស. | - សមាជិក | អវត្តមាន |
| ១៩ | លោក **ឃ្លាំង សុប៊ុណ្ណា** | ប្រធានការិយាល័យគ្រប់គ្រងកាកសំណល់នៃនាយកដ្ឋានផលិតកម្មសត្វ នៃ អ.ស.ផ.ស. | - សមាជិក | វត្តមាន |
| ២០ | លោក **ហ៊ិន លីហួរ** | អ្នកបច្ចេកទេសឡជីវឧស្ម័នរបស់មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ(BTIC) នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | - សមាជិក | វត្តមាន |
| ២១ | លោក **ឡោ លីតួ** | ប្រធាន មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មាន ជីវឧស្ម័នខ្នាតធំ(BTIC) នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | - ភ្ញៀវ | វត្តមាន |
| ២២ | លោក **ឆេង រតនៈ** | ប្រធានផ្នែករដ្ឋបាល និងគណនេយ្យ នៃកម្មវិធីឡជីវឧស្ម័នជាតិ នៃ អស.ផ.ស. | - សមាជិក | វត្តមាន |

| | | | | |
|---|---|---|---|---|
| ២៣ | លោក **ហ៊ឹម សម្បត្តិ** | ប្រធានផ្នែកបច្ចេកទេសឡជីវឧស្ម័ន នៃកម្មវិធីឡជីវឧស្ម័នជាតិ នៃ អស.ផ.ស. | - សមាជិក | វត្តមាន |
| ២៤ | លោក Eric Buysman | ប្រធានក្រុមការងារកែសម្រួលគោលនយោបាយឡជីវឧស្ម័ន តំណាងអង្គការ UNIDO | - សមាជិក | អវត្តមាន |
| ២៥ | លោក **ឆេង ង៉ូវវេង** | ជំនាញការជីវឧស្ម័ន តំណាងអង្គការUNIDO | - សមាជិក | វត្តមាន |
| ២៦ | លោកស្រី **គង់ រចនា** | មន្ត្រីគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយជម្រុញការវិនិយោគលើជីវឧស្ម័នខ្នាតធំ តំណាងអង្គការ UNIDO | - លេខាធិការ | វត្តមាន |
| ២៧ | លោក **សេង សុភាព** | ប្រធានផ្នែកអភិវឌ្ឍវិស័យឯកជន និងជីកាកឡជីវឧស្ម័ន នៃកម្មវិធីឡជីវឧស្ម័នជាតិ នៃ អ.ស.ផ.ស | - លេខាធិការ | វត្តមាន |
| | | **ថ្នាក់ខេត្ត** | | |
| | PDAFF-NPB<br>( 14 provinces )<br>1. ខេត្តបាត់ដំបង<br>2. ខេត្តបន្ទាយមានជ័យ<br>3. ខេត្តកំពង់ចាម<br>4. ខេត្តកំពង់ឆ្នាំង<br>5. ខេត្តកណ្តាល<br>6. ខេត្តកំពត<br>7. ខេត្តកំពង់ស្ពឺ<br>8. ខេត្តកំពង់ធំ<br>9. ខេត្តពោធិសាត់<br>10. ខេត្តព្រៃវែង<br>11. ខេត្តសៀមរាប<br>12. ខេត្តស្វាយរៀង<br>13. ខេត្តត្បូងឃ្មុំ<br>14. ខេត្តតាកែវ។ | | - ភ្ញៀវ | វត្តមាន |
| | | **វិស័យឯកជន** | | |
| ៤២ | លោក **លី ឡាវីល** | ប្រធានក្រុមប្រឹក្សាភិបាល សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា | - ភ្ញៀវ | វត្តមាន |
| ៤៣ | លោក **មាន ច័ន្ទណារិទ្ធ** | ធនាគារពាណិជ្ជកម្មក្រៅប្រទេស ) នៃកម្ពុជាFTB) | - ភ្ញៀវ | វត្តមាន |

| | | | | |
|---|---|---|---|---|
| ៤៤ | លោក Nikolai Schwarz | នាយកក្រុមហ៊ុនATEC | - ភ្ញៀវ | វត្តមាន |
| ៤៥ | លោក វ៉ាត់ ប៊ុនថង | នាយកក្រុមហ៊ុន VW Gas | - ភ្ញៀវ | វត្តមាន |
| ៤៦ | Mr. Wong Keet Loong | CEO, Credit Guarantee Corporation of Cambodia Plc. | - ភ្ញៀវ | វត្តមាន |
| ៤៧ | Mr Zola Taing | Public-Private Dialogue Officer, European Chamber of Commerce in Cambodia | - ភ្ញៀវ | វត្តមាន |
| ៤៨ | Mr. Ieuk Dana | Soma Energy | - ភ្ញៀវ | វត្តមាន |
| ៤៩ | BY SOKUNTHEA | Food Security Progamme Officer at European Commission Cambodia | - ភ្ញៀវ | វត្តមាន |
| ៥០ | Mr. Lim Darun | Netherlands Development Organization ( SNV ) Cambodia | - ភ្ញៀវ | វត្តមាន |
| ៥១ | H.E. Tin Ponlok | Secretary of State, MoE | - ភ្ញៀវ | វត្តមាន |
| ៥២ | H.E. Chea Chantou | Deputy Secretary General, NCSD | - ភ្ញៀវ | វត្តមាន |
| ៥៣ | Mr. Men Seanchhun | MEF | - ភ្ញៀវ | វត្តមាន |
| ៥៤ | Sam Nang | | - ភ្ញៀវ | វត្តមាន |
| ៥៥ | But Bunmakara | | - ភ្ញៀវ | វត្តមាន |
| ៥៦ | By Sokunthea | | - ភ្ញៀវ | វត្តមាន |
| ៥៧ | Sem Souphea | | - ភ្ញៀវ | វត្តមាន |